សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et Des Sciences Économiques

Royal University of Law Economics

# សារណាបញ្ចប់ការសិក្សា

# ទោស និង ការអនុវត្តទោសព្រហ្មទណ្ឌកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ភិក្ខុ **ចិន ផៃយ៉ាភុត**

លោក **ឈឹម ដាវីត**

ណែនាំដោយ

លោក **ជួន ម៉ុនធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទឈ្មោះ **ចិន ផៃយ៉ាគុត** និងឈ្មោះ **ឈឹម ដាវីត** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៤ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំសិក្សា ២០២៣-២០២៤។

**សូមគោរពថ្លែងនូវកតញ្ញុតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ**

| | | | |
|---|---|---|---|
| លោកឪពុក | **ចិន សារិទ្ធ** | លោកឪពុក | **ឈឹម ឆួន** |
| អ្នកម្តាយ | **សូត សុមុន** | អ្នកម្តាយ | **ឆឹង ស៊ីណាត** |

ដែលអ្នកមានគុណបានផ្តល់កំណើត និងអត់ធ្មត់ប្រឹងប្រែងតស៊ូធ្វើការសព្វគ្រប់បែបយ៉ាង ដើម្បីចិញ្ចឹមបីបាច់ថែរក្សារូបកូនតាំងពីនៅតូចរហូតដល់ធំពេញវ័យ ហើយព្រមទាំងបានឧបត្ថម្ភផ្គត់ផ្គង់ ទំនុកបម្រុងឲ្យរូបកូនបានចូលសិក្សាតាំងពីថ្នាក់បឋមសិក្សារហូតដល់រូបកូនបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។ មិនតែប៉ុណ្ណោះលោក ទាំងពីរបានលះបង់នូវកម្លាំងកាយ កម្លាំងចិត្ត បង្ហាត់បង្រៀន អប់រំណែនាំ ទូន្មានប្រៀនប្រដៅ និងជួយជំរុញ លើកទឹកចិត្តដល់រូបកូនឱ្យខំប្រឹងប្រែងរៀនសូត្រ ដើម្បីឱ្យរូបកូនមានអនាគតភ្លឺស្វាង និងអភិវឌ្ឍខ្លួនក្លាយជាកូនល្អ សិស្សល្អ ពលរដ្ឋល្អ នៅក្នុងសង្គមជាតិទៀតផង។

ហើយក៏ពួកខ្ញុំបាទសូមគោរពអរគុណ ឯកឧត្តមបណ្ឌិត **លុយ ចន្ថា** សាកលវិទ្យាធិការ ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស រួមទាំងលោក លោកស្រីសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលោកបាន ខិតខំដឹកនាំគ្រប់គ្រង បង្ហាត់បង្រៀន និងផ្តល់នូវចំណេះដឹងក្នុងការជួយតម្រង់ទិសដៅដល់រូបយើងខ្ញុំតាំងពីឆ្នាំ សិក្សាថ្នាក់មូលដ្ឋាន រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនេះដោយជោគជ័យ ប្រកបដោយក្រមសីលធម៌។

ជាពិសេសគោរពអរគុណដល់ លោកគ្រូ **ជួន ម៉ុនធី** ដែលលោកបានខិតខំចំណាយពេលវេលាដ៏មានតម្លៃផ្តល់នូវគំនិតយោបល់ វិធីសាស្ត្រសិក្សាស្រាវជ្រាវ បង្ហាត់បង្ហាញផ្តល់នូវមតិកែលម្អ និងជួយជ្រោមជ្រែងក្នុងការសរសេរកិច្ចការស្រាវជ្រាវ មួយនេះតាំងពីដើមរហូតដល់ចប់ស្នាដៃ។ ស្នាដៃដែលកើតចេញពីការស្រាវជ្រាវមួយនេះពិតជាមិនអាចមាន អត្ថិភាពឡើយ ប្រសិនបើគ្មានការជ្រោមជ្រែងពីលោកគ្រូ ។

ជាចុងបញ្ចប់ យើងខ្ញុំសូមបួងសួងដល់វត្ថុសក្តិសិទ្ធទាំងឡាយក្នុង ព្រះរាជាណាចក្រកម្ពុជាជួយប្រសិទ្ធ ពរជ័យជូនអ្នកមានគុណទាំងទ្វេ ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យនិស្សិត និងមិត្តជាទីស្រលាញ់រាប់អានទាំងអស់ ឲ្យជួបតែនឹងសេចក្តីសុខចម្រើន សុខភាពល្អ នៅក្នុងជីវិតតរៀងទៅ ព្រមទាំងជួបប្រទះ តែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀតឃ្លាឡើយ។

# **អារម្ភកថា**

ក្រោយពីបានឆ្លងកាត់ការសិក្សា និងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល៤ឆ្នាំកន្លងមកនេះ ដោយការខិតខំប្រឹងប្រែង ក្នុងការរៀនសូត្រដើម្បីទទួលបានចំណេះដឹងពី លោក លោកស្រី សាស្ត្រាចារ្យនៅក្នុងសាកលវិទ្យាល័យ យើងខ្ញុំទាំងពីររូបត្រូវបានលើកទឹកចិត្ត និងទទួលបានការអនុញ្ញាតពីសាកលវិទ្យាល័យដើម្បីសរសេរសារណាបញ្ចប់ការ សិក្សាក្រោមប្រធានបទស្តីពី **ទោសក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា និង ការអនុវត្តទោសព្រហ្មទណ្ឌកម្ពុជា** ។

មូលហេតុដែលយើងខ្ញុំទាំងពីររូបជ្រើសរើសយកប្រធានបទមួយនេះ គឺដោយសារក្រុមយើងខ្ញុំចង់សិក្សាស្វែងយល់បន្ថែម ឲ្យកាន់តែស៊ីជម្រៅទៅលើផ្នែកព្រហ្មទណ្ឌ ដែលជាផ្នែកដ៏សំខាន់នៅក្នុងការអនុវត្តច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ជាពិសេសទាក់ទងនឹងទោសព្រហ្មទណ្ឌ ការអនុវត្តទោស និងការប្រកាសទោសរបស់តុលាការនៅក្នុងប្រព័ន្ធច្បាប់។

ក្រុមយើងខ្ញុំមានសេចក្តីសោមនស្សរីករាយពន់ពេកដែលមានឱកាសក្នុងការសិក្សាស្រាវជ្រាវ និងរៀបចំ សរសេរសារណានេះក្រោមការណែនាំដោយលោក **ជួន ប៊ុនធី** ដែលជា សាស្ត្រាចារ្យផ្នែកច្បាប់មួយរូបដែល មានបទពិសោធន៍ច្រើនឆ្នាំទាក់ទងនឹងវិស័យសាធារណៈ។ សារណាមួយនេះមានទិសដៅស្រាវជ្រាវប្រមូលផ្តុំ និងចងក្រងក្នុងគោលបំណងបន្សល់ទុកជាឯកសារ សម្រាប់បំពេញនូវតម្រូវការរបស់សិស្សនិស្សិតជំនាន់ក្រោយ យកទៅសិក្សាស្រាវជ្រាវបន្ថែមទៀត ដើម្បីបង្កើននូវចំណេះដឹងក៏ដូចជាការយល់ដឹងអំពីច្បាប់ព្រហ្មទណ្ឌឲ្យកាន់តែទូលំទូលាយនឹងដើម្បីបានជាប្រយោជន៍សម្រាប់ប្រឡងប្រជែងផ្នែកច្បាប់ដែលទាក់ទងនឹងទោសព្រហ្មទណ្ឌនិងការអនុវត្តទោសព្រហ្មទណ្ឌផងដែរ។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរនាក់សង្ឃឹមថាសារណាបញ្ចប់ការសិក្សានេះនឹងអាចធ្វើជាឯកសារជំនួយក្នុងការសិក្សាស្រាវជ្រាវក្នុងរឿងព្រហ្មទណ្ឌដល់អ្នកសិក្សាជំនាន់ក្រោយ។ ទន្ទឹមនឹងនេះផងដែរ យើងខ្ញុំទាំងពីរសូម ធ្វើការអធ្យាស្រ័យទុកជាមុនចំពោះចំណុចខ្វះខាត កំហុសខុសឆ្គងទាំងខ្លឹមសារ ឃ្លាប្រយោគ ព្រមទាំង អក្ខរា វិរុទ្ធ ដោយអចេតនា ឬ ដោយប្រការណាមួយ។ យើងខ្ញុំទាំងពីររង់ចាំទទួលការរិះគន់ ការកែតម្រូវ ដើម្បីស្ថាបនា គ្រប់បែបយ៉ាងពីសំណាក់ លោក លោកស្រី សាស្ត្រាចារ្យ សិស្សនិស្សិត មិត្តអ្នកអាន និងអ្នកស្តាប់ទាំងអស់គ្នា ដើម្បីឱ្យសារណានេះកាន់តែមានភាពល្អប្រសើរឡើង។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម**......1
១. លំនាំបញ្ហានៃការស្រាវជ្រាវ......1
២. ចំណោទបញ្ហា......1
៣. គោលបំណងនៃការស្រាវជ្រាវ......២
៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ......២
៥. វិធីសាស្ត្រនៃការស្រាវជ្រាវ......២
៦. សារៈសំខាន់នៃការស្រាវជ្រាវ......៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ......៣

**ជំពូកទី១**

**ទោសក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា**

**ផ្នែកទី១ សញ្ញាណទូទៅនៃទោសព្រហ្មទណ្ឌកម្ពុជា**......៤
**១ អត្ថន័យនៃទោសព្រហ្មទណ្ឌ**......៤
**២ ចរិកលក្ខណៈនៃទោសព្រហ្មទណ្ឌ**......៤
២.១ គោលការណ៍នៃការកំណត់ទោសដោយច្បាប់......៤
២.២ គោលការណ៍នៃការប្រកាសទោសដោយតុលាការ......៥
**៣ មុខងារនៃទោសព្រហ្មទណ្ឌ**......៥
៣.១ មុខងារបង្ក្រាប និងដាក់ទណ្ឌកម្ម......៥
៣.២ មុខងាបន្លាច និងបង្ការ......៥
៣.៣ មុខងារអប់រំកែប្រែនិងសម្រួលទណ្ឌិតឲ្យធ្វើសមាហរណកម្មចូលទៅរស់នៅក្នុងសង្គមវិញ......៦
**ផ្នែកទី២ ប្រភេទនៃទោសព្រហ្មទណ្ឌ**......៦
**១. មូលទោស**......៦
១.១ អត្ថន័យនៃមូលទោស......៦
១.២ ប្រភេទនៃមូលទោស......៦
១.២.១ ទោសដាក់ពន្ធនាគា......៦
**២. ទោសបន្ថែម**......៧
២.១ អត្ថន័យនៃទោសបន្ថែម......៧
២.២ លក្ខខណ្ឌនៃទោសបន្ថែម......៧

២.៣ ប្រភេទនៃទោសបន្ថែម ......................................................................................៧

**៣. ទោសជំនួស**..............................................................................................៩

៣.១ អត្ថន័យនៃទោសជំនួស ................................................................................៩

៣.២ ប្រភេទនៃទោសជំនួស ...................................................................................៩

៣.២.១ ទោសការងារសហគមន៍ .............................................................................៩

៣.២.២ ទោសការស្តីបន្ទោស.....................................................................................៩

## ជំពូកទី២

## ការអនុវត្តទោសក្នុងច្បាប់ព្រហ្មទណ្ឌ

**ផ្នែកទី១ ទោសដែលត្រូវអនុវត្តចំពោះរូបវន្តបុគ្គលជានីតិជន** ..........................១១

**១. មូលទោស** ................................................................................................ ១១

១.១ ទោសដាក់ពន្ធនាគារ.......................................................................................១១

១.២ ទោសពិន័យ ..................................................................................................១២

**២ ទោសបន្ថែម** ..................................................................................................១២

**៣ ទោសជំនួស** ...................................................................................................១៧

៣.១ ទោសការងារសហគមន៍...................................................................................១៧

៣.២ ទោសស្តីបន្ទោស ............................................................................................១៨

**ផ្នែកទី២ ទោសដែលត្រូវអនុវត្តចំពោះរូបវន្តបុគ្គលជាអនីតិជន** .........................១៩

**១. មូលទោស**......................................................................................................១៩

**២. ទោសបន្ថែម** ...................................................................................................២០

**៣. ទោសជំនួស** ...................................................................................................២១

**ផ្នែកទី៣ ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល** ...................................................២១

**១ ទោសពិន័យក្នុងឋានៈជាមូលទោស**.........................................................................២១

**២ ទោសបន្ថែម** ....................................................................................................២១

## ជំពូកទី៣

## នីតិវិធីនៃការអនុវត្តទោស និងមូលហេតុទូទៅដែលនាំឲ្យមានផលប៉ះពាល់ដល់ការអនុវត្តទោស

**ផ្នែកទី១ នីតិវិធីអនុវត្តសេចក្តីសម្រេចរបស់តុលាការពាក់ព័ន្ធនឹងមូលទោស**....២៣

**១. ការអនុវត្តទោសដាក់ពន្ធនាគារ** ...... ២៣
១.១ ការអនុវត្តទោសចំពោះបុគ្គលដែលជាប់ឃុំ...... ២៣
១.២ ការអនុវត្តទោសចំពោះបុគ្គលដែលនៅក្រៅឃុំ ...... ២៤
**២. ការអនុវត្តទោសពិន័យ** ...... ២៥
២.១ ការដាស់តឿនឱ្យបង់ប្រាក់ពិន័យ...... ២៥
២.២ ការបង្ខំដល់រូបរាយកាយ ...... ២៦
២.២.១ ការបង្ខំដល់រូបកាយក្នុងករណីមិនបង់ប្រាក់ពិន័យ និងប្រាក់ពន្ធនីតិវិធី...... ២៦
២.២.២ ការបង្ខំដល់រូបកាយក្នុងករណីមិនបង់ប្រាក់សំណងរដ្ឋប្បវេណី និងជម្ងឺចិត្ត ... ២៧
២.២.៣ ចិរវេលានៃការបង្ខំរូបកាយ និងជនដែលមានសមត្ថភាពអាចទទួល
រងនូវការបង្ខំរូបកាយ ...... ២៧
**ផ្នែកទី២ មូលហេតុទូទៅនាំឲ្យមានផលប៉ះពាល់ដល់ការអនុវត្តទោស** ...... ២៨
**១. អាជ្ញាយុកាលនៃទោស** ...... ២៨
១.១ ដែនអនុវត្តអាជ្ញាយុកាលនៃទោស ...... ២៩
១.២ រយៈពេលអាជ្ញាយុកាលនៃទោស ...... ៣០
**២. ការបន្ធូរបន្ថយទោស និងការលើកលែងទោស** ...... ៣០
២.១ លក្ខខណ្ឌនៃការបន្ធូរបន្ថយទោស និងការលើកលែងទោស ...... ៣០
២.១.១ លក្ខខណ្ឌ និងចរិកលក្ខណៈសម្បត្តិរបស់ទណ្ឌិត...... ៣១
២.១.២ អាជ្ញាយុកាលកំណត់ក្នុងការបន្ធូរបន្ថយទោស ...... ៣២
២.២ នីតិវិធីក្នុងការបន្ធូរបន្ថយទោស និងលើកលែងទោស ...... ៣៣
**៣. ការលើកលែងទោសជាទូទៅ** ...... ៣៤
សេចក្ដីសន្និដ្ឋាន ...... ៣៦
អនុសាសន៍ ...... ៣៧
ឯកសារយោង
ឧបសម្ព័ន

# សេចក្តីផ្តើម

## ១.លំនាំនៃការស្រាវជ្រាវ

នៅក្នុងសង្គមនីមួយៗតែងតែមានច្បាប់ដើម្បីគ្រប់គ្រង បង្ការ និងការពារឱ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយល្អ ទន្ទឹមនឹងនេះរដ្ឋក៏បានប្រើប្រាស់នូវវិធានការផ្សេងៗ ដែលមានលក្ខណៈជាការកែលំអរ និងជាលក្ខណៈបង្ខិតបង្ខំផងដែរ ។ មានបទដ្ឋានគតិយុត្តជាច្រើនបានដាក់ ចេញឱ្យប្រើប្រាស់ដែលមានគោលបំណងចាត់តាំងគ្រប់គ្រងសង្គម លក្ខណៈចាប់បង្ខំដើម្បីអនុវត្ត ដោយផ្ទុកនូវមាត្រាដែលមាន និងតទុលជាមួយអំពើរំលោភបំពានប្រកបដោយលក្ខណៈធ្ងន់ធ្ងរដែលបង្ក ឱ្យមានការអន្តរាយធំធេង ។ បញ្ហាទាំងនេះរដ្ឋត្រូវប្រើប្រាស់នូវវិធានការខ្លាំងខ្លាមានលក្ខណៈបង្ខំតាម ច្បាប់ព្រហ្មទណ្ឌ ។ ដោយលិខិតបទដ្ឋានព្រហ្មទណ្ឌបានកំណត់ថាអំពើរំលោភបំពារបំពាននោះជា បទល្មើស និងកំណត់អំពីទណ្ឌកម្មដើម្បីប្រើប្រាស់ទៅលើបណ្តាជនល្មើស ។

ម្យ៉ាងទៀត រាល់អំពើរំលោភបំពានទាំងអស់សុទ្ធតែផ្ទុកនូវលក្ខណៈបង្កគ្រោះថ្នាក់ដល់សង្គមជាតិ ប៉ុន្តែកម្រិតនៃការអន្តរាយមានទំហំខុសៗគ្នា ដូចនេះទាមទារឱ្យរដ្ឋមានវិធានការដោះស្រាយសមស្រប ចំពោះបណ្តាអំពើទាំងនោះ ។ ជាមួយនឹងអំពើរំលោភច្បាប់ដែលបង្កឱ្យមានការអន្តរាយតិចតួច រដ្ឋប្រើ ប្រាស់នូវវិធានការធន់ល្មមដើម្បីស្តាឡើងវិញនូវទំនាក់ទំនងសង្គម ប៉ុន្តែចំពោះអំពើរំលោភបំពានដែល មានចរិកគ្រោះថ្នាក់ខ្លាំងក្លា បង្កអន្តរាយធ្ងន់ធ្ងរនោះ រដ្ឋត្រូវអនុវត្តនូវវិធានការតឹងតែងដើម្បីផ្តន្ទាទោស ចំពោះជនដែលប្រព្រឹត្តអំពើនោះ ។ តាមរយៈច្បាប់ព្រហ្មទណ្ឌ យើងសង្កេតឃើញមានគោលការណ៍ ជាច្រើនដែលជាគោលបំណងក្នុងការអនុវត្ត ក្នុងនោះច្បាប់បញ្ញត្តិអំពីបទល្មើសផ្សេងៗអំពីបុគ្គល ដែលអាចទទួលខុសត្រូវព្រហ្មទណ្ឌ អំពីទោស ព្រមទាំងបែបបទនៃការអនុវត្តទោស ។

ជាគោលការណ៍ នៅពេលមានបទល្មើសមួយកើតមានឡើងមុននឹងឈានដល់ការជំនុំជម្រះ គឺទាមទារឲ្យបំពេញនីតិវិធីជាច្រើនតាមដំណាក់កាលជាមុនសិនដូចជា កិច្ចស៊ើបអង្កេត កិច្ចចោទប្រកាន់ និងកិច្ចស៊ើបសួរជា ដើម ដើម្បីស្វែងរកភស្តុតាង និងការពិតនៃរឿងក្តីទាំងនោះមុននឹងចេញសេចក្តីសម្រេច។ នៅពេលតុលាការប្រកាស សេចក្តីសម្រេច ទោសអាចត្រូវបានអនុវត្ត ឬមិនត្រូវបានអនុវត្ត អាស្រ័យលើសេចក្តីប្រកាសរបស់តុលាការលើ ស្ថានភាពនៃបទល្មើសនោះ។ ទោសព្រហ្មទណ្ឌដែលអាចយកមកអនុវត្តមាន៣ គឺ មូលទោស ទោសបន្ថែម និង ទោសជំនួស ដែលការអនុវត្តទោសទាំង៣ នេះមានលក្ខខណ្ឌខុសគ្នាៗពីគ្នា ។

## ២.ចំណោទបញ្ហា

ទោសព្រហ្មទណ្ឌមានសារៈសំខាន់ចំពោះចារីទាំងឡាយណាដែលមានពិរុទ្ធភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ ដែលត្រូវបានចោទប្រកាន់ហើយឈានដល់ការសម្រេចសេចក្តីដោយតុលាការព្រហ្មទណ្ឌ

នូវទណ្ឌកម្ម ចំពោះពិរុទ្ធជននោះ ។ ម្យ៉ាងវិញទៀត ទណ្ឌកម្មព្រហ្មទណ្ឌអាចនាំឲ្យមាននូវទោសទណ្ឌចំពោះជនដែលបានប្រព្រឹត្តល្មើសនឹងប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ព្រហ្មទណ្ឌ ហើយក្នុងការប្រកាសសេចក្ដីសម្រេចគឺមានតែតុលាការប៉ុណ្ណោះ ដែលមានសមត្ថកិច្ចក្នុងការសម្រេចផ្ដន្ទាទោសដល់ជនដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

ហេតុនេះហើយ ទើបយើងខ្ញុំលើកយកប្រធានបទអំពី ទោស និងការអនុវត្តទោសក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា មកសរសេរនៅ ក្នុងសារណានេះ គឺដើម្បីចង់បង្ហាញដល់អ្នកអាន ដូចជានិស្សិតជំនាន់ក្រោយៗទៀតឲ្យយល់ដឹងបន្ថែមអំពី ទោស និងការអនុវត្តទោសក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា ? ថាតើទោសក្នុងច្បាប់ព្រហ្មទណ្ឌមានប៉ុន្មានប្រភេទ ហើយគេយកទោសមកអនុវត្តយ៉ាងដូចម្ដេច? មានផលប៉ះពាល់អ្វីខ្លះដល់ការអនុវត្តទោស?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវសារណានេះឡើង គឺក្នុងគោលបំណងដើម្បីធ្វើការពង្រឹង និងពង្រីកនូវសមត្ថភាពបន្ថែមពីសារៈសំខាន់នៃទោសព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលទាក់ទងជាមួយនឹងនីតិវិធីរបស់តុលាការក្នុងការអនុវត្តទោសណាមួយ ដែលជាចំណេះដឹង និងបទពិសោធន៍ដ៏ល្អមួយដល់យើងខ្ញុំទាំងពីរ និងជាទុនមួយសម្រាប់ទុកជាឯកសារដល់និស្សិតជំនាន់ក្រោយៗថែមទៀតផង ។

## ៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងប្រធានបទដែលបានលើកឡើងនៅក្នុងចំណោទបញ្ហាខាងលើ យើងខ្ញុំទាំងពីរបាន ខិតខំធ្វើការសិក្សាស្រាវជ្រាវដោយផ្អែកទៅលើឯកសារតាមច្បាប់ និងបទប្បញ្ញត្តិដែលចូលជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជាមានដូចជាក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងកម្រងឯកសារ ស្នាដៃ សៀវភៅ បទឧបទ្ទេសរបស់សាស្ត្រាចារ្យ និងអ្នកជំនាញវិស័យច្បាប់នានា ទើបសរសេរនូវសារណានេះឡើងបានចំនួន ០៣ ជំពូក ។ នៅក្នុងសារណានេះនឹង បង្ហាញអំពីទោសក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា, ការអនុវត្តទោសក្នុងច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីនៃការអនុវត្តទោស ក៏ដូចជាមូលហេតុទូទៅដែលនាំឱ្យមានផលប៉ះពាល់ដល់ការអនុវត្តទោសផងដែរ ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវក្នុងការសរសេរសារណានេះឡើង យើងខ្ញុំបានដកស្រង់ នឹងប្រមូលឯកសារមួយចំនួនចេញពីក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ពន្ធនាគារ ព្រះរាជក្រឹត្យស្ដីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស ព្រមទាំងសៀវភៅមេរៀនដែលសាស្ត្រាចារ្យផ្នែកច្បាប់បានចងក្រង និងតាមប្រព័ន្ធអ៊ីនធឺណេតនូវព័ត៌មានមួយចំនួន រួមទាំងការសាកសួរពិគ្រោះយោបល់ជាមួយសាស្ត្រាចារ្យណែនាំជាច្រើននៅក្នុងអំឡុងពេលនៃការស្រាវជ្រាវ ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

សារណានេះអាចនាំឱ្យ អ្នកអានទុកជាជំនួយស្មារតីដល់ការសិក្សាស្រាវជ្រាវរបស់ខ្លួន បានយល់ដឹងដល់ ការពង្រឹង និងពង្រីកលើវិស័យច្បាប់ព្រហ្មទណ្ឌ គឺបញ្ញត្តិច្បាប់ដែលពាក់ព័ន្ធនឹងទោសព្រហ្មទណ្ឌ ដើម្បីកំណត់ ទោសឱ្យបានត្រឹមត្រូវ មានន័យថាទោសដែលសមស្របបំផុតទៅនឹងចំណុចតុល្យភាពរវាងការបង្ក្រាប និងការ បង្ការនោះ គេត្រូវគិតមិនត្រឹមតែពីកាលៈទេសៈដែលបទល្មើសនោះត្រូវបានប្រព្រឹត្តប៉ុណ្ណោះទេ តែថែមទាំង បុគ្គលិកលក្ខណៈរបស់ចារីថែមទៀត ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងគម្រោងប្លង់នៃសារណាបញ្ចប់ការសិក្សា លើប្រធានបទស្ដីពី នីតិវិធីនៃការអនុវត្តមូលទោស នេះ យើងខ្ញុំបានបែងចែកចេញជា ០៣ ជំពូក ដូចខាងក្រោម៖

ជំពូកទី១ ទោសក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា

ជំពូកទី២ ការអនុវត្តទោសក្នុងច្បាប់ព្រហ្មទណ្ឌ

ជំពូកទី៣ នីតិវិធីនៃការអនុវត្តទោស និងមូលហេតុទូទៅដែលនាំឲ្យមានផលប៉ះពាល់ដល់ការអនុវត្តទោស

# ជំពូកទី១
# ទោសក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា

## ផ្នែកទី១ សញ្ញាណទូទៅនៃទោសព្រហ្មទណ្ឌកម្ពុជា

នៅក្នុងការរស់នៅរបស់មនុស្សក្នុងសង្គម យើងឃើញថា មនុស្សរមែងតែងតែប្រើសិទ្ធិរបស់ខ្លួនបំពានទៅលើសិទ្ធិរបស់អ្នកដទៃ ក៏ដូចជាបំពារបំពានលើសណ្តាប់ធ្នាប់សាធារណៈ ឬ ផលប្រយោជន៍សង្គមណាមួយកើតឡើងនោះ រដ្ឋត្រូវតែមានវិធានការដើម្បីទប់ស្កាត់ ។ ហេតុនេះហើយ បានជាលេចវត្តមានឡើងនូវក្រមព្រហ្មទណ្ឌ ដើម្បីជាវិធានការទប់ស្កាត់ទៅលើបុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើស ហើយធ្វើការដាក់ទណ្ឌកម្មទៅលើបុគ្គលទាំងអស់នោះ ។

### ១ អត្ថន័យនៃទោសព្រហ្មទណ្ឌ

ទោសព្រហ្មទណ្ឌ គឺជាទណ្ឌកម្មរបស់សង្គម ឬ ក៏ជាការឆ្លើយតបរបស់សង្គមទៅនឹងបុគ្គលដែលបានប្រព្រឹត្តបទល្មើស បានន័យថាប្រឆាំងជាមួយនឹងចារីនៃបទល្មើស ។ ចំណែកបទល្មើស គឺជាអំពើប្រឆាំងនឹងច្បាប់ព្រហ្មទណ្ឌជាធរមាន និងត្រូវផ្តន្ទាទោសក្នុងបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ[1] ។ ជាធម្មតា យើងដឹងហើយថាគ្រប់សង្គមទាំងអស់តែងតែមានធ្វើការកំណត់នូវច្បាប់ដើម្បីធ្វើការគ្រប់គ្រងសង្គម ដើម្បីធានានូវសន្តិសុខសណ្តាប់ធ្នាប់សាធារណៈរបស់សង្គម ។ ដូច្នេះ ច្បាប់បានកម្រិតនូវសកម្មភាពមួយចំនួនដែលហាមឃាត់ ហើយការប្រព្រឹត្តនោះផ្ទុយទៅនឹងអំពើហាមឃាត់របស់សង្គមពេល ។ ប៉ុន្តែ ប្រសិនបើជនណានៅតែរឹងទទឹង ហើយបានប្រព្រឹត្តបទល្មើសណាមួយនោះ សង្គមនឹងមានវិធានការយ៉ាងតឹងរឹងត្រឡប់ទៅវិញ ដោយត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌ ឬ យើងហៅថាទោសព្រហ្មទណ្ឌនេះឯង ។

### ២ ចរិកលក្ខណៈនៃទោសព្រហ្មទណ្ឌ

ស្តែងចេញអំពីលក្ខណៈដ៏សំខាន់ និងមានភាពច្បាស់លាស់នៃទោសព្រហ្មទណ្ឌ ទើបធ្វើឲ្យទោសព្រហ្មទណ្ឌមានលក្ខណៈខុសពីទោសផ្សេងៗទៀត ។ ទោសព្រហ្មទណ្ឌ មានចរិកលក្ខណៈចំនួន ២ (ពីរ) គឺ

#### ២.១ គោលការណ៍នីត្យានុកូលភាពនៃទោស

ជាគោលការណ៍ ច្បាប់ព្រហ្មទណ្ឌមានគោលដៅកំណត់បទល្មើស ចង្អុលបង្ហាញអំពីបុគ្គលដែលត្រូវទទួលរងទោស ឬ អាចត្រូវប្រកាសថាទទួលខុសត្រូវព្រហ្មទណ្ឌ ហើយមានគោលដៅកំណត់អំពីទោសព្រមទាំងបែបបទនៃការអនុវត្តទោសនោះ[2] ។ ទោសព្រហ្មទណ្ឌ ដាច់ខាតត្រូវតែកំណត់ដោយច្បាប់ព្រហ្មទណ្ឌទុកជាមុន ដើម្បីឆ្លើយតបទៅនឹងគោលការណ៍នីត្យានុកូលភាពនៃទោសព្រហ្មទណ្ឌ ដែលយើងឃើញ

---

[1] មាត្រា ២ វាក្យខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

[2] មាត្រា ១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

កំណត់នៅក្នុងមាត្រា ៣ កថាខណ្ឌទី ២ នៃក្រមនេះ។

**២.២ គោលការណ៍នៃការប្រកាសទោសដោយតុលាការ**

ជាគោលការណ៍ គ្មានទោសណាមួយដែលអាចយកមកអនុវត្តបានឡើយ ប្រសិនបើទោសនោះមិនត្រូវបានប្រកាសដោយតុលាការព្រហ្មទណ្ឌ[3] ។ ទោសព្រហ្មទណ្ឌ ត្រូវតែប្រកាសដោយតុលាការព្រហ្មទណ្ឌគឺមានសារៈសំខាន់ខ្លាំងណាស់ ព្រោះគ្មានអ្នកណាក្រៅពីចៅក្រមទេ ដែលអាចប្រកាសផ្ដន្ទាទោសជនណាម្នាក់បាន ដោយសារតែ ចៅក្រមគឺជាមនុស្សដែលធ្វើការនៅក្នុងអំណាចតុលាការ ហើយអំណាចតុលាការនេះត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល ឬ ជាច្បាប់គ្រឹះរបស់ប្រទេស ។

**៣ មុខងារនៃទោសព្រហ្មទណ្ឌ**

ទោសព្រហ្មទណ្ឌមានមុខងារសំខាន់ៗ ចម្បងចំនួន ៣ (បី) គឺ ៖

**៣.១ មុខងារបង្ក្រាប និងដាក់ទណ្ឌកម្ម**

កាលពីបុរាណកាលនោះ ទោសព្រហ្មទណ្ឌមានមុខងារចម្បងគឺធ្វើការបង្ក្រាប និងធ្វើការដាក់ទណ្ឌកម្មនេះ គឺជាមុខងារចម្បង ហើយជាមុខងារទី ១ នៃទោសព្រហ្មទណ្ឌ ។ ការដាក់ទណ្ឌកម្ម នេះមានគោលដៅធ្វើយ៉ាងម៉េចឲ្យចារីដែលប្រព្រឹត្តបទល្មើសនោះទទួលរងនូវផលពិបាក ទទួលរងនូវការឈឺចាប់ឲ្យកាន់តែខ្លាំងក្លាដែលនេះជាការឆ្លើយតបទៅនឹងសកម្មភាពរើករារដល់សង្គម ដែលបង្កដោយបទល្មើសរបស់ខ្លួន ។

**៣.២ មុខងារបន្លាច និងបង្ការ**

មុខងារទី ២ នៃទោសព្រហ្មទណ្ឌ គឺមានគោលដៅធ្វើឲ្យមានការខ្លាចរអារទៅលើជនដែលប្រព្រឹត្តបទល្មើស  និងបង្ការដល់សាធារណៈជន  ។

**ក. បន្លាចដល់ប្រធាននៃបទល្មើស**

បន្លាចដល់ប្រធាននៃបទល្មើស គឺសំដៅដល់ជនណាដែលជាបានប្រព្រឹត្តបទល្មើស ឬ អ្នកចូលរួមប្រព្រឹត្តបទល្មើសទទួលរងសមល្មមទៅនឹងអំពើដែលខ្លួនបានប្រព្រឹត្ត ហើយខ្លាចរអាដល់ពេលថ្ងៃក្រោយក៏លាលែងនិងអាចជៀសវាងមិនប្រព្រឹត្តបទល្មើសសារជាថ្មីម្ដងទៀតឡើយ ។ មានន័យថា មុខងារបន្លាចគឺធ្វើឲ្យប្រធាននៃបទល្មើសខ្លាចរអារលែងហ៊ានប្រព្រឹត្តបទល្មើសជាថ្មីម្ដងទៀត ដែលសំដៅដល់ចារី សហចារី អ្នកផ្ដើមគំនិត និងអ្នកសមគំនិត ។

**ខ. បង្ការដល់សាធារណៈជន**

មុខងារបង្ការមានអានុភាពក្នុងការប្រើប្រាស់ដើម្បីបង្ការទៅដល់សារធារណៈជន សមាជិកសង្គមទាំងមូលជាពិសេសអ្នកដែលមានគំនិតក្នុងការប្រព្រឹត្តបទល្មើស បោះបង់ចោលនូវការប្រព្រឹត្តបទល្មើស

[3] មាត្រា ៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

របស់ខ្លួន ដោយហេតុយល់ឃើញថា ទោសព្រហ្មទណ្ឌមានលក្ខណៈធ្ងន់ធ្ងរហើយ បើគាត់ហ៊ានប្រព្រឹត្តបទល្មើស នោះគាត់នឹងមានវាសនាដូចចារី ឬ សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ដែលនឹងត្រូវទទួលរងទណ្ឌកម្មព្រហ្មទណ្ឌ ។

**៣.៣ មុខងារអប់រំកែប្រែនិងធានាសម្រួលទណ្ឌិតឲ្យធ្វើសមាហរណកម្មចូលទៅរួមរស់នៅក្នុងសង្គមវិញ**

ចំណុចទី៣ ជាមុខងារសំដៅធ្វើយ៉ាងណាសម្រួល អប់រំ កែប្រែទណ្ឌិត និងធានាឲ្យទណ្ឌិតអាចធ្វើសមាហរណកម្មចូលទៅរស់នៅក្នុងសង្គមវិញបាន ។ ដូច្នេះហើយ ទើបគេពិនិត្យទៅដល់ការធ្វើយ៉ាងណាឲ្យទណ្ឌិតដែល ទទួលទោសរួច អាចកែប្រែខ្លួន អាចធ្វើសមាហរណកម្មខ្លួនឯងទៅក្នុងសង្គមវិញ ដើម្បីជាផលប្រយោជន៍ដល់សង្គម ។ ទើបក្រមព្រហ្មទណ្ឌរបស់កម្ពុជាយើងបានប្រកាន់យកនូវនិន្នាការនេះ ដោយផ្តោតជាពិសេសទៅលើមងារទី ៣ នៃទោសព្រហ្មទណ្ឌគឺការអប់រំ កែប្រែ សម្រួលទណ្ឌិត ដើម្បីអាចធ្វើសមាហរណកម្មទណ្ឌិតចូលទៅរស់នៅក្នុងសង្គមវិញដោយបានកំណត់នូវគោលការណ៍ជាច្រើនដូចជា គោលការណ៍ឯកត្តកម្មនៃទោស ក៏ដូចជាគោលការណ៍និងយន្តការដ៏ទៃទៀតដើម្បីជ្រើសរើសទោសឲ្យសមស្របទៅនឹងបុគ្គលភាពនៃជនល្មើសហើយអាចកែសម្រួលនិងធ្វើសមាហរណកម្មទណ្ឌិតទៅក្នុងសង្គមវិញ ។

## ផ្នែកទី២ ប្រភេទនៃទោសព្រហ្មទណ្ឌ

### ១. មូលទោស

**១.១ អត្ថន័យនៃមូលទោស**

មូលទោស គឺជាទោសមូលដ្ឋានដែលតុលាការយកទៅប្រើប្រាស់សម្រាប់ការប្រកាសទោសចំពោះជនជាប់ចោទដែលបានប្រព្រឹត្តបទល្មើស មានន័យថា ការបើមានជនណាម្នាក់បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយនោះ តុលាការនឹងធ្វើការប្រកាសមូលទោសនេះទៅលើជនជាប់ចោទ ។

**១.២ ប្រភេទនៃមូលទោស**

នៅក្នុងច្បាប់ព្រហ្មទណ្ឌ មូលទោសមានពីរ គឺទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់[4] ។

**១.២.១ ទោសដាក់ពន្ធនាគារ**

ទោសពន្ធនាគារជាទោស ដែលច្បាប់កំណត់ពីការដកហូតសិទ្ធសេរីភាពចំពោះបុគ្គល ដោយត្រូវយកជននោះដាក់ក្នុងពន្ធនាគារ ហើយទោសនេះផងដែរក៏ចាំបាច់ត្រូវកំណត់អំពីរយៈពេលមួយច្បាស់លាស់ ។ ម្យ៉ាងទៀត ជាគោលការណ៍បទល្មើសទាំងឡាយ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ច្បាប់តែងតែកំណត់ពី

[4] មាត្រា ៤៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

អប្បបរមា និងអតិបរមានៃការដាក់ពន្ធនាគារ[5] ។ ការកំណត់អំពីអប្បបរមា និង អតិប្បរមានៃការដាក់ពន្ធនាគារ មានន័យថា ច្បាប់បានទុកលទ្ធភាពឱ្យចៅក្រមដែលមានឆន្ទានុសិទ្ធិ ក្នុងការសម្រេចអំពីទណ្ឌកម្ម ធ្វើការថ្លឹងថ្លែង ចំពោះអំពើ ដែលជននោះបានប្រព្រឹត្តដើម្បីដាក់ទណ្ឌកម្មទៅតាមកំរិតដែលច្បាប់បានកំណត់ ដោយចៅក្រម ពុំអាចសម្រេចដាក់ទោសច្រើនជាងអតិបរមា ឬ បន្ថយឱ្យទាបជាងអប្បបរមានៃទោសដែលច្បាប់បានកម្រិតទុក ឡើយ លើកលែងតែក្នុងករណីស្ថាន សម្រាល និងស្ថានទម្ងន់ទោស ដែលតុលាការអាចសម្រេចផ្តន្ទាទោសទាប ជាងអប្បបរមា ឬ ខ្ពស់ជាងអតិបរមា ។

**២.ទោសបន្ថែម**

**២.១ អត្ថន័យនៃទោសបន្ថែម**

ទោសបន្ថែមនេះជាទោសមួយប្រភេទដែលតុលាការធ្វើការប្រកាស ដើម្បីបន្ថែមទៅលើមូល ទោស បានន័យថាក្រៅអំពីការផ្តន្ទាទោសជាមូលទោសដែលមានដូចជាទោសដាក់ពន្ធនាគារឬពិន័យ ហើយ តុលាការអាចធ្វើការសម្រេចពិចារណាអំពីទោសបន្ថែមដែលអាចប្រកាសចំពោះទណ្ឌិតនោះថែមទៀតបាន ។ យើងអាចនិយាយម្យ៉ាងទៀតថា ទោសបន្ថែមនេះ ពេលដែលចៅក្រមគាត់ប្រកាសអំពីមូលទោសហើយក្នុងករណី ដែលលក្ខខណ្ឌច្បាប់ចែងកំណត់ថាអនុញ្ញាឲ្យមានផ្តន្ទាទោសបន្ថែមទៀត នោះចៅក្រមអាចសម្រេចប្រកាស ទោសបន្ថែម ដើម្បីបន្ថែមទៅលើមូលទោសបាន ។

**២.២ លក្ខខណ្ឌនៃទោសបន្ថែម**

យោងតាមមាត្រា៥៤ នៃក្រមព្រហ្មទណ្ឌបានចែងថា ទោសបន្ថែម នឹងអាចប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងដោយជាក់លាក់ចំពោះបទលហុ បទមជ្ឈិម ឬបទឧក្រិដ្ឋដែលត្រូវចោទប្រកាន់ ។ ទោសបន្ថែម អាចប្រកាសក៏បាន មិនប្រកាសក៏បាន ។ ទោសបន្ថែមត្រូវប្រកាសជាកាតព្វកិច្ច ប្រសិនបើច្បាប់ ចែងយ៉ាងជាក់លាក់ ។ នេះជាវិធានមួយដ៏មានសារៈសំខាន់ដែលមានន័យថា ជាគោលការណ៍ ចៅក្រមពុំមាន កាតព្វកិច្ចត្រូវតែប្រកាសទោសបន្ថែមឡើយ ក៏នៅក្នុងករណីមួយចំនួន ចៅក្រមនឹងមានកាតព្វកិច្ចប្រកាសទោស បន្ថែម លុះត្រាតែច្បាប់បានចែងជាក់លាក់តែប៉ុណ្ណោះ បានសេចក្តីថាមិនមែនចេះតែយកទៅអនុវត្តនោះទេ ទាល់តែបទល្មើសដែលជនល្មើសបានប្រព្រឹត្តនោះ ច្បាប់បានកំណត់ទុកជាមុន ទើបចៅក្រមអាចប្រកាសទោស បន្ថែមនេះបាន ។ ឧទាហរណ៍ នៅក្នុងករណីបទល្មើសជួញដូរគ្រឿងញៀនជាដើម ដែលក្នុងករណីនេះចៅក្រម ត្រូវតែរឹបអូសគ្រឿងញៀននោះ ដែលនេះជាទោសបន្ថែមដែលច្បាប់បានកំណត់ទុកជាមុន ។

**២.៣ ប្រភេទនៃទោសបន្ថែម**[6]

[5] មាត្រា ៤៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

[6] មាត្រា ៥៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

ប្រភេទនៃទោសបន្ថែម មានដូចជា ៖

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្ត នៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ ។

៣-ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ។

៤-ការព្យួរលិខិតបើកបរ ។

៥-ការហាមឃាត់ចំពោះការស្នាក់នៅ ។

៦-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

៧-ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិតដែលជាជនបរទេស ។

៨-ការរឹបអូសឧបករណ៍សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ។

៩-ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

១០-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស ។

១១-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុ ដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

១២-ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត ។

១៣-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ។

១៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

១៥-ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស ។

១៦-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន ។

១៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ។

១៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

បទប្បញ្ញត្តិដោយឡែក អាចបង្កើតទោសបន្ថែមផ្សេងៗទៀត ។

## ៣. ទោសជំនួស

### ៣.១ អត្ថន័យនៃទោសជំនួស

ទោសជំនួសនេះ ជាប្រភេទទោសមួយដែលថ្មី ទើបនឹងត្រូវបានបញ្ចូលមកក្នុងប្រព័ន្ធច្បាប់កម្ពុជា ។ ទោសជំនួស គឺជាទោសមួយប្រភេទដែលតុលាការអាចជ្រើសរើសយកទៅប្រើប្រាស់ដើម្បីជំនួសឲ្យមូលទោសបានន័យថា យកទៅប្រើប្រាស់ជំនួសឲ្យមូលទោស ហើយកាលណាតុលាការសម្រេចប្រកាសទោសជំនួសនេះ ទៅលើជនជាប់ចោទរួចហើយ តុលាការមិនអាចប្រកាសទោសក្នុងឋានៈជាមូលទោសទៀតបានឡើយ ។ តុលាការអាចប្រកាសទោសជំនួសទៅលើជនជាប់ចោទបាន ប្រសិនបើយល់ឃើញថា អំពើ ដែលជននោះបានប្រព្រឹត្តមានលក្ខណៈតូចតាច ព្យសនៈកម្មដែលកើតឡើងដោយសារអំពើនោះត្រូវ បានជនជាប់ចោទបានជួសជុលរួចហើយ ពោលគឺតុលាការអនុវត្តទោសនេះសម្រាប់តែបទល្មើសដែល កម្រិតអតិបរមានៃទោសដាក់ពន្ធនាគាររយៈពេលខ្លីៗប៉ុណ្ណោះ ។

### ៣.២ ប្រភេទនៃទោសជំនួស

នៅក្នុងច្បាប់ព្រហ្មទណ្ឌ ទោសជំនួសមានពីរ ប្រភេទគឺទោសការងារសហគមន៍ និងទោសការស្តីបន្ទោស ។

#### ៣.២.១ ទោសការងារសហគមន៍

តុលាការអាចប្រកាសទោសការងារសហគមន៍ទៅលើជនជាប់ចោទបាន ប្រសិនបើបទល្មើសដែលជននោះបានប្រព្រឹត្តមានកម្រិតអតិបរមានៃទោសពន្ធនាគារតិចជាង ឬស្មើ ៣ ឆ្នាំ ។

ការងារសហគមន៍ គឺជាកាតព្វកិច្ចត្រូវបំពេញក្នុងចិរវេលាចន្លោះពី ៣០ (សាមសិប) ម៉ោង និង ២០០ (ពីររយ) ម៉ោង នូវការងារគ្មានកំរៃជាអត្ថប្រយោជន៍របស់រដ្ឋ នីតិបុគ្គលនៃនីតិសាធារណៈផ្សេង ទៀត សមាគមន៍ ឬដល់អង្គការមិនមែនរដ្ឋាភិបាល[7] ។ ការងារសហគមន៍មិនអាចបំពេញជាប្រយោជន៍ នៃរូបវន្តបុគ្គលនោះទេ ។ ម្យ៉ាងទៀតទោសនេះត្រូវស្ថិតនៅក្រោមបទបញ្ញត្តិនៃក្រមការងារជាអាទិ៍ ការងារពេលយប់ អនាម័យ សន្តិសុខ ហើយនិងការងាររបស់ស្ត្រី ។ ការងារនេះអាចត្រួតគ្នាបានជា មួយនឹងការអនុវត្តសកម្មភាពវិជ្ជាជីវៈបានផងដែរ ។

#### ៣.២.២ ទោសការស្តីបន្ទោស

ការស្តីបន្ទោសជាទោសម្យ៉ាងដែលតុលាការអាចប្រកាសត្រឹមជាការស្តីបន្ទោស ដោយគ្មានទោសណាមួយត្រូវបានប្រកាសចំពោះជននោះទេដូចជាមូលទោសឬទោសបន្ថែម ។ តុលាការអាច ប្រកាសការ

[7] មាត្រា ៧២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

ស្តីបន្ទោសនៅក្នុងករណីដែលជនជាប់ចោទ រងទោសដាក់ពន្ធនាគារដែលមានអតិបរមា តិចជាង ឬស្មើ ៣ ឆ្នាំ[៥] ។ ក្នុងករណី បើជននោះបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

-ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈ ដែលបណ្តាលមកពីបទល្មើសបានបញ្ចប់ ។

-កាខូចខាតត្រូវបានជួសជុលរួចហើយ

-ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ ។

[៥] មាត្រា ៧៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

# ជំពូកទី២

# ការអនុវត្តទោសក្នុងច្បាប់ព្រហ្មទណ្ឌ

ចំពោះទោសដែលត្រូវយកមកអនុវត្តទៅលើរូបវន្តបុគ្គល ឬ នីតិបុគ្គល ទណ្ឌកម្មស្តែងឡើងក្រោមរូបភាពជាការដកហូតនូវសិទ្ធិសេរីភាពរបស់បុគ្គល ដូចជា ការយកបុគ្គលដែលបានប្រព្រឹត្តបទល្មើសឱ្យអនុវត្តទោសក្នុងពន្ធនាគារ ការរឹបអូសទ្រព្យសម្បត្តិដែលបានមកពីបទល្មើស ការហាមឃាត់នូវសកម្មភាពផ្សេងៗ ជាដើម ហើយទណ្ឌកម្មទាំងនេះ ត្រូវបានបញ្ញត្តិយ៉ាងច្បាស់លាស់ក្នុងច្បាប់ជាធរមាន ។ ដូច្នេះ នៅក្នុងផ្នែកនេះនឹងធ្វើការបកស្រាយអំពី ទោសដែលត្រូវអនុវត្តចំពោះរូបវន្តបុគ្គលជានីតិជន **ផ្នែកទី១** ទោសដែលត្រូវអនុវត្តចំពោះរូបវន្តបុគ្គលជាអនីតិជន **ផ្នែកទី ២** និងទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល **ផ្នែកទី ៣** ។

## ផ្នែកទី១ ទោសដែលត្រូវអនុវត្តចំពោះរូបវន្តបុគ្គលជានីតិជន

នីតិជន សំដៅដល់ជនដែលមានអាយុចាប់ពី១៨ ឆ្នាំឡើងទៅ ។ ជាគោលការណ៍ នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់ចាប់ពីអាយុ១៨ ឆ្នាំឡើងទៅ ។ មានន័យថា បុគ្គលដែលមានអាយុចាប់ពី ១៨ ឡើងទៅ នៅក្នុងករណីដែលជននេះ បានប្រព្រឹត្តបទល្មើសណាមួយនោះ គឺគាត់ត្រូវទទួលរងនូវទោសព្រហ្មទណ្ឌយ៉ាងពេញលេញ ។ ទន្ទឹមនឹងនេះ ទោសដែលត្រូវអនុវត្តចំពោះរូបវន្តបុគ្គលជានីតិជននេះមានបីគឺ មូលទោស ទោសបន្ថែម និងទោសជំនួស ។

### ១.មូលទោស

ជាគោលការណ៍ ប្រសិនបើ មានជនណាមួយបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ ជននោះនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ដោយត្រូវទទួលរងនូវទណ្ឌកម្មព្រហ្មទណ្ឌ តាមការកំណត់របស់ច្បាប់ជាធរមាន ។ ដោយឡែក មូលទោសដែលត្រូវយកមកអនុវត្តចំពោះរូបវន្តបុគ្គលជានីតិជនមានពីរ គឺទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ។

#### ១.១ ទោសដាក់ពន្ធនាគារ

ទោសដាក់ពន្ធនាគារ គឺជាទោសគុក ទោសដែលបំបាត់សេរីភាព ហើយមានកំណត់កាលដែលត្រូវបានផ្តន្ទាទោសដោយដាក់ពន្ធនាគារ មានន័យថាជនម្នាក់ក្រោយពេលតុលាការសម្រេចផ្តន្ទាទោសរួចហើយ ក៏យកជននោះទៅដាក់ពន្ធនាគារ ដើម្បីឱ្យអនុវត្តទោស ។

ឧទាហរណ៍. បទលួច ដែលមានចែងក្នុងមាត្រា៣៥៣ និងមាត្រា៣៥៦ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ ខែទៅ៣ ឆ្នាំ និងពិន័យជាប្រាក់ពី១លានរៀលទៅ៦លានរៀល ។ ដូច្នេះ ក្នុងករណីដែលបុគ្គលណាម្នាក់ដែលបានប្រព្រឹត្តបទលួចខាងលើ នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចន្លោះពី៦ខែ ទៅ៣ ឆ្នាំ ដោយយកទណ្ឌិតនោះទៅដាក់ក្នុងពន្ធនាគារហូតអនុវត្តទោសរបស់ខ្លួនចប់ ។

ជាងនេះទៅទៀត ក្រមព្រហ្មទណ្ឌក៏បានកំណត់អំពីរបៀបក្នុងការគណនាថិរវេលានៃទោសដាក់ពន្ធនាគារនេះផងដែរ ។ ការគណនាអំពីថិរវេលានៃទោសដាក់ពន្ធនាគាទោសដាក់ពន្ធនាគារ ១ (មួយ) ថ្ងៃ ត្រូវគិត ២៤ (ម្ភៃបួន) ម៉ោង ។ ទោសដាក់ពន្ធនាគារ ១ (មួយ) ខែ ត្រូវគិត ៣០ (សាមសិប) ថ្ងៃ ។ ទោសដាក់ពន្ធនាគារលើសពី ១ (មួយ) ខែ ត្រូវគិតតាមចំនួនថ្ងៃជាក់ស្តែង ដែលមាននៅក្នុងខែនោះ ។ ទោសដាក់ពន្ធនាគារ ១ (មួយ) ឆ្នាំ ត្រូវគិត ១២ (ដប់ពីរ) ខែ[9] ។ ឧទាហរណ៍ លោក ក ត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល១ ឆ្នាំ ចាប់ពីថ្ងៃទី១ ខែ០១ ឆ្នាំ២០២០ ដូច្នេះការគណនាទៅតាមចំនួនថ្ងៃនៃខែ គឺនាំឱ្យគេកំណត់ការដោះលែងលោក ក ឱ្យមានសេរីភាពវិញនៅថ្ងៃទី១ ខែ០១ ឆ្នាំ២០២១ ។ ក៏ប៉ុន្តែ ច្បាប់ក៏បានកំណត់នូវលក្ខខណ្ឌដោយឡែកនៃការបញ្ចប់ទោសផងដែរថា ជាគោលការណ៍ ទណ្ឌិតដែលទោសរបស់ខ្លួនត្រូវបញ្ចប់នៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកផ្សេងទៀតដែលច្បាប់ ឬបទដ្ឋានគតិយុត្តបានកំណត់ ត្រូវតែដោះលែងឱ្យ មានសេរីភាពវិញនៅមុនថ្ងៃឈប់សម្រាកនោះ[10] ។

**១.២ ទោសពិន័យ**

ចំណែកឯទោសពិន័យវិញ ជាទោសដែលភ្ជាប់ជាមួយទោសដាក់ពន្ធនាគារ ហើយជាទោសដែលតម្រូវឱ្យមានការបង់ប្រាក់តាមការកំណត់របស់ច្បាប់ ហើយរាល់ការពិន័យជាប្រាក់ គឺត្រូវគិតជាប្រាក់រៀលដែលជារូបិយវត្ថុជាតិ និងត្រូវបង់ចូលទៅក្នុងថវិការបស់រដ្ឋ[11] ។ ឧទាហរណ៍ តពីខាងលើ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ និងពិន័យជាប្រាក់ពី ១ លានរៀល ទៅ ៦ លានរៀល ។ ដូច្នេះ នៅក្នុងករណីនេះ ប្រសិនបើតុលាការកំណត់ប្រាក់ដែលត្រូវពិន័យចំនួនប៉ុន្មាន ប្រាក់ទាំងនេះនឹងត្រូវបង់ចូលទៅក្នុងថវិការដ្ឋ ។ម្យ៉ាងទៀត ច្បាប់ព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៩ ក៏បានកំណត់នូវបទល្មើសមួយចំនួនដែលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ប៉ុណ្ណោះ ដោយមិនមានការផ្តន្ទាទោសដាក់ពន្ធនាគារនោះទេ ។ ឧទាហរណ៍ មាត្រា ២២៨ នៃក្រមព្រហ្មទណ្ឌបានបញ្ញត្តិពីបទហិង្សាស្រាល ដែលបានចែងថា អំពើប្រព្រឹត្តទៅលើអ្នកដទៃនូវហិង្សាស្រាលដែលមិននាំឱ្យរងរបួសទេនោះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០០ (ប្រាំពាន់) រៀល ទៅ ១០០០០០ (មួយសែន) រៀល ។

**២. ទោសបន្ថែម**

ទោសបន្ថែមនេះ មានចំនួន១៩ ចំណុច មានដូចជា ៖

១. ការដកសិទ្ធិខ្លះជាពលរដ្ឋ[12]

- សិទ្ធិពលរដ្ឋដែលអាចដកបានរួមមាន៖

[9] មាត្រា ៤៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

[10] មាត្រា ៥០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

[11] មាត្រា ៥២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

[12] មាត្រា ៥៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

- សិទ្ធិបោះឆ្នោត
- សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត
- សិទ្ធិបំពេញការងារជាមន្ត្រីក្រមខ័ណ្ឌមុខងារសាធារណៈ
- សិទ្ធិទទួលការចាត់តាំងជាអ្នកជំនាញជាអាជ្ញាកណ្តាល ឬជាអាណត្តិគាហករបស់តុលាការ។
- សិទ្ធិទទួល និងពាក់គ្រឿងឥស្សរិយយសទាំងអស់ ។
- សិទ្ធិធ្វើជាសាក្សី ដែលទទួលសម្បថនៅមុខតុលាការ ។

ឧទាហរណ៍មាត្រា៥៨៧ នៃក្រមព្រហ្មទណ្ឌ ឃើញមានចែងពីពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតហេតុនេះបើសិនជាគាត់នៅតែបន្តបំពេញមុខងាររបស់គាត់ នៅពេលដែលមុខងារនោះត្រូវបានផុត អាណត្តិ ឬបានបញ្ចប់ទៅហើយ ។ ទង្វើបែបនេះ បើយោងតាមមាត្រា ៥៨៧ គឺគាត់បានប្រព្រឹត្ត បទល្មើសមួយឈ្មោះថា "បទបន្តអនុវត្តមុខងារដោយខុសច្បាប់"។ ដូច្នេះបន្ទាប់ពីតុលាការផ្តន្ទា ទោសគាត់ក្នុងឋានៈជាមូលទោសអាចជាទោសដាក់គុក ឬទោសពិន័យជាប្រាក់រួចហើយ ចៅក្រម អាចប្រកាសដកសិទ្ធិបោះឆ្នោតគាត់ទៀតបាននៅក្នុងឋានៈជាទោសបន្ថែមនេះដោយផ្អែកទៅលើ មាត្រា ៦០៤ ចំណុចទី ១ ចែងពីការដកសិទ្ធិខ្លះជាពលរដ្ឋ ។ ហេតុនេះនៅពេលដែលតុលាការ សម្រេចដកសិទ្ធិបោះឆ្នោតរួចហើយ នៅពេលដែលដល់ថ្ងៃបោះឆ្នោតណាមួយនោះ គាត់មិនអាច ទៅបោះឆ្នោតជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ទោះបីជាសិទ្ធិបោះឆ្នោតនេះ មានកំណត់យ៉ាងច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញក៏ដោយ។

ទោសនេះអាចជាស្ថាពរ ឬ ជាបណ្តោះអាសន្នសម្រាបរយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២.ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ

ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ មិនអនុវត្តទៅលើការបំពេញអាណត្តិដែលជ្រើសតាំងដោយការបោះឆ្នោតជាសាធារណៈឬការទទួលខុសត្រូវខាងសហជីពទេ ប៉ុន្តែការហាមឃាត់នេះ មិនអាចអនុវត្តំពោះបទល្មើសរំលោភលើច្បាប់ស្តីពីរបបសារព័ត៌មានទេ ហើយទោសនេះអាចជាស្ថាពរ ឬ ក៏ជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន[13] ។ តុលាការត្រូវបញ្ជាក់មុខរបរដែលត្រូវហាមឃាត់ ។ មានន័យថា ប្រសិនបើ ដោយសារតែមុខរបរណាមួយ ជនល្មើសអាចមាលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រព្រឹត្តបទល្មើសណាមួយនោះ តុលាកានឹងពិចារណាថាទោសបន្ថែមហាមឃាត់ចំពោះវិជ្ជាជីវៈមួយនោះ ។ ករណីដូចជាវិជ្ជាជីវៈគ្រូបង្រៀន វិជ្ជាជីវៈវិស្វករ វិជ្ជាជីវៈគ្រូពេទ្យ ជាដើម ។ល។

ឧទាហរណ៍ គ្រូបង្រៀនម្នាក់មានពិរុទ្ធភាពពីបទឈ្លានពានខាងផ្លូវភេទទៅលើសិស្សរបស់ខ្លួន

[13] មាត្រា ៥៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

ម្នាក់ ដូច្នេះតុលាការនឹងសម្រេចលែងឱ្យជនល្មើសអនុវត្តវិជ្ជាជីវៈគ្រូបង្រៀនទៀតហើយ ។ ហេតុដូច្នេះហើយ តុលាការ គាត់នឹងពិចារណាថាទោសបន្ថែមសម្រេចហាមឃាត់ចំពោះវិជ្ជាជីវៈបែបនេះ គឺសមរម្យហើយ។ ប៉ុន្តែ ប្រសិនបើ នៅពេលដែលតុលាការផ្តន្ទាទោសបន្ថែមទៀតរួចហើយ ប្រសិនបើជននោះបំពានលើសេចក្តីសម្រេច របស់តុលាការ ។ ដូច្នេះយោងតាមមាត្រា៥៧៩ នៃក្រមព្រហ្មទណ្ឌ **បទបំពានលើទោសហាមឃាត់ផ្នែកវិជ្ជាជីវៈ** បានចែងថា នៅក្នុងករណីដែលទោសហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ ត្រូវបានប្រកាសដោយអាជ្ញាធរ តុលាការ អំពើបំពានលើការហាមឃាត់នេះត្រូវ ផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និង ពិន័យជាប្រាក់ ពី ២.០០០.០០០ (ពីរលាន) រៀលទៅ ៤.០០០.០០០ (បួនលាន) រៀល។

៣. ការហាមឃាត់ចំពោះការបើកយានយន្តគ្រប់ប្រភេទ ។ ការហាមឃាត់ចំពោះការបើកបរ យានយន្ត មិនត្រូវលើសពី ៥ ឆ្នាំទេ[14] ។ ឧទាហរណ៍ ករណីគ្រោះថ្នាក់ចរាចរណ៍មួយ លោក ក បានបើករថយន្ត ដោយការធ្វេសប្រហែសខ្វះការប្រុងប្រយ័ត្ន ហើយក៏បានបើកបុកបុរសម្នាក់បណ្តាលឱ្យបាត់បង់ជីវិត ក្នុងករណី នេះ ជាបទល្មើសមនុស្សឃាតអចេតនា ដែលមានបញ្ញត្តិនៅក្នុងមាត្រា២០៧ នៃក្រមព្រហ្មទណ្ឌ ។ ដូច្នេះ បន្ទាប់ ពីតុលាការសម្រេចផ្តន្ទាទោសពីមូលទោសហើយ តុលាការអាចប្រកាសទោសបន្ថែមមួយ ឬច្រើន ដូចដែលមាន ចែងនៅក្នុងមាត្រា២០៨ នៃក្រមព្រហ្មទណ្ឌបាន ។

៤. ការព្យួរលិខិតបើកបរ ទោសព្យួរលិខិតបើកបរមិនត្រូវលើសពី ៥ ឆ្នាំទេ ។ ទណ្ឌិតត្រូវប្រគល់ លិខិតបើកបររបស់ខ្លួនទៅក្រឡាបញ្ជីតុលាការ[15] ។ ឧទាហរណ៍ ដូចករណីខាងលើនេះ តុលាការអាច ប្រកាសទោសបន្ថែមដូចជា ហាមឃាត់បើកបរយានយន្ត ទោះបីជាប្រភេទណាក៏ដោយសម្រាប់រយៈ ពេល ៥ ឆ្នាំយ៉ាងច្រើន និងការព្យួរលិខិតបើកបរ របស់លោក ក ។

៥. ការហាមឃាត់ចំពោះការស្នាក់នៅទីកន្លែងមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា[16]

ទោសហាមឃាត់ការស្នាក់នៅ គឺជាការហាមឃាត់ដល់ទណ្ឌិត ចំពោះការមានមុខនៅទីកន្លែង ខ្លះលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយទោសនេះ មិនអាចលើសពី ១០ (ដប់) ឆ្នាំ ចំពោះបទឧក្រិដ្ឋ និង ៥(ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម ហើយតុលាការកំណត់បញ្ជីនៃទីកន្លែងដែលហាមឃាត់ និង កំណត់ចិរវេលា នៃការហាមឃាត់ ហើយការហាមឃាត់ការស្នាក់នៅរួមមានវិធានការតាមដាន ។

ទណ្ឌិតត្រូវតែ ៖

១-ចូលបង្ហាញខ្លួនតាមដីកាកោះរបស់អាជ្ញាធរតុលាការឬរដ្ឋបាលដែលតុលាការបានចាត់តាំង។

[14] មាត្រា ៥៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

[15] មាត្រា ៥៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

[16] មាត្រា ៥៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

២-ចូលបង្ហាញខ្លួនឱ្យបានទៀងទាត់តាមការកំណត់នៅស្នាក់ការនគរបាលឬកងរាជអាវុធហត្ថតាមការ ចាត់តាំងរបស់តុលាការ ។

ម្យ៉ាងទៀត តុលាការត្រូវកំណត់បែបបទនៃវិធានការតាមដាន ហើយសេចក្តីសម្រេចរបស់តុលាការត្រូវជូនដំណឹងដោយព្រះរាជអាជ្ញាដល់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិក្នុងគោលបំណងសុំឲ្យមានកិច្ចសហប្រតិបត្តិការជាមួយតុលាការ ។

ឧទាហរណ៍ លោក ក បានប្រព្រឹត្តបទល្មើសឃាតកម្ម ដែលមានចែងនៅក្នុងមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ នៅអាកាសយានដ្ឋាន នៃព្រះរាជាណាចក្រកម្ពុជា ដោយផ្តើមឡើងពីទំនាស់ពាក្យសម្តីគ្នា ។ ដូច្នេះ តុលាការអាចប្រកាសទោសបន្ថែម ដោយហាមឃាត់មិនឱ្យលោក ក ចូលទៅក្នុងអាកាសយានដ្ឋានកម្ពុជាសម្រាប់រយៈពេល ១០ ឆ្នាំ ជាដើម ផ្អែកតាមមាត្រា ២០៦ ចំណុចទី៣ ។

៦. ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជាមិនត្រូវលើសពី ៥ (ប្រាំ) ឆ្នាំ ។

៧. ការហាមឃាត់ចំពោះការចូល និង ការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាដល់ទណ្ឌិតដែលជាជនបរទេស ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូលនិងការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណា ចក្រកម្ពុជាអាចជាស្ថាពរឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ហើយការហាមឃាត់នេះនាំឱ្យមានការបណ្តេញទណ្ឌិតឱ្យចេញដោយពេញច្បាប់នៅពេលបញ្ចប់ទោសដាក់ពន្ធនាគារ ។

ឧទាហរណ៍ ក្នុងករណីដូចជាមានជនបរទេសម្នាក់ចូលមកដល់រដ្ឋកម្ពុជាគាត់ក៏ប្រព្រឹត្តបទល្មើសមួយចំនួន អាចមាន គាត់ចាប់គេរំលោភ ឬគាត់ប្រព្រឹត្តអំពើឆបោក ។ ដូច្នេះ ក្នុងករណីដែលតុលាការឬចៅក្រមបានប្រកាសមូលទោសរួចហើយ តុលាការអាចជ្រើសយកទោសមួយទៀតគេឲ្យឈ្មោះថាទោសបន្ថែមដែលមានចែងក្នុងចំណុចទី ៧ នៃមាត្រា ៥៣ ដើម្បីបន្ថែមទៅលើមូលទោសទៀត ហេតុនេះ នៅពេលដែលចៅក្រមគាត់សម្រេចបន្ថែមទោសបន្ថែមនេះហើយ នៅពេលដែលជនបរទេសនោះបានអនុវត្តទោសនៅក្នុងពន្ធនាគាររួចហើយ ជនបរទេសនោះនឹងត្រូវបានគេបណ្តេញចេញដោយស្វ័យប្រវត្តិពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

៨. ការរឹបអូសឧបករណ៍សម្ភារៈឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស

៩. ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស

១០. ការរឹបអូសផលទុនឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស

១១. ការរឹបអូសឧបភោគភណ្ឌសម្ភារៈ ឬ ចលនវត្ថុ ដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

១២. ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត

១៣. ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវនេះ អាចជាស្ថាពរ ឬ ជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥( ប្រាំ) ឆ្នាំយ៉ាងច្រើន ។

១៤.ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ[17] ។ លទ្ធកម្មសាធារណៈ គឺជាការផ្គត់ផ្គង់ទំនិញផ្សេងៗ តាមការដេញថ្លៃជាសាធារណៈដោយប្រើ ថវិការដ្ឋ ។ ការបណ្តេញចេញពីលទ្ធកម្មសាធារណៈនាំឱ្យមានការហាមឃាត់ចំពោះការចូលរួមដោយផ្ទាល់ ឬ ដោយប្រយោលក្នុងលទ្ធកម្មសាធារណៈទាំងឡាយដែលរៀបចំដោយ៖

១-រដ្ឋ។

២-រដ្ឋបាលថ្នាក់ក្រោមជាតិ។

៣-គ្រឹះស្ថានសាធារណៈ។

៤-សហគ្រាសដែលទទួលសម្បទានពីរដ្ឋ ឬ ពីរដ្ឋបាលថ្នាក់ក្រោមជាតិឬដែលត្រួតពិនិត្យដោយរដ្ឋឬដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ទោសបណ្តេញចេញនេះអាចជាស្ថាព រឬ ជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ ឆ្នាំ យ៉ាងច្រើនបាន ។

១៥. ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬ ប្រព្រឹត្តបទល្មើស ។ គ្រឹះស្ថាន គឺជាកន្លែងធ្វើពាណិជ្ជកម្ម អាជីវកម្ម ឬសហគ្រាស ។ ម្យ៉ាងទៀត ទោសបិទគ្រឹះស្ថាននាំឱ្យមានការហាមឃាត់ចំពោះការធ្វើសកម្មភាពនៅក្នុងគ្រឹះស្ថានដែលនៅក្នុងឱកាសធ្វើសកម្មភាពនោះបទល្មើសត្រូវបានប្រព្រឹត្តឡើង ហើយទោសបិទគ្រឹះស្ថាននេះអាចជាស្ថាពរឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ ឆ្នាំយ៉ាងច្រើន[18]។

១៦.ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថានដែលបើកចំហ សម្រាប់សាធារជន ឬ ដែលប្រើប្រាស់ដោយសាធារណជន ។ ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហសម្រាប់សាធារណជន ឬ ដែល ត្រូវប្រើប្រាស់ដោយសាធារណជនអាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល៥(ប្រាំ) ឆ្នាំយ៉ាងច្រើន[19] ។

---

[17] មាត្រា ៦៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

[18] មាត្រា ៦៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

[19] មាត្រា ៦៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

១៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ។ ទោសបិទផ្សាយសេចក្តីសម្រេចត្រូវអនុវត្តនៅទីកន្លែងដែលចង្អុលបង្ហាញដោយតុលាការ និងក្នុងរយៈពេលមួយដែលកំណត់ដោយតុលាការ ហើយការបិទផ្សាយមិនអាចលើសពី២ (ពីរ) ខែនោះទេ ។ ម្យ៉ាងទៀត ការបិទផ្សាយអាចធ្វើទាំងស្រុង ឬ តាមសម្រង់ ឬ តាមនិទ្ទេសធម្មតាបាន ។ ចំពោះសោហ៊ុយបិទផ្សាយ គឺជាបន្ទុករបស់ទណ្ឌិត ។

១៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ។ ទោសផ្សាយសេចក្តីសម្រេចរបស់តុលាការត្រូវចុះផ្សាយក្នុងសារព័ត៌មានសរសេរតាមបែបបទ និងក្នុងចិរវេលាដែលកំណត់ដោយតុលាការ ។ សោហ៊ុយក្នុងការចុះផ្សាយជាបន្ទុករបស់ទណ្ឌិត ហើយក្នុងករណី មិនគោរពតាមទណ្ឌិតអាចត្រូវបានបង្ខំដល់រូបកាយ ហើយប្រសិនបើតុលាការបានបង្គាប់ឱ្យផ្សព្វផ្សាយសេចក្តីសម្រេចសារព័ត៌មានមិនអាចបដិសេធការផ្សាយនេះបានទេ ។

១៩.ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។ ទោសផ្សាយជាសាធារណៈនូវសេចក្តីសម្រេចតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ត្រូវអនុវត្តតាមបែបបទដែលកំណត់ដោយតុលាការ ។ ការផ្សាយនេះមិនអាចលើសពី៨ (ប្រាំបី) ថ្ងៃទេ ហើយការផ្សាយអាចផ្សាយទាំងស្រុង តាមសម្រង់ ឬ តាមនិទ្ទេស ។ ចំពោះសោហ៊ុយនៃការផ្សាយ គឺជាបន្ទុករបស់ទណ្ឌិត ។

**៣.ទោសជំនួស**

ទោសជំនួស ជាទោសមួយប្រភេទដែលជំនួសឱ្យមូលទោស ដែលជាទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ។ ដូច្នេះ នៅក្នុងករណីដែលតុលាការសម្រេចប្រកាសទោសជំនួសយកមកអនុវត្តចំពោះជនជាប់ចោទ តុលាការមិនអាចប្រកាសមូលទោសបាននោះឡើយ ។ ម្យ៉ាងទៀត ទោសជំនួសដែលត្រូវយកមកអនុវត្តចំពោះនីតិជនមានពីរគឺ ទោសការងារសហគមន៍ និងការស្តីបន្ទោស ។

**៣.១ ទោសការងារសហគមន៍**

តុលាការអាចប្រកាសទោសការងារសហគមន៍បាន បើកាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសទោសការងារសហគមន៍បាន ។ [20]

ការងារសហគមន៍ គឺជាកាតព្វកិច្ចត្រូវបំពេញក្នុងចិរវេលាចន្លោះពី ៣០ (សាមសិប)ម៉ោង ទៅ ២០០ (ពីររយ) ម៉ោងដោយគ្មានកម្រៃ ជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងៗទៀត ដល់សមាគម ឬដល់អង្គការ មិនមែនរដ្ឋាភិបាល។ ហើយនៅក្នុងគ្រប់ករណីទាំងអស់ ការងារសហគមន៍មិនអាចបំពេញជាប្រយោជន៍នៃរូបវន្តបុគ្គលទេ ។ ដូចមានចែងក្នុងមាត្រា៧៣ នៃក្រមព្រហ្មទណ្ឌនៃព្រះ

[20] មាត្រា៧២ នៃក្រមព្រហ្មទណ្ឌ

រាជាណាចក្រកម្ពុជា ជាទូទៅ ការងារសហគមន៍ត្រូវអនុវត្តឱ្យបានសមស្របតាមលក្ខខណ្ឌនៃច្បាប់ស្តីពីការងារ ជាអាទ៍ ការងារនៅពេលយប់ អនាម័យ និងការងាររបស់ស្ត្រី ។ ម្យ៉ាងទៀត តុលាការក៏អាចប្រកាសទោសការងារសហគមន៍ត្រួតគ្នាបានជាមួយនឹងការអនុវត្តសកម្មភាពវិជ្ជាជីវៈណាមួយបានផងដែរ មាត្រា៧៤ នៃក្រមព្រហ្មទណ្ឌ ។

ជាងនេះទៅទៀត រដ្ឋមានកាតព្វកិច្ចចេញសោហ៊ុយជួសជុលការខូចខាត ដែលបង្កឡើងដល់អ្នកដទៃដោយអំពើរបស់ទណ្ឌិតនៅក្នុងពេលដែលទណ្ឌិតនេះកំពុងបំពេញការងារ ដើម្បីផលប្រយោជន៍របស់សហគមន៍ណាមួយផងដែរ ។

**៣.២ ទោសស្តីបន្ទោស**

ទោសស្តីបន្ទោសនេះ យើងអាចនិយាយបានថា ជាទោសដែលប្រើប្រាស់សម្រាប់បទល្មើសដែលស្រាល ហើយតុលាការសម្រេចមិនដាក់ពន្ធានាគារ ឬពិន័យជាប្រាក់អ្វីនោះទេ ក្នុងគោលបំណងជាការព្រមាន ការអប់រំ ការប្រដៅអំពីកំហុសឆ្គងរបស់ជនល្មើសដែលបានប្រព្រឹត្ត ហើយជាការព្រមានកុំឱ្យជននេះប្រព្រឹត្តបទល្មើសជាថ្មីទៀត ។ ដូចនេះ  កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារ ដែលអតិបរមាតិចជាង ឬស្មើនឹង៣ (បី) ឆ្នាំ តុលាការអាចប្រកាសស្តីបន្ទោស ប្រសិនបើមានគ្រប់លក្ខខណ្ឌ ទាំងបីដូចតទៅនេះ ៖

-ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈដែលបណ្តាលមកពីបទល្មើសបានបញ្ចប់

-ការខូចខាតត្រូវបានជួសជុលរួចហើយ និង

-ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ ។

ជាងនេះទៅទៀត ការងារសហគមន៍ត្រូវស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ ជាអាទិ៍ការងារនៅពេលយប់ អនាម័យ សន្តិសុខ ហើយនិងការងាររបស់ស្ត្រីការងារសហគមន៍នេះអាចត្រួតគ្នាបានជាមួយនឹងសកម្មភាព វិជ្ជាជីវៈ[21] ។ ម្យ៉ាងទៀត រដ្ឋត្រូវតែចេញសោហ៊ុយជួលជុលការខូចខាតដែលបង្កដល់អ្នកដទៃដោយទណ្ឌិតនៅក្នុងពេលដែលកំពុងអនុវត្តការងារសហគមន៍ ហើយរដ្ឋត្រូវតែធ្វើឧបាទេសកម្មដោយពេញច្បាប់ទៅក្នុងសិទ្ធិជនរងគ្រោះ[22] ។

ឧបាទេសកម្មមានន័យថា គឺជាឋានៈមួយដែលបុគ្គលម្នាក់ទទួលជំនួសបុគ្គលណាមួយទៅតាមផ្លូវច្បាប់ ។ បានជាច្បាប់កំណត់យ៉ាងនេះ ព្រោះពេលខ្លះជនដែលទទួលរងនូវការងារសហគមន៍នេះគ្មានថវិកាបង់ខ្លួនឯងឡើយ ។ ដូច្នេះបើរដ្ឋមិនចេញសំណងជំនួសនោះទេ ជនរងគ្រោះនឹងមិនទទួលបានការជួសជុលនូវការខូចខាតនោះទេ ហើយនឹងបណ្តាលឱ្យមានភាពអយុត្តិធម៌ចំពោះជនរងគ្រោះដែលជាប្រជាពលរដ្ឋរបស់ខ្លួនជាក់ជាមិនខាន ។

---

[21] មាត្រា ៧៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

[22] មាត្រា ៧៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

## ផ្នែកទី២ ទោសដែលត្រូវអនុវត្តចំពោះរូបវន្តបុគ្គលជាអនីតិជន

ជាគោលការណ៍ អនីតិជនអាយុក្រោម១៤ឆ្នាំ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។ ដូចនេះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងត្រូវប្រគល់អនីតិជននោះឱ្យទៅអ្នកតំណាងដែលច្បាប់បានកំណត់វិញភ្លាម ។ ម្យ៉ាងទៀត ការកំណត់ពីអាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន គឺត្រូវកំណត់យកអាយុនៅពេល ដែលអនីតិជននោះប្រព្រឹត្តបទល្មើស។ ភស្តុតាងនៃអាយុរបស់អនីតិជន ត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត ឬឯកសារផ្សេងៗទៀតដែលបានបញ្ជាក់អំពីកំណើត។ ក្នុងករណីមានការសង្ស័យពីអាយុរបស់អនីតិជនវិមតិ សង្ស័យត្រូវបានជាប្រយោជន៍ដល់អនីតិជននោះ។

### ១ មូលទោស

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវកំណត់ចាប់ពីអាយុ១៨ ឆ្នាំឡើងទៅ មាត្រា៣៨ នៃក្រមព្រហ្មទណ្ឌ ហើយជាគោលការណ៍អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ មិនមែនជាកម្មវត្ថុនៃការទទួលខុសត្រូវព្រហ្មទណ្ឌនោះឡើយ មានន័យថា គ្មានទោសណាមួយដែលអាចត្រូវបានអនុវត្តចំពោះអនីតិជនដែលមានអាយុក្រោម ១៤ នោះឡើយ ។ ប៉ុន្តែ ច្បាប់បានបញ្ញត្តិនៅអញ្ញត្តកម្មដែលអាចឱ្យតុលាការធ្វើការអនុវត្តទោសទៅលើអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំដល់ក្រោម ១៨ ឆ្នាំបាន ប្រសិនបើបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ ហើយប្រែក្លាយការដាក់ពន្ធនាគារជាការអប់រំ និងកែប្រែក្នុងទិសដៅស្តារនីតិសម្បទារឡើងវិញ ក្នុងការចូលមករួមរស់ក្នុងសង្គមវិញ ហើយវិធានការផ្សេងពីនេះពិតជាមិនមានប្រសិទ្ធិភាពកែប្រែអនីតិជននោះទេ ។ ប៉ុន្តែ ទោសដែលត្រូវអនុវត្តចំពោះអនីតិជននេះ មានលក្ខណៈមិនដូចនីតិជននោះទេ ព្រោះការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជនមានលក្ខណៈស្រាលជាងនីតិជន ។ ម្យ៉ាងទៀត ប្រសិនបើតុលាការសម្រេចផ្តន្ទាទោសទៅលើអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ អត្ថប្រយោជន៍ដែលអនីតិជនទទួលបាននោះគឺការបន្ថយទោសចំនួនពាក់កណ្តាល[23] ។

កាលណាតុលាការ សម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ មូលទោស លើបទល្មើសដែលចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ ៖

- អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល។
- ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ឆ្នាំ។
- អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះ លើសពី ១ថ្ងៃ។
- អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល។

[23] មាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាព បន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមចិរវេលាមួយស្មើ ឬតិចជាង ៥ឆ្នាំ នោះ បទ ល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល។

ឧទាហរណ៍ ករណីអនីតិជនប្រព្រឹត្តបទហិង្សាដោយចេតនាមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចន្លោះពី ១ ឆ្នាំទៅ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ២ លានរៀលទៅ ៦ លានរៀល ។ ដូច្នេះ យោងតាមបញ្ញត្តិនៃមាត្រា១៦០ អប្បបរមា និងអតិបរមា នៃទោសដាក់ពន្ធនាគារនិងទោសពិន័យជាប្រាក់ត្រូវបន្ថយពាក់កណ្តាល មានន័យថា អនីតិជននឹងត្រូវទទួលរងទោសដាក់ពន្ធនាគារចន្លោះពី ៦ ខែទៅ ១ឆ្នាំកន្លះ និងពិន័យជាប្រាក់ពី ១ លានរៀលទៅ ៣ លានរៀល តែប៉ុណ្ណោះ ។

ឧទាហរណ៍ ករណីអនីតិជនប្រព្រឹត្តបទល្មើសឃាតកម្មគិតទុកជាមុន មាត្រា២០០ នៃក្រមព្រហ្មទណ្ឌ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់១ជីវិត ។ ដូច្នេះ អតិបរមានៃទោសដាក់ពន្ធនាគារអស់មួយជីវិតនេះនឹងបន្ថយមកសល់ត្រឹមតែ ២០ ឆ្នាំ ប៉ុណ្ណោះ ។

**២ ទោសបន្ថែម**

ដូចដែលបានរៀបរាប់ពីខាងដើមរួចមកហើយថា ការប្រកាសទោសបន្ថែមគឺអាស្រ័យលើបម្រែបម្រួលនៃបុគ្គលផ្ទាល់ ហើយទោសបន្ថែមដែលមានចែងនៅក្នុងមាត្រា៥៣ ទាំង១៩ ចំណុច ជាបញ្ញត្តិទូទៅ ឬ អាចនិយាយបានថាសម្រាប់ដាក់លើនីតិជន ដោយឡែកអនីតិជនវិញមានបញ្ញត្តិដោយឡែកសម្រាប់ពួកគេផងដែរ គឺ មានចែងនៅក្នុងមាត្រា ១៦១ នៃក្រមព្រហ្មទណ្ឌ ។

ជាគោលការណ៍ទោសបន្ថែម គឺជាទោសដែលគេត្រូវប្រកាសបន្ថែមឲ្យមូលទោស ហើយបើទោះបីជាច្បាប់ អនុគ្រោះសម្រាប់អនីតិជនដែលមានអាយុក្រោម១៤ (ដប់បួន) ឆ្នាំ ពុំទទួលខុសត្រូវព្រហ្មទណ្ឌក៏ដោយ តែទោះជាយ៉ាងណាដើម្បីការពារសណ្តាប់ធ្នាប់សាធារណៈ និងសង្គមជាតិឲ្យមានរបៀបរៀបរយល្អ ច្បាប់មិនលើកលែងចំពោះអនីតិជនដែលមានអាយុចាប់ពី១៤ (ដប់បួន)ឆ្នាំ ដល់ក្រោម១៨ (ដប់ប្រាំបី) ឆ្នាំទេ គឺពួកគេនៅតែទទួលទណ្ឌកម្មពីច្បាប់ដដែល។ ក្នុងករណីដែលតុលាការជ្រើសរើសសម្រេចផ្តន្ទាទោសមូលទោសចំពោះអនីតិជនប្រភេទរួចហើយ ហើយប្រសិនបើ តុលាការនោះសម្រេចប្រកាសទោសបន្ថែម នោះមានតែទោសបន្ថែមចំនួន៥ប៉ុណ្ណោះ ដែលត្រូវយកទៅអនុវត្តចំពោះអនីតិជន ហើយក្នុងនោះទោសបន្ថែមទាំងនោះមាន៤ គឺជាទោសដែលជាវិធានការនៃការរឹបអូសយកទ្រព្យសម្បត្តិដែលមានទំនាក់ទំនងជាមួយ បទល្មើសផ្ទាល់ និងទោសមួយគឺជាទោសដែលមានលក្ខណៈជាការហាមឃាត់ រីឯទោសដែលមានលក្ខណៈជា ការបង្ខាំងទុក ការដកហូតសិទ្ធិពលរដ្ឋ ការហាមឃាត់មិនឲ្យស្នាក់អាស្រ័យ និងការផ្សព្វផ្សាយការផ្តន្ទាទោសជា អាទិ៍ មិនត្រូវយកមកអនុវត្តឡើយ ព្រោះវាជាទោសដែលអាចនាំឲ្យបាត់បង់សេចក្តីថ្លៃថ្នូរ និងនាំឲ្យខូចកិត្តិយសក៏ ដូចជាអនាគតរបស់អនីតិ

ជន ។ ដូច្នេះ មានតែទោសបន្ថែមដែលមានចែងដូចតទៅនេះប៉ុណ្ណោះ ដែលអាចអនុវត្តចំពោះអនីតិជនបាន

១- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែលមាន គោលដៅប្រព្រឹត្តបទល្មើស។

២- ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។

៣- ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

៤- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត។

៥- ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

**៣ ទោសជំនួស**

ចំពោះទោសជំនួសវិញ មានតែទោសការងារសហគមន៍ប៉ុណ្ណោះដែលអាចអនុវត្តចំពោះអនីតិជនបាន។ ប៉ុន្តែអនីតិជននោះត្រូវតែមានអាយុចាប់ពី ១៦ ឆ្នាំឡើងទៅ ហើយថិរវេលាក៏មានរយៈតិចជាងនីតិជនផងដែរ ។ ដោយឡែក ទោសការងារសហគមន៍អាចអនុវត្តទៅលើអនីតិជនដែលមានអាយុយ៉ាងតិច ១៦ ឆ្នាំ ប៉ុន្តែថិរវេលានៃការងារមិនអាចលើសពី ១០០ ម៉ោង ហើយការងារសហគមន៍ ត្រូវតែសម្របសម្រួលទៅលើអនីតិជន មានលក្ខណៈជាការបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ជូនខ្លួនទៅរស់នៅក្នុងសង្គមវិញ[24] ។ ម្យ៉ាងទៀត បញ្ញត្តិស្តីពីការមិនរាងចាល ក៏មិនត្រូវយកមកអនុវត្តឡើយចំពោះអនីតិជន[25] ។

**ផ្នែកទី៣ ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល**

នីតិបុគ្គល គឺជាក្រុមមនុស្ស ឬជាមូលនិធិ ដែលមានបុគ្គលភាពគតិយុត្ត ហើយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច ។ ដូច្នេះហើយ ទោសមួយចំនួនពុំអាចត្រូវបានយកមកអនុវត្តបាននោះឡើយ ចំពោះនីតិបុគ្គល ។ ហេតុនេះ ជាគោលការណ៍ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គលមានពីរគឺ មូលទោស និងទោសបន្ថែម ដោយមិនអនុវត្តទោសពន្ធនាគារទៅលើនីតិបុគ្គលបានទេ ។

**១ ទោសពិន័យក្នុងឋានៈជាមូលទោស**

មូលទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល គឺមានតែទោសពិន័យជាប្រាក់តែប៉ុណ្ណោះ ដោយសារតែនីតិបុគ្គលអាចជាក្រុមហ៊ុន សមាគម ឬអង្គការជាដើម ដែលត្រូវបានបង្កើតឡើងដោយក្រុមមនុស្ស ដូចនេះ យើងមិនអាចយកក្រុមហ៊ុនដែលជាថ្មមកដាក់គុកបានទេ[26] ។

**២ ទោសបន្ថែម**[27]

---

[24] មាត្រា ១៦២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

[25] មាត្រា ១៦៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

[26] មាត្រា ១៦៧ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

[27] មាត្រា ១៦៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

ទោសបន្ថែមដែលត្រូវអនុវត្តចំពោះនីតិបុគ្គលមាន១៤ ចំណុចរួមមាន ៖

-ការរំលាយចោល ការរំលាយនេះមានន័យថាតុលាការបានចេញសេចក្តីបង្គាប់ឱ្យរំលាយនីតិ បុគ្គលនោះ ដែលការនេះនាំឱ្យមានការបញ្ជូននីតិបុគ្គលទៅតុលាការដែលមានសមត្ថកិច្ច ដើម្បីធ្វើការ ជំរះបញ្ជីឆ្នាំ ទេ ។

-ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ ទោសនេះមិនអាចលើសពី ៥

-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬច្រើន ការហាមនេះអាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់ចិរវេលា ៥ ឆ្នាំ យ៉ាងច្រើន ។ តុលាការបញ្ជាក់អំពីសកម្មភាពដែលត្រូវហាមឃាត់ ។

-ការបណ្តេញចេញពីលិទ្ធកម្មសាធារណៈ ទោសនេះអាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់ចិរវេលា មិនលើសពី ៥ ឆ្នាំ ទេ ។

-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ ទោសនេះអាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល៥ឆ្នាំយ៉ាងច្រើន ។

-ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន ក្រៅពីឧករណ៍អាចជួញដូរបាន ដែលកំណត់ ដោយកំណត់ដោយធនាគារ ទោសនេះអាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈ ពេល ៥ ឆ្នាំ យ៉ាងច្រើន ។

-ការហាមឃាត់ចំពោះការប្រើបណ្ណទូទាត់ ។

-ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬប្រព្រឹត្តបទល្មើស ទោសបិទគ្រឹះស្ថាននាំឱ្យ មានការហាមឃាត់ចំពោះការព្រឹត្តនៅក្នុងគ្រឹះស្ថាននេះ នូវសកម្មភាពដែលបទល្មើសបានកើតឡើង នៅក្នុងឱកាសដែលធ្វើសកម្មភាពដែលបទល្មើសបានកើតឡើងនៅក្នុងឱកាសដែលធ្វើសកម្មភាពនេះ ទោសនេះផងដែរអាចស្ថាពរ ឬបណ្តោះអាសន្នសម្រាប់រយៈពេល ៥ ឆ្នាំ យ៉ាងច្រើន ។

-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហរដល់សាធារណៈជន ឬដែលបានប្រើប្រាស់ដោយសាធារណៈជន ទោសនេះអាចស្ថាពរ ឬជាបណ្តោះអាសន្នក្នុងរយៈពេល ៥ ឆ្នាំ យ៉ាងច្រើន ។

-ការរឹបអូសឧករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមាន គោលដៅសម្រាប់ប្រព្រឹត្តល្មើស កាលបើរឹបអូសក្លាយជាស្ថាពរ វត្ថុរឹបអូសក្លាយជាកម្មសិទ្ធរបស់រដ្ឋ លើកលែងតែបទបញ្ញត្តិដោយឡែកបានចែងអំពីការប្រគល់ផ្សេងទៀត ។

-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

-ការរិបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតពីបទល្មើស ។

-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ។

-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារាព័ត៌មាន។

# ជំពូកទី៣
# នីតិវិធីនៃការអនុវត្តទោស និងមូលហេតុទូទៅដែលនាំឲ្យមានផលប៉ះពាល់ដល់ការអនុវត្តទោស

## ផ្នែកទី១ នីតិវិធីអនុវត្តសេចក្តីសម្រេចរបស់តុលាការពាក់ព័ន្ធនឹងមូលទោស

នៅពេលពេលធ្វើការពិភាក្សាដេញដោលចប់សព្វគ្រប់ តុលាការនឹងធ្វើការកំណត់ថ្ងៃដែលត្រូវប្រកាសសាលក្រម ។ នៅពេលដែលប្រកាសសាលក្រមប្រធានសវនា ត្រូវអានដោយសម្លេងខ្លាំងៗផ្នែកនៃសេចក្តីសម្រេចរបស់សាលក្រម[28] ។ តុលាការអាចសម្រេចសេចក្តីបានតែទៅលើអំពើទាំងឡាយណា ដែលមានបង្ហាញនៅក្នុងសាលដីកា បញ្ជូន ដីកាបញ្ជូន ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬកំណត់ហេតុនៃការបង្ហាញខ្លួនភ្លាម [29] ។ ប្រសិនបើពិនិត្យឃើញថា មានពិរុទ្ធភាពលើជនជាប់ចោទ តុលាការប្រកាសផ្តន្ទាទោសតាមច្បាប់បញ្ញត្តិ[30] ។ ហេតុដូច្នេះ សេចក្តីសម្រេចរបស់តុលាការដែលត្រូវបានប្រកាសលើជនជាប់ចោទ ត្រូវតែអនុវត្តតាមសេចក្តីសម្រេចនោះ ។

ម្យ៉ាងទៀត បន្ទាប់ពីសេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរ ទណ្ឌិតត្រូវអនុវត្ត ឬត្រូវបង្ខំឱ្យអនុវត្តតាមសេចក្តីសម្រេចរបស់តុលាការ ។ ចំពោះសេចក្តីសម្រេចចំពោះរឿងក្តីព្រហ្មទណ្ឌ ទណ្ឌិតត្រូវអនុវត្តមូលទោសទៅតាមការប្រកាសរបស់តុលាការ ដែលមានការអនុវត្តទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ។

### ១. ការអនុវត្តទោសពន្ធនាគារ

តុលាការប្រកាសផ្តន្ទាទោសជនជាប់ចោទតាមបញ្ញប្បត្តិច្បាប់ ក្រោយពីបានពិនិត្យឃើញមានពិរុទ្ធភាព លើជនជាប់ចោទ។ ប្រសិនបើតុលាការប្រកាសផ្តន្ទាទោសដាក់ពន្ធនាគារ ដោយគ្មានការព្យួរទោសទេ តុលាការតាមសេចក្តីសម្រេច និងដោយតាមសំអាងហេតុ អាចចេញនៅក្នុងសវនាការ ដីកាបង្គាប់ឱ្យឃុំ ខ្លួនជនជាប់ចោទដែលមានវត្តមានដែលកំពុងជាប់ឃុំ និងដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទ ដែលអវត្តមានដែលកំពុងនៅក្រៅឃុំ[31] ។

#### ១.១ ការអនុវត្តទោសចំពោះបុគ្គលដែលជាប់ឃុំ

ចំពោះបុគ្គលជាប់ឃុំដែលត្រូវបានចៅក្រមស៊ើបសួរចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដែលយើងហៅថាជាជនត្រូវចោទ ។ ត្រូវជនជាប់ចោទ ជាបុគ្គលដែលត្រូវបានបញ្ជូនទៅចំពោះមុខតុលាការដើម្បីជំនុំជម្រះ តាមដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីការបញ្ជូនរបស់សភាស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងទៅកាន់តុលាការជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា ឬតាមកំណត់ហេតុស្តីពីការចូលបង្ហាញខ្លួន

[28] មាត្រា៣៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[29] មាត្រា៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[30] មាត្រា៣៥០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[31] មាត្រា៣៥៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ភ្លាមរបស់ព្រះរាជអាជ្ញា ។ ការឃុំឃាំងពិរុទ្ធជន ត្រូវធ្វើឡើងតាមអំណាចដីការបស់ចៅក្រម បន្ទាប់ពីចៅក្រមធ្វើការជំនុំជម្រះទៅលើជនជាប់ចោទថាពិតជាមានពិរុទ្ធមែន និងត្រូវរង់ចាំផុតអំឡុងពេលប្ដឹងឧទ្ធរណ៍សិន (បណ្ដឹងទាស់ និងបណ្ដឹងឧបាស្រ័យ) ។ បន្ទាប់តុលាការប្រកាសសេចក្ដី សម្រេចរួចមក ពិរុទ្ធជនដែលត្រូវចាប់ខ្លួនដោយអនុវត្តតាមដីកាបង្គាប់ឱ្យចាប់ខ្លួននោះ ត្រូវតែបានគេនាំទៅ បង្ហាញខ្លួនក្នុងរយៈពេលខ្លីបំផុតនៅមុខព្រះរាជអាជ្ញា ជាទីកន្លែងចាប់ខ្លួនដែលឱ្យដំណឹងដល់សាមីខ្លួនអំពីដីកានេះ និងធ្វើការឃុំខ្លួន[32] ។

ក្រោយពីសេចក្ដីសម្រេចរបស់តុលាការចូលជាស្ថាពររួចហើយ ទណ្ឌិតត្រូវបានឃុំខ្លួនក្នុងមណ្ឌលឃុំឃាំង ស្របច្បាប់តាមអំណាចសេចក្ដីសម្រេចពីតុលាការមានសមត្ថកិច្ច ។ ចំពោះការអនុវត្តទោសពន្ធនាគារ គឺត្រូវធ្វើនៅក្នុងពន្ធនាគាររបស់រដ្ឋ ។ ទណ្ឌិតដែលឃុំខ្លួនក្នុងពន្ធនាគារ អនុវត្តការឃុំខ្លួននេះរហូតដល់រយៈពេលដែលទោសត្រូវបានបញ្ចប់ ។ ចំណែកឯចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវបានគិតបញ្ចូលទាំងស្រុងនៅក្នុងចិរវេលានៃទោស ដែលបានប្រកាស ឬជាយថាហេតុនៃចិរវេលាសរុបនៃទោសដែលត្រូវទទួលរង បន្ទាប់ពីការស្រូបទោសបញ្ចូលគ្នា[33] ។

ទោសដាក់ពន្ធនាគារ ១ (មួយ)ថ្ងៃ ត្រូវគិត ២៤ (ម្ភៃបួន)ម៉ោង។ ទោសដាក់ពន្ធនាគារ ១ (មួយ)ខែ ត្រូវគិត ៣០ (សាមសិប)ថ្ងៃ ទោសដាក់ពន្ធនាគារលើស។ ទោសដាក់ពន្ធនាគារលើសពី ១ (មួយ)ខែ ត្រូវគិតតាមលេខ រៀងនៃថ្ងៃក្នុងខែទី១ ទៅលេខរៀងនៃថ្ងៃក្នុងខែមួយទៀត។ ទណ្ឌិតដែលបានអនុវត្តទោសរបស់ខ្លួនរួចហើយ ត្រូវដោះលែងនៅក្នុងចន្លោះពីម៉ោង៦ ព្រឹក ដល់ម៉ោង ១៨[34] ។

### ១.២ ការអនុវត្តទោសចំពោះបុគ្គលដែលនៅក្រៅឃុំ

កាលណាសាលក្រមត្រូវបានសម្រេចដោយកំបាំងមុខនោះ ពិរុទ្ធជនដែលសម្រេចចិត្តប្ដឹងទាស់ ត្រូវតែចូល បង្ហាញខ្លួននៅក្នុងរយៈពេលយ៉ាងខ្លីបំផុត នៅមុខតុលាការដែលបានប្រកាសសាលក្រម។ ពិរុទ្ធជនអាចធ្វើពាក្យ សុំនៅក្រៅឃុំ ។ តុលាការត្រូវសម្រេចដូចដែលមានចែងក្នុងមាត្រា ៣០៧ បណ្ដឹងសុំដោះលែងឱ្យមានសេរីភាព របស់ជនជាប់ចោទដែលជាប់ឃុំ[35] ។ ក្នុងករណីដែលពិរុទ្ធជនមិនបង្ហាញខ្លួន និងក្នុងករណីមានសេចក្ដីសម្រេចផ្ដន្ទាទោសដោយតុលាការ គឺជាសេចក្ដីសម្រេចដែលធ្វើឡើងដោយកំបាំងមុខនោះ សេចក្ដីជូនដំណឹងពីសេចក្ដីសម្រេចនេះតាមលក្ខខណ្ឌដែល ច្បាប់បានកំណត់នឹងធ្វើឱ្យសេចក្ដីសម្រេចផ្ដន្ទាទោសរបស់តុលាការក្លាយចូលជាស្ថាពរចំពោះទណ្ឌិត ។

[32] មាត្រា៣៥៣ កថាខណ្ឌទី៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[33] មាត្រា៥០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[34] មាត្រា៥០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[35] មាត្រា៣៥៣ កថាខណ្ឌទី៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

## ២. ការអនុវត្តទោសពិន័យ

នៅក្នុងករណីមួយចំនួន ក្រោយពីការប្រកាសទោសណាមួយដូចជាទោសពិន័យជាដើមនោះទណ្ឌិតមិនបានបង់ប្រាក់ពិន័យ ឬប្រាក់ពន្ធនៃនិតិវិធី និងប្រាក់សំណងទៅជនរងគ្រោះនោះទេ ។ ដូច្នេះ ច្បាប់បានបញ្ញត្តិបន្ថែមនូវទណ្ឌកម្ម ពោលគឺការបង្ខំរូបកាយ ដែលត្រូវឃុំឃាំងទណ្ឌិតនៅក្នុងពន្ធនាគារតាមកម្រិតដែលច្បាប់បានកំណត់ ។ ម្យ៉ាងទៀត ក្នុងការដឹកនាំការអនុវត្តទោសព្រហ្មទណ្ឌជាភារកិច្ចរបស់អយ្យការ ដែលមានព្រះរាជអាជ្ញាជាអ្នកផ្តួចផ្តើមទាំងការចោទប្រកាន់ ទាំងការអនុវត្តទោសនៅពេលដែលសេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរ ។

ទោសពិន័យជាប្រាក់តម្រូវឱ្យទណ្ឌិតត្រូវតែបង់ប្រាក់ពិន័យ ឬបានកំណត់ដោយតុលាការ ហើយដើម្បីធានាឱ្យបាននូវការបង់ប្រាក់ពិន័យ មានវិធានការពីរយ៉ាងដែលអាចយកមកអនុវត្តបានគឺ **ការរឹបអូស** និង**ការបង្ខំដល់រូបកាយ** ។ ស្របជាមួយគ្នានេះដែរ រាល់ការពាក់ព័ន្ធនឹងការរឹបអូសទ្រព្យសម្បត្តិរបស់ទណ្ឌិត បទបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវតែយកមកអនុវត្ត។ ដោយឡែកវិធានការទីពីរនៃការទាមទារប្រាក់ពិន័យ គឺជាការបង្ខំដល់រូបកាយដែលមានចែកក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ម៉្យាងវិញទៀត ការបង្ខំដល់រូបកាយក៏អាចត្រូវយកមកប្រើប្រាស់ ដើម្បីទាមទារប្រាក់ពន្ធនៃនីតិវិធី ប្រាក់សំណង និងជម្ងឺចិត្តដែលត្រូវបង់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីផងដែរ[36] ។ ការបង្ខំដល់រូបកាយត្រូវយកមកអនុវត្តដោយពេញលក្ខណៈច្បាប់ មានន័យថា តុលាការពុំបាច់ប្រកាសអំពីការបង្ខំដល់រូបកាយនៅក្នុងសេចក្តីសម្រេចនោះទេ [37] គឺការបង្ខំដល់រូបកាយនឹងត្រូវតែយកមកអនុវត្តដោយស្វ័យប្រវត្តិ ដោយធ្វើការចាប់ផ្តើមពីការដាស់តឿនឱ្យបង់ប្រាក់ពិន័យជាមុន ។

### ២.១ ការដាស់តឿនឱ្យបង់ប្រាក់ពិន័យ[38]

ចំពោះករណី ប្រសិនបើទណ្ឌិតមិនបង់ប្រាក់ពិន័យទេ អង្គភាពរតនាគារត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា។ រាល់ការមិនបង់ប្រាក់ពិន័យប្រភេទណាក៏ដោយ គឺសុទ្ធសឹងតែអាចចូលជាកម្មវត្ថុនៃការបង្ខំរូបកាយបានទាំង អស់ ទោះបីជាប្រាក់ពិន័យដែលត្រូវបានប្រកាសពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ឬពីបទលហុ ។

ព្រះរាជអាជ្ញាត្រូវកំណត់រយៈពេលចុងក្រោយបង្អស់ដល់ទណ្ឌិតដើម្បីឱ្យទណ្ឌិតបង់ប្រាក់ពិន័យដោយជូន ដំណឹងថា ប្រសិនបើទណ្ឌិតមិនព្រមបង់ សាមីខ្លួនអាចនឹងត្រូវបង្ខំដល់រូបកាយ។ ចំណែកឯរយៈពេលដែលព្រះ រាជអាជ្ញាកំណត់មិនអាចតិចជាង ១០ (ដប់)ថ្ងៃទេ។ ចំពោះការជូនដំណឹងត្រូវធ្វើឡើងដោយផ្ទាល់មាត់ ឬក៏តាម ផ្លូវរដ្ឋបាល ឬតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ បន្ថែមពីនេះទៅទៀត ការឱ្យដំណឹងត្រូវ

---

[36] មាត្រា៥២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[37] មាត្រា៥២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[38] មាត្រា៥២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

តែមាន ការធ្វើកំណត់ហេតុដែលត្រូវចុះហត្ថលេខា ឬផ្តិតស្នាមមេដៃដោយទណ្ឌិត ក្នុងករណីដែលទណ្ឌិតមិនចេះចុះហត្ថ លេខា។

**២.២ ការបង្ខំដល់រូបកាយ**

ការបង្ខំដល់រូបកាយ ជាវិធានការមួយដែលត្រូវអនុវត្តទៅលើបុគ្គលដែលត្រូវតុលាការសម្រេចផ្តន្ទាទោស តែបុគ្គលទាំងនេះមិនបង់នូវប្រាក់ដូចជា ប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធីប្រាក់សំណង ឬ ជំងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណី[39] ។ ការបង្ខំដល់រូបកាយនេះគឺដើម្បីបង្ខំឱ្យទណ្ឌិតបង់ប្រាក់ ដោយត្រូវទទួលនូវទណ្ឌកម្មបន្ថែមក្នុងករណីរឹងទទឹងមិនព្រមបង់ ។ ទោះបីជាការបង្ខំដល់រូបកាយត្រូវអនុវត្តចប់ ហើយទណ្ឌិតទទួលរងទោសរួចហើយក៏ដោយ ក៏ទណ្ឌិតរូបនេះមិនអាចរួចផុតពីបំណុលដដែល មានន័យថាទណ្ឌិតត្រូវមានកាតព្វកិច្ចបង់ប្រាក់ដដែល ប៉ុន្តែទណ្ឌិតមិនត្រូវទទួលរងការបង្ខំដល់រូបកាយ ម្តងទៀតចំពោះបំណុលដដែលនោះបានទេ ពោលគឺការបង្ខំរូបកាយអាចធ្វើបានតែម្តងគត់ប៉ុណ្ណោះ សម្រាប់បំណុលមួយ[40] ។ ការបង្ខំដល់រូបកាយនេះត្រូវបានបែងចែកជាពីរករណី គឺការបង្ខំដល់រូបកាយក្នុងករណីមិនបង់ប្រាក់ពិន័យនិងប្រាក់ពន្ធនីតិវិធី និងការបង្ខំរូបកាយតាមពាក្យប្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

**២.២.១. ការបង្ខំដល់រូបកាយក្នុងករណីមិនបង់ប្រាក់ពិន័យ និងប្រាក់ពន្ធនីតិវិធី**

ប្រសិនបើទណ្ឌិតមិនបង់ប្រាក់ពិន័យ ឬប្រាក់ពន្ធនៃនីតិវិធីទេ អង្គភាពរតនាគារជូនដំណឹងដល់ព្រះរាជអាជ្ញានៃតុលាការអមសាលាដំបូង ។ ព្រះរាជអាជ្ញាកំណត់រយៈពេលចុងក្រោយដល់ទណ្ឌិតដើម្បីបង់ប្រាក់នោះហើយ ឱ្យដំណឹងដល់ ព្រះរាជអាជ្ញានៃតុលាការអមសាលាដំបូង[41] ។

ព្រះរាជអាជ្ញាកំណត់ពេលចុងក្រោយដល់ទណ្ឌិត ដើម្បីបង់ប្រាក់នោះ ហើយឱ្យដំណឹងថា ប្រសិនបើមិនបង់ទេនោះ សាមីខ្លួនអាចត្រូវបង្ខំដល់រូបកាយ ។ រយៈពេលនេះមិនអាចតិចជាង ១០ ថ្ងៃ ទេ ។

ការឱ្យដំណឹងត្រូវធ្វើ ៖

-ដោយផ្ទាល់មាត់ ឬ

-តាមផ្លូវរដ្ឋបាល ឬ

-តាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ។

ត្រូវតែមានធ្វើកំណត់ហេតុស្តីពីការឱ្យដំណឹងនេះ ហើយកំណត់ហេតុនេះត្រូវចុះហត្ថលេខាដោយទណ្ឌិត ។

[39] មាត្រា៥២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[40] មាត្រា៥៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[41] មាត្រា៥២៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ប្រសិនបើទណ្ឌិតមិនចេះចុះហត្ថលេខាទេ ទណ្ឌិតត្រូវផ្តិតម្រាមដៃ[42] ។ លុះផុតរយៈពេលកំណត់ ប្រសិនបើទណ្ឌិតមិនបានបង់ប្រាក់នោះទេ ព្រះរាជអាជ្ញាចេញបញ្ជា ឱ្យបង្ខំ និងឱ្យឃុំខ្លួន ។ ព្រះរាជអាជ្ញាអាចបង្អង់សេចក្តីសម្រេចនេះបាន ដោយមូលហេតុមនុស្សធម៌ ជាអាទិ៍ ដូចជាស្ថានភាពសុខភាពរបស់ទណ្ឌិត[43] ។

**២.២.២ ការបង្ខំរូបកាយក្នុងករណីមិនបង់ប្រាក់សំណងរដ្ឋប្បវេណី និងជម្ងឺចិត្ត**

កាលណាដើមបណ្តឹងរដ្ឋប្បវេណីមិនបានទទួលប្រាក់សំណង និងជម្ងឺចិត្តពីទណ្ឌិត ឬ ពីអ្នកទទួលខុសត្រូវរដ្ឋប្បវេណីទេ ដើមបណ្តឹងរដ្ឋប្បវេណី អាចសុំដល់ព្រះរាជអាជ្ញាឱ្យធ្វើការបង្ខំដ រូបកាយបាន ។ ការបង្ខំដល់រូបកាយដើម្បីទារសំណង និងជម្ងឺចិត្ត អាចអនុវត្តបានតែនៅលើទណ្ឌិតប៉ុណ្ណោះ ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវជូនភស្តុតាងថា ខ្លួនបានប្រើអស់មធ្យោបាយអនុវត្តដែលមាន ចែងក្នុងច្បាប់ដូចជាការរឹបអូសចលនវត្ថុ ឬ អចលនវត្ថុជាដើម ។

ក្នុងករណី ប្រសិនបើទណ្ឌិតមិនព្រមបង់ ការបង្ខំដល់រូបកាយត្រូវយកមកអនុវត្ត ហើយនីតិវិធីគឺមានលក្ខណៈដូចគ្នាទៅនឹងការបង្ខំរូបកាយក្នុងករណីមិនព្រមបង់ប្រាក់ពិន័យ និងប្រាក់ពន្ធនីតិវិធីដែរ[44] ។

**២.២.៣ ថិរវេលានៃការបង្ខំរូបកាយ និងជនដែលមានសមត្ថភាពអាចទទួលរងនូវការបង្ខំរូបកាយ**[45]

ថិរវេលានៃការបង្ខំរូបកាយត្រូវកំណត់ដូចតទៅ ៖

-១០ ថ្ងៃ កាលណាទឹកប្រាក់ដែលមិនបង់នោះមានចំនួនមិនលើសពី ២៥០ ០០០ (ពីរសែនប្រាំម៉ឺន) រៀល ។

-២០ (ម្ភៃ) ថ្ងៃ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ២៥០.០០១ (ពីរសែនប្រាំម៉ឺនមួយ) រៀលដល់ ៥០០.០០០ (ប្រាំសែន) រៀល ។

-១ (មួយ) ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ៥០០.០០១ (ប្រាំសែនមួយ) រៀលដល់ ១.០០០.០០០ (មួយលាន) រៀល ។

-២ (ពីរ) ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ១.០០០.០០១ (មួយលានមួយ)រៀល ដល់ ២.៥០០.០០០ (ពីរលានប្រាំសែន) រៀល ។

-៣ (បី) ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ២.៥០០.០០១ (ពីរលានប្រាំសែនមួយ) រៀលដល់ ៥.០០០.០០០ (ប្រាំលាន) រៀល ។

---

[42] មាត្រា៥២៣ កថាខណ្ឌទី២និងទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[43] មាត្រា៥២៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[44] មាត្រា៥៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[45] មាត្រា៥៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

-៦ (ប្រាំមួយ) ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ៥.០០០.០០១ (ប្រាំលានមួយ) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល ។

-១ (មួយ) ឆ្នាំ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ១០.០០០.០០១ (ដប់លានមួយ)រៀល ដល់ ២០.៥០០.០០០ (ម្ភៃលានប្រាំសែន) រៀល ។

-១៨ (ដប់ប្រាំបី) ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ២០.៥០០.០០១ (ម្ភៃលានប្រាំសែនមួយ) រៀល ដល់ ៥០.០០០.០០០ (ហាសិបលាន) រៀល ។

-២ (ពីរ) ឆ្នាំ ប្រសិនបើទឹកប្រាក់នេះមានចំនួនលើសពី ៥០.០០០.០០០ (ហាសិបលាន) រៀល ។

កាលណាការបង្ខំដល់រូបកាយធានាការប្រមូលឥណទេយ្យច្រើននោះ ថិរវេលានៃការបង្ខំនេះ ត្រូវកំណត់ដោយគិតគួរតាមចំនួនសរុបនៃទណ្ឌកម្ម ។

## ផ្នែកទី២ មូលហេតុទូទៅដែលនាំឲ្យមានផលប៉ះពាល់ដល់ការអនុវត្តទោស

កាលណាតុលាការប្រកាសទោស ទោសនោះត្រូវអនុវត្តទៅលើបុគ្គលដែលត្រូវទទួលរងទណ្ឌកម្ម និងធានាការអនុវត្តទោសនោះឱ្យបានត្រឹមត្រូវ ប៉ុន្តែនៅក្នុងនោះមានករណីមួយចំនួនដែលធ្វើឱ្យការអនុវត្តត្រូវបានបញ្ឈប់ទៅវិញដោយអានុភាពរបស់ច្បាប់ ។

### ១.អាជ្ញាយុកាលនៃទោស

អាជ្ញាយុកាលនៃទោស គឺជាអំឡុងពេលមួយដែលច្បាប់កំណត់អំពីភាពដែលអាចអនុវត្តទោសបាន ក្នុងនោះច្បាប់បានកំណត់អាជ្ញាយុកាលនៃទោសដូចខាងក្រោម ៖

-ចំពោះបទឧក្រិដ្ឋ ៖ ប្រសិនបើតុលាការប្រកាសទោសចំពោះបទឧក្រិដ្ឋ អាជ្ញាយុកាលនៃទោសគឺមានរយៈពេល ២០ ឆ្នាំ ។ មានន័យថាប្រសិនបើផុតរយៈពេល ២០ ឆ្នាំ បន្ទាប់ពីសេចក្តីសម្រេចផ្តន្ទាទោសក្លាយជាស្ថាពរ នោះទោសមិនអាចអនុវត្តបានទេ ។ ឧទាហរណ៍៖ បុគ្គល ក ត្រូវបានផ្តន្ទាទោស ដាក់ពន្ធនាគារ ១០ ឆ្នាំ ពីបទរំលោភសេពសន្ថវៈ ដោយសាលក្រមកំបាំងមុខ ។ សាលក្រមចូលជា ស្ថាពរនៅថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥ ។ ប្រសិនបើចន្លោះពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១០ រហូតដល់ថ្ងៃទី ០១ ខែ ១២ ឆ្នាំ ២០៣៥ មិនទាន់ចាប់បានជននេះទេ ជននោះត្រូវ រួចផុតពីការអនុវត្តទោសដោយមិន អាចចាប់ជននេះមកអនុវត្តបានទេ ព្រោះអាជ្ញាយុកាលនៃទោសត្រូវផុតរលត់ ។

-ចំពោះបទមជ្ឈិម ៖ ប្រសិនតុលាការប្រកាសទោសចំពោះបទមជ្ឈិម អាជ្ញាយុកាលនៃទោស មានរយៈពេល ៥ ឆ្នាំ ។ ឧទាហរណ៍ ៖ បុគ្គល ក ត្រូវចោទប្រកាន់ពីបទមនុស្សឃាតដោយអចេតនា ដែលត្រូវដាក់ពន្ធនាគារ ៣ ឆ្នាំ ។ សាលក្រមចូលជាស្ថាពរនៅថ្ងៃទី ០១-១២-២០១០ ។ ជននេះជាប់ ពន្ធនាគារបាន ២ ឆ្នាំ ក៏លួចរត់ចេញពីពន្ធនាគារថ្ងៃទី ០១-១២-២០១២ ។ ប្រសិនបើជននេះរត់គេចបានលើសពី ៣ ឆ្នាំ នោះគេមិនអាច

ចាប់ជននេះមកអនុវត្តទោសដែលនៅសល់ ១ ឆ្នាំ នោះបានឡើយ ព្រោះអាជ្ញាយុកាលត្រូវផុតរលត់ ។ ប៉ុន្តែជននេះត្រូវបានចោទប្រកាន់ពីបទល្មើសផ្សេង គឺការរត់ចេញពី ពន្ធនាគារ ។

-ចំពោះបទលហុ ៖ ប្រសិនបើតុលាការប្រកាសទោសចំពោះបទលហុ អាជ្ញាយុកាលនៃទោស មានរយៈពេល ១ ឆ្នាំ ។

ម្យ៉ាងវិញទៀត អាជ្ញាយុកាលនៃទោសត្រូវបានបង្កើតឡើងមក ដោយសារមានការយល់ឃើញថាក្នុងរយៈពេលនៃអាជ្ញាយុកាលនៃទោស ទណ្ឌិតប្រាកដជាក្លាយជាមនុស្សល្អ ដឹងខ្លួនខុស ប្រព្រឹត្តតែអំពើល្អ ពោលគឺទណ្ឌិតបានកែប្រែខ្លួនដោយស្វ័យប្រវត្តិរួចហើយ ហេតុដូច្នេះមិនមានការចាំបាច់ត្រូវធ្វើការបង្ខំយកទណ្ឌិតមកអនុវត្តទោសតទៅទៀតនោះឡើយ ។[46]

អាជ្ញាយុកាលនៃទោសត្រូវបានយកមកអនុវត្តទៅតាមដែនអនុវត្តអាជ្ញាយុកាលនៃទោស និងគិតទៅតាមរយៈពេលអាជ្ញាយុកាលនៃទោស។

### ១.១ ដែនអនុវត្តអាជ្ញាយុកាលនៃទោស

ជាក់ស្តែងនៅពេលផុតអាជ្ញាយុកាលហើយ ទោសលែងអនុវត្តបានទៀតហើយ[47] ។ បានន័យថានៅ អំឡុងពេលនៃការផ្តន្ទាទោសចូលជាស្ថាពរ ហើយចៅក្រមសម្រេចឲ្យជននោះជាប់ពន្ធនាគារ ប៉ុន្តែជននោះបាន គេចខ្លួនដោយរស់នៅក្នុងស្ថានភាពណាមួយ ដែលគ្មាននរណាដឹងរហូតដល់ផុតអាជ្ញាយុកាលនៃទោសដែលខ្លួន បានប្រព្រឹត្ត បើគិតចាប់តាំងពីពេលដែលជននោះបានប្រព្រឹត្តបទល្មើសបូករួមទាំងអាជ្ញាយុកាលនៃទោសដែលខ្លួន បានប្រព្រឹត្ត។ ដូច្នេះនៅពេលផុតអាជ្ញាយុកាលនៃទោសហើយ ទោសនោះមិនត្រូវបានយកមកអនុវត្តបានទៀតទេ ជននោះនឹងត្រូវបានរួចទោសហើយមានសិទ្ធិក្នុងការរស់នៅក្នុងសង្គមសារជាថ្មី។

ទោសអាចនឹងត្រូវផុតអាជ្ញាយុកាលបាន ដោយមិនចាំបាច់គិតពីប្រភេទនៃបទល្មើសនោះទេ។ ប៉ុន្តែនៅក្នុងនោះ មានបទល្មើសខ្លះគ្មានអាជ្ញាយុកាលនោះទេ ច្បាប់បានបញ្ញត្តិឲ្យបទល្មើសទាំងនោះ ពុំមានទាំងអាជ្ញាយុ កាលនៃទោស និងពុំមានទាំងអាជ្ញាយុកាលនៃបណ្តឹង។ ពិសេសចំពោះបទឧក្រិដ្ឋមួយចំនួន ដែលប្រកាសពីបទ ឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម មិនអាចផុតរលត់អាជ្ញាយុកាល ទេ[48]។ បើទោះជាជននោះបានប្រព្រឹត្តក្នុង អំឡុងពេលប៉ុន្មានក៏ដោយក៏ត្រូវតែទទួលបានការផ្តន្ទាទោសទៅតាម ច្បាប់ផងដែរ ដោយសារតែមានឥទ្ធិពល គ្រោះថ្នាក់ខ្លាំងក្លាដល់សង្គមទាំងមូល។ ម្យ៉ាងទៀត ក្រៅពីបទល្មើសខាង លើច្បាប់ពិសេសក៏អាចកំណត់អំពីភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោស ចំពោះបទឧក្រិដ្ឋ

[46] នីតិព្រហ្មទណ្ឌទូទៅ,លោកគ្រូ រុន ពណ្ណារិទ្ធ និងអ្នកគ្រូ ចាំង ស៊ីណាត
[47] មាត្រា១៤២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
[48] មាត្រា១៤៣ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ផ្សេងៗទៀត បានដូចគ្នា[49] ។

### ១.២. រយៈពេលអាជ្ញាយុកាលនៃទោស

រយៈពេលអាជ្ញាយុកាលនៃទោស ត្រូវចាប់ផ្តើមគិតពីថ្ងៃដែលសេចក្តីសម្រេចផ្តន្ទាទោសបានចូលជា ស្ថាពរ។ រយៈអាជ្ញាយុកាលនៃទោសមានដូចជា[50] ៖

ទោសដែលប្រកាសពី បទឧក្រិដ្ឋមានអាជ្ញាយុកាល ២០ (ម្ភៃ) ឆ្នាំ ។

ទោសដែលប្រកាសពី បទមជ្ឈិមមានអាជ្ញាយុកាល ៥ (ប្រាំ) ឆ្នាំ ។

ទោសដែលប្រកាសពី បទលហុមានអាជ្ញាយុកាល ១ (មួយ) ឆ្នាំ។

ដូច្នេះហើយ ប្រសិនបើហួសអាជ្ញាយុកាលនៃទោសខាងលើហើយ ទោសនោះនឹងរលត់ ហើយជនដែល ជាប់ទោសនោះនឹងមានសិទ្ធិសេរីភាពក្នុងការចូលទៅរស់នៅក្នុងសង្គមជាថ្មីម្តងទៀត។

## ២. ការបន្ធូរបន្ថយទោស និងការលើកលែងទោស

ការអនុគ្រោះទោសដោយការបន្ធូរបន្ថយទោស ឬការលើកលែងទោសដោយអនុលោមមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លើកលែងឲ្យទណ្ឌិតរួចផុតពីការអនុវត្តទោសដែលអនុគ្រោះនោះ[51]។

ការបន្ធូរបន្ថយទោស និងការលើកលែងទោសមានអត្ថន័យខុសគ្នា ពោលគឺការបន្ធូរបន្ថយទោស គឺជា ការកាត់បន្ថយទោសរបស់ទណ្ឌិតឲ្យនៅសល់រយៈពេលខ្លី និងឆាប់បញ្ចប់ទោសដែលទណ្ឌិតត្រូវអនុវត្ត ។ ការលើក លែងទោសមានពីរ គឺការលើកលែងទោសពីព្រះមហាក្សត្រ និងការលើកលែងទោសជាទូទៅ ។ ការលើកលែង ទោសពីព្រះមហាក្សត្រមានន័យថា គឺជាការបញ្ចប់ការអនុវត្តទោសក្នុងពន្ធនាគារដែលនៅសល់ ដោយមានការព្រះ រាជទានលើកលែងទោសពីព្រះមហាក្សត្រ រីឯការលើកលែងទោសជាទូទៅវិញ គឺសំដៅទៅលើការលើកលែង ទោសដល់ជនប្រព្រឹត្តឧក្រិដ្ឋជាក្រុមតាមរយៈច្បាប់អនុម័តរបស់សភា ។

ជាទូទៅទណ្ឌិតត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួនជាមុនសិន ទើបអាចទទួលបាននូវការបន្ធូរបន្ថយទោស ឬលើកលែងទោស ដែលអាចបញ្ចប់នូវការអនុវត្តដែលនៅសល់ ហើយទណ្ឌិតនឹងមានសេរីភាពសារជាថ្មីក្នុងការ ចូលទៅរស់នៅក្នុងសង្គមវិញ។

### ២.១. លក្ខខណ្ឌនៃការបន្ធូរបន្ថយទោស និងការលើកលែងទោស

ការបន្ធូរបន្ថយទោស និងការលើកលែងទោសចំពោះទណ្ឌិត ដែលជាប់ពន្ធនាគារតែងតែធ្វើឡើងជារៀងរាល់ឆ្នាំ ប៉ុន្តែទណ្ឌិតត្រូវអនុវត្តទោសរបស់ខ្លួននៅក្នុងពន្ធនាគារទៅតាមច្បាប់កំណត់ជាមុនសិន

[49] មាត្រា១៤៣ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[50] មាត្រា១៤៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[51] មាត្រា១៤៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ទើបអាចទទួល បានការបន្ធូរបន្ថយទោស និងការលើកលែងទោសទាំងនោះបាន ។ នីតិវិធីក្នុងការបន្ធូរបន្ថយទោស និងការលើក លែងទោសចំពោះទណ្ឌិត ក្នុងគោលបំណងដើម្បីធ្វើសមាហរណកម្មទណ្ឌិតនោះ ឲ្យចូលទៅរួមរស់ក្នុងសង្គមវិញ ឬក្នុងគោលបំណងផ្នែកមនុស្សធម៌[52] ។

ជាពិសេសការបន្ធូរបន្ថយទោស និងលើកលែងទោស ក៏អាចអនុវត្តចំពោះទណ្ឌិតដែលមានវ័យចាស់ជរា ជាស្រ្តីមានគភ៌ ឬមានជំងឺរ៉ាំរ៉ៃធ្ងន់ធ្ងរ វិបល្លាសស្មារតី ឬពិការភាព ដោយមានលិខិតបញ្ជាក់ពីគ្រូពេទ្យ ដែលទទួល ស្គាល់ដោយក្រសួងមានសមត្ថកិច្ច[53] ។ ចំពោះបញ្ហានេះ ប្រធានពន្ធនាគារគឺជាអ្នកធ្វើការបញ្ជាក់អំពី ស្ថានភាព ឬ លក្ខណៈរបស់ទណ្ឌិត ដោយបំពេញនូវលក្ខខណ្ឌនីមួយៗទៅតាមច្បាប់បានកំណត់ រួចស្នើសុំទៅ កាន់គណៈកម្ម ការរាជធានី-ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ ដើម្បីត្រួតពិនិត្យ។

បច្ចុប្បន្នការអនុវត្តនីតិវិធីការបន្ធូរបន្ថយទោស និងការលើកលែងទោសចំពោះទណ្ឌិត អាចប្រព្រឹត្តទៅ បានអាស្រ័យលក្ខខណ្ឌពីរ ដូចជាលក្ខខណ្ឌចរិកលក្ខណៈសម្បត្តិរបស់ទណ្ឌិត និង អាជ្ញាយុកាលកំណត់ក្នុងការ បន្ធូរបន្ថយ ទោស ។

### ២.១.១. លក្ខខណ្ឌនៃចរិតលក្ខណៈសម្បត្តិរបស់ទណ្ឌិត

ដើម្បីទទួលបាននូវការបន្ធូរបន្ថយទោស និងលើកលែងទោសទណ្ឌិតត្រូវបំពេញលក្ខខណ្ឌធំៗ ដូចខាង ក្រោមជាមុនសិនមានដូចជា ៖

- ភ្ញាក់រលឹកខិតខំកែប្រែគំនិតមាយាទឲ្យក្លាយជាពលរដ្ឋសុចរិត ដើម្បីធ្វើសមាហរណកម្មចូលរួមរស់ក្នុងសង្គមវិញ[54] ។ លុះត្រាតែទណ្ឌិតនោះចេះភ្ញាក់រឭក កែប្រែខ្លួនឲ្យក្លាយទៅជាមនុស្សល្អ និងបង្ហាញឲ្យឃើញថាខ្លួនមានគំនិតមាយាទល្អក្នុងរយៈពេលជាប់ឃុំ និងមានសម្បទាដែលអាចបញ្ចូលខ្លួនទៅក្នុង សង្គមវិញបាន ។

- គោរពប្រតិបត្តិបានយ៉ាងហ្មត់ចត់ និងត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ និងជាគំរូល្អ

- ដល់ ទណ្ឌិត និងជនជាប់ឃុំទៃទៀត[55] ។

- ចូលរួមអនុវត្តយ៉ាងសកម្ម និងទៀតទាត់នូវកម្មវិធីអប់រំកែប្រែ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្មវិធី សមាហរណកម្ម ដើម្បីជួយជំរុញដល់ទេពកោសល្យ និងជំនាញផ្សេងៗរបស់ជននោះឲ្យកាន់តែខ្លាំង និងងាយស្រួលក្នុងការយកទៅប្រកបមុខរបរពេលចេញទៅរស់នៅក្នុងសង្គមវិញ[56] ។

[52] ព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស, លេខ នស/រកត/០១២១/០៣០ មាត្រាទី១

[53] ព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស, លេខ នស/រកត/០១២១/០៣០ មាត្រាទី៦ កថាខណ្ឌទី១

[54] ព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស, លេខ នស/រកត/០១២១/០៣០ មាត្រាទី5 កថាខណ្ឌទី១ ចំណុចទី១

[55] ព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស, លេខ នស/រកត/០១២១/០៣០ មាត្រាទី៥ កថាខណ្ឌទី១ ចំណុចទី២

[56] ព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស,លេខ នស/រកត/០១២១/០៣០ មាត្រាទី៥ កថាខណ្ឌទី១ចំណុចទី៣

នៅពេលដែលទណ្ឌិតយល់ឃើញថា ខ្លួនបានបំពេញនៅលក្ខខណ្ឌដូចដែលមាននៅខាងលើ ក៏ប៉ុន្តែមិនបានត្រូវប្រធានពន្ធនាគារធ្វើការស្នើសុំឲ្យខ្លួនទេ នោះទណ្ឌិតមានសិទ្ធិប្តឹងតវ៉ាទៅ គណៈកម្មការថ្នាក់ជាតិដោយមានការគាំទ្រពីក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគារ[57] ។

### ២.១.២ អាជ្ញាយុកាលកំណត់ក្នុងការបន្ធូរបន្ថយទោស

រយៈពេលនៃការបន្ធូរបន្ថយទោស ឬការលើកលែងទោសអាចអនុញ្ញាតទៅបាន លុះត្រាតែទណ្ឌិតបាន អនុវត្តទោសដាក់ពន្ធនាគារទៅតាមរយៈពេលណាមួយ ដែលច្បាប់បានកំណត់ជាមុនសិន ។ ចំពោះទណ្ឌិត ដែល បានជាប់ទោសដាក់ពន្ធនាគារ ទាក់ទងនឹងចិរវេលានៃទោសក្នុងការបន្ធូរបន្ថយ និងការលើកលែងទោសមានដូចជា[58] ៖

- ករណីបន្ធូរបន្ថយទោសលុះត្រាតែទណ្ឌិតទាំងនោះ បានទទួលទោសមួយភាគបី (១/៣) នៃទោស ដាក់ពន្ធនាគារមានកំណត់ ឬទទួលទោស០៧ ឆ្នាំចំពោះទោសដាក់ពន្ធនាគារមួយជីវិត។
- ករណីលើកលែងទោសលុះត្រាតែទណ្ឌិតទាំងនោះបានទទួលទោសចំនួនពីរភាគបី (២/៣) នៃទោស ដាក់ពន្ធនាគារមានកំណត់ ឬទទួលទោស ១៥ ឆ្នាំចំពោះទោសដាក់ពន្ធនាគារមួយជីវិត។

ជាងនេះទៅទៀត ការបន្ធូរបន្ថយទោសចំពោះទណ្ឌិតមានអាជ្ញាយុកាលខុសៗគ្នា ដែលត្រូវបានកំណត់ដូចខាងក្រោម[59] ៖

- ចំពោះទោសដែលកំណត់ចាប់ពី ០១ (មួយ) ឆ្នាំដល់ ១០ (ដប់) ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ ពន្ធនាគារបានចំនួន ០៦ (ប្រាំមួយ) ខែម្តងក្នុងរយៈពេលមួយឆ្នាំ។
- ចំពោះទោសដែលកំណត់ចាប់ពី ១០ (ដប់) ឆ្នាំដល់ ១៥ (ដប់ប្រាំ) ឆ្នាំ អាចនឹងបន្ថយរយៈពេល ជាប់ពន្ធនាគារបានចំនួន ០៩ (ប្រាំបួន) ខែម្តងក្នុងរយៈពេលមួយឆ្នាំ។
- ចំពោះទោសដែលកំណត់ចាប់ពី ១៥ (ដប់ប្រាំ) ឆ្នាំដល់ ២០ (ម្ភៃ) ឆ្នាំ អាចនឹងបន្ថយរយៈពេល ជាប់ពន្ធនាគារបានចំនួន ១២ (ដប់ពីរ) ខែម្តងក្នុងរយៈពេលមួយឆ្នាំ។

ទណ្ឌិតម្នាក់អាចទទួលការបន្ធូរបន្ថយទោសច្រើនដងបានតែក្នុងលក្ខខណ្ឌដែលទណ្ឌិតនោះបានទទួលរងទោសទាំងអស់បានពាក់កណ្តាលនៃទោសដែលតុលាការបានកំណត់ ហើយការកំណត់ចំពោះទោសដាក់

---

[57] ច្បាប់ស្តីពីពន្ធនាគារ ,នស/រកម/១២១១/០២១ អនុម័តថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១១ មាត្រា៧៦

[58] ព្រះរាជក្រឹត្យលេខ ២៨ក្រ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៨៨ មាត្រា៣ និងមាត្រា៤

[59] ព្រះរាជក្រឹត្យលេខ ២៨ក្រ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៨៨ មាត្រា៣ និងមាត្រា៤

ពន្ធនាគារមួយជីវិតអនុញ្ញាតអាចនឹងបន្ថយទោសលើកទី១ មកត្រឹម ២០ ឆ្នាំហើយអាចបន្ធូរបន្ថយទោសច្រើនដង ទៀតបានប៉ុន្តែបើទោះបីជាទណ្ឌិតនោះត្រូវបន្ធូរបន្ថយទោសច្រើនដងក៏ដោយក៏រយៈពេលនៃការទទួលទោសក្នុង ពន្ធនាគារទាំងអស់ត្រូវអនុវត្តទោសឲ្យបាន ១៥ ឆ្នាំសិនដែរ ។

ចំពោះទណ្ឌិត ដែលមិនបានអនុវត្តទោសដូចលក្ខខណ្ឌខាងលើក៏អាចទទួលបានការលើកលែងទោសដែរ ប៉ុន្តែក្នុងករណីនេះមិនសូវកើតមានទេព្រោះលក្ខខណ្ឌតឹងរ៉ឹងពេក។ ប៉ុន្តែក្នុងករណីចាំបាច់ប្រមុខរាជរដ្ឋាភិបាលមាន បុព្វសិទ្ធិធ្វើសំណើថ្វាយព្រះមហាក្សត្រសុំលើកលែងទោសឲ្យទណ្ឌិតនៅពេលណាក៏បាន[60] ។ ករណីនេះទណ្ឌិត អាចលើកលែងទោសបានដោយមិនគោរពនូវលក្ខខណ្ឌខាងលើក៏បានដែរ ក៏ប៉ុន្តែទាល់តែជាករណីចាំបាច់ហើយ មានសំណើពីប្រមុខរាជរដ្ឋាភិបាលថ្វាយទៅព្រះមហាក្សត្រ និងអាចធ្វើបានគ្រប់ពេលវេលាដោយមិនចាំបាច់រង់ចាំ ដល់ពេលមានបុណ្យជាតិធំៗនោះទេ។

វិធីបុណ្យជាតិធំៗ ដែលអាចឲ្យទណ្ឌិតទទួលបានការបន្ធូរបន្ថយទោស និងការលើកលែងទោសបានមានដូចជា [61]៖

១- បុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ

២- បុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ

៣- បុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែ

៤- បុណ្យឯករាជ្យជាតិ

៥- បុណ្យវិសាខបូជាជាដើម ។

ម្យ៉ាងទៀតការបន្ធូរបន្ថយទោស និងការលើកលែងទោស ក៏អាចធ្វើសម្រាប់ពីធីបុណ្យនីមួយៗ ខាងលើដាច់ដោយឡែកពីគ្នា ឬរួមគ្នាផងដែរ ។

### ២.២. នីតិវិធីក្នុងការបន្ធូរបន្ថយទោស និងលើកលែងទោស

ការលើកលែងទោស និងការបន្ធូរបន្ថយទោស អាចធ្វើឡើងបានអាស្រ័យទៅនឹងលក្ខណៈសម្បត្តិ និង លក្ខខណ្ឌជាច្រើនដែលទណ្ឌិតបានបំពេញ និងអនុវត្តតាមដូចបានបង្ហាញនៅខាងផ្នែកលើ ។ ពិធីបុណ្យលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបន្ធូរបន្ថយទោស និងការលើកលែងទោសត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

ចំពោះនីតិវិធីការបន្ធូរបន្ថយទោស និងការលើកលែងទោសវិញ ដំបូងប្រធានពន្ធនាគារជាអ្នករៀបចំ និង ពិនិត្យមើលបញ្ជីឈ្មោះ ទណ្ឌិតដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ស្របទៅតាមលក្ខខណ្ឌ ដែលច្បាប់បានកំណត់ បន្ទាប់មកប្រធានពន្ធនាគារបញ្ជូនឯកសារពាក់ព័ន្ធទាក់ទងនឹងទណ្ឌិត ស្នើសុំទៅកាន់គណៈ

[60] ច្បាប់ស្តីពីពន្ធនាគារ ,នស/រកម/១២១១/០២១ អនុម័តថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១១ មាត្រា៧៧

[61] ព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស, លេខ នស/រកត/០១២១/០៣០ មាត្រាទី៣

កម្មាការរាជធានី-ខេត្ត និងកម្មាការក្រសួងមហាផ្ទៃ។ គណៈកម្មាការរាជធានី-ខេត្ត និងគណៈកម្មាការក្រសួងមហាផ្ទៃ និងធ្វើការត្រួតពិនិត្យហើយវាយតម្លៃ លើឯកសារទាំងនោះ និងត្រូវរៀបចំបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងការលើកលែង ទោស រួមនិងសំណុំឯកសារពាក់ព័ន្ធបញ្ជូនទៅកាន់គណៈកម្មាការថ្នាក់ជាតិ ដើម្បីពិនិត្យ និងវាយតម្លៃបន្ថែមទៅលើ បញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និង ការលើកលែងទោស យ៉ាងយឺតបំផុត ៣០ (សាមសិប) ថ្ងៃមុនថ្ងៃកំណត់[62] ។

ម្យ៉ាងទៀត រាល់ឯកសារដែលពាក់ព័ន្ធនឹងការស្នើសុំនោះ ត្រូវបានបញ្ជូនទៅដល់ប្រមុខរាជរដ្ឋាភិបាល ដើម្បីត្រួតពិនិត្យបន្ថែមសាជាថ្មីម្តងទៀត មុននឹងសម្រេចដាក់សំណើថ្វាយព្រះមហាក្សត្រសុំបន្ធូរបន្ថយទោស និងលើកលែងទោសឲ្យទណ្ឌិតយ៉ាងយឺតបំផុត ១០ (ដប់) ថ្ងៃមុនថ្ងៃកំណត់[63] ។

ជាងនេះទៅទៀត ចំពោះទណ្ឌិតដែលត្រូវបានបន្ធូរបន្ថយទោសដោយព្រះរាជក្រឹត្យ និងលើកលែងឲ្យទណ្ឌិត នោះរួចផុតពីការអនុវត្តទោស សម្រាប់រយៈពេលដែលត្រូវបានបន្ធូរបន្ថយ ហើយព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី-ខេត្តដែលមានសមត្ថកិច្ច និងប្រធានពន្ធនាគារ ត្រូវធ្វើការប្រកាសផ្សព្វផ្សាយព្រះរាជក្រឹត្យ បន្ធូរបន្ថយទោស ដល់ទណ្ឌិតដែលត្រូវបានបន្ធូរបន្ថយទោសនោះ ។ ការផ្សព្វផ្សាយព្រះរាជក្រឹត្យនេះដល់ទណ្ឌិត គឺដើម្បីឲ្យទណ្ឌិតបានដឹងមុន និងងាយស្រួលក្នុងការរៀបចំខ្លួនមុនពេលត្រូវបានដោះលែង។ ចំណែកឯ ការបន្ធូរបន្ថយទោស និងលើកលែងទោស មិនមែនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលសំណងជួសជុល ការខូចខាតនោះទេ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយនឹងព្រះរាជក្រឹត្យដែលពាក់ព័ន្ធនឹងការបន្ធូរបន្ថយ និងការលើកលែងនោះ[64] ។

ដូច្នេះ ការអនុវត្តការបន្ធូរបន្ថយទោស និងការលើកលែងទោស នៅតែប្រព្រឹត្តប្រសិនបើទណ្ឌិតបានអនុវត្ត តាមលក្ខខណ្ឌដែលច្បាប់បានកំណត់ ។

### ៣. ការលើកលែងទោសជាទូទៅ

ការលើកលែងទោសជាទូទៅ គឺជាសិទ្ធិផ្តាច់មុខរបស់អង្គការនីតិបញ្ញត្តិ (រដ្ឋសភា) ដូចមានចែងក្នុងមាត្រា ៩០នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ២៤ កញ្ញា ១៩៩៣ ។

ក្នុងនោះការលើកលែងទោសជាទូទៅដូចមានចែងក្នុងមាត្រា ៩០ ថ្មី (ពីរ) វាក្យខណ្ឌទី៤ នៃរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជាលុបបំបាត់ចោលនូវទណ្ឌកម្មដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីការលើកលែងទោសជា

[62] ច្បាប់ស្តីពីពន្ធនាគារ ,នស/រកម/១២១១/០២១ អនុម័តថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១១ មាត្រា៧៤

[63] ព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស, លេខ នស/រកត/០១២១/០៣០ មាត្រាទី១៣

[64] ព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស, លេខ នស/រកត/០១២១/០៣០ មាត្រាទី១៧

ទូទៅ[65] ។ ម្យ៉ាងវិញទៀតនៅពេលដែលច្បាប់ស្តីពីការលើកលែងទោសជាទូទៅចូលជាធរមានហើយ នោះការលើកលែង ទោសជាទូទៅត្រូវមានអានុភាពនៃការលើកលែងទោសជាទូទៅ ដែលនាំឲ្យមានការលុបចោលការសម្រេចទាំងស្រុង ។ បានន័យថា ប្រសិនបើការផ្តន្ទាទោសចូលជាស្ថាពរហើយ ក៏ទោសនោះមិនអាចយកមកអនុវត្តឡើយ[66] ។ ម្យ៉ាងវិញទៀត បើទណ្ឌិតកំពុងតែអនុវត្តទោសក្នុងពន្ធនាគារ ទោសដែលកំពុងអនុវត្តត្រូវបានបញ្ចប់ មានន័យថា ទណ្ឌិតនឹងត្រូវទទួលបានការដោះលែងឱ្យមានសេរីភាពវិញភ្លាមៗ [67] ។

[65] មាត្រា ១៤៩ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ

[66] មាត្រា ១៤៩ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ

[67] មាត្រា ១៤៩ កថាខណ្ឌទី៣ នៃក្រមព្រហ្មទណ្ឌ

# សេចក្តីសន្និដ្ឋាន

តាមរយៈការបកស្រាយខាងលើរួចមកយើងអាចសន្និដ្ឋានបានថា របបគតិយុត្តិនៃទោសដែល ត្រូវអនុវត្តពិតជាមានសារៈសំខាន់ក្នុងវិស័យយុត្តិធម៌ ដោយការអនុវត្តទាំងឡាយត្រូវគោរពតាមបែប បទដែលមានចែងក្នុងច្បាប់ ។ ថ្វីត្បិតតែទោសវាជាវិធានការដ៏តឹងរឹងរបស់រដ្ឋ ប៉ុន្តែគោលបំណងដែលរដ្ឋចង់បានគឺដើម្បីឱ្យសង្គមមានស្ថេរភាពសណ្តាប់ធ្នាប់ល្អ និងការអភិវឌ្ឍន៍ ដោយបញ្ចៀសនូវបទល្មើស ទាំងឡាយកុំឱ្យកើតមានបន្តទៅទៀត ។ ចំពោះវិធានការនេះថ្វីត្បិតតែលទ្ធផល ដែលទទួលបានមិនល្អ ឥតខ្ចោះ ប៉ុន្តែវាក៏អាចទប់ស្កាត់បានមួយផ្នែកធំនូវបទល្មើស។ ឧទាហរណ៍ ៖ ក្នុងច្បាប់បានចែងថាអំពើ សំលាប់មនុស្សត្រូវមានទោស ។ ប៉ុន្តែនៅក្នុងសង្គមយើងសង្កេតឃើញថាអំពើនេះនៅតែមានកើតឡើង ក្នុងន័យនេះបានសេចក្តីថា ថ្វីត្បិតតែអំពើមួយចំនួនច្បាប់ចែងថាជាបទល្មើសដែលត្រូវផ្តន្ទាទោស ប៉ុន្តែអានុភាពរបស់វាអាចទប់ស្កាត់បានមួយផ្នែកលើសតិអារម្មណ៍របស់ជន ដែលបំរុងនឹងប្រព្រឹត្តបទ ល្មើសអាចផ្លាស់ប្តូរចិត្តគំនិត ដោយកសាងនូវអំពើល្អវិញ ។

ក្នុងការដាក់ទណ្ឌកម្ម តុលាការត្រូវគោរពនូវព្រំដែននៃអប្បបរមា និងអតិបរមាព្រមទាំងស្ថានភាពមួយចំនួនជាអាទិ៍ ក្នុងករណីស្ថានសម្រាលទោស ស្ថានទម្ងន់ទោស ចំពោះនីតិជន អនីតិជននីតិ បុគ្គល ដោយត្រូវអនុវត្តឱ្យបានត្រឹមត្រូវជៀសវាងការរំលោភសិទ្ធផ្សេងៗរបស់បុគ្គលទាំងនោះ។

ទន្ទឹមនឹងនេះផងដែរ ការយកទោសទៅអនុវត្តលើជនល្មើសឬនីតិបុគ្គលដំបូងយើងឃើញថា បណ្តាបុគ្គលទាំងអស់ដែលទទួលរងនូវទណ្ឌកម្មមិនគួរឱ្យចូលខ្លួនមករស់នៅក្នុងសង្គមវិញ ឬបន្តនូវ សកម្មភាពរបស់ខ្លួនទេ ប្រសិនទណ្ឌកម្មដែលទទួលរងមិនទាន់ចប់សព្វគ្រប់ ប៉ុន្តែដើម្បីស្តាសង្គមឡើង វិញ រដ្ឋអាចបញ្ចូលខ្លួនទណ្ឌិតអោយចូលរួមសកម្មភាពសង្គមដោយអនុញ្ញាតឱ្យមានសេរីភាពខ្លះ ឬ អនុញ្ញាតឱ្យនីតិបុគ្គលមានសិទ្ធបន្តសកម្មភាពរបស់ខ្លួនដែលការអនុញ្ញាតនោះមានក្រោមរូបភាពដូចជា ការអនុវត្តនូវរបបពាក់កណ្តាលសេរីភាព ឬការព្យួរទោស របបការបែងទោសជាប្រភាគ ឬ ការចាត់ វិធានការរៀបចំនឹងលុបចោលនូវទោសបន្ថែមខ្លះ ដែលនេះជាវិធានអនុគ្រោះដែលជាប្រយោជន៍ដល់ ទណ្ឌិតនិងនីតិបុគ្គលទទួលបាន ។ម្យ៉ាងវិញទៀតចំពោះសិទ្ធរបស់ទណ្ឌិតក្នុងការស្នើសុំឱ្យលើកលែង ទោស ឬបន្ធូរបន្ថយទោសត្រូវបានអនុញ្ញាតដោយរដ្ឋធម្មនុញ្ញ ដែលបញ្ហាទាំងនេះទណ្ឌមានសិទ្ធិពេញ ច្បាប់ក្នុងការស្នើសុំដោយត្រូវគោរពតាមបែបបទដែលមានចែងក្នុងច្បាប់ ។
មួយវិញទៀតទណ្ឌិតអាចត្រូវបានអនុគ្រោះដោយអានុភាពរបស់ច្បាប់ ដូចជាច្បាប់ស្តីពីការ លើកលែងទោសជាទូទៅជាដើមដោយទណ្ឌិតមួយចំនួនដែលកំពុងរងនូវទណ្ឌកម្មក្នុងពន្ធនាគារអាចរួចផុតពីទណ្ឌកម្មទាំងនេះបាន ។

# អនុសាសន៍

បន្ទាប់ពីការបកស្រាយនូវប្រធានបទខាងលើនេះរួចមកយើងឃើញថាថក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មានយន្តការច្រើនក្នុងការអនុវត្ត និងប្រកាសទោសព្រហ្មទណ្ឌ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសដូចមានចែង នៅក្នុងក្រមព្រហ្មទណ្ឌ។ បន្ថែមពីនេះ ប្រភេទនៃទោសដែលក្រមព្រហ្មទណ្ឌបានចែងមាន មូលទោស ទោសបន្ថែម និងទោសជំនួស ដែលប្រភេទនៃទោសទាំងបីនេះមានលក្ខខណ្ឌ និងនិតិវិធីក្នុងការអនុវត្តខុសៗគ្នាអាស្រ័យទៅ លើទម្ងន់នៃទោសដែលជនល្មើសបានប្រព្រឹត្ត។ ក្រមព្រហ្មទណ្ឌក៏បានបញ្ញត្តិអំពីផ្សេងៗដែលអាចនាំឲ្យមានផល ប៉ះពាល់ដល់ការអនុវត្តទោស ដូចជាការព្យួរទោស ការបន្ធូរបន្ថយទោស ការលើកលែងទោស និងកត្តាគតិយុត្ត មួយចំនួនទៀត ដែលត្រូវបានប្បញ្ញត្តិឡើងដែលមានលក្ខណៈងាយស្រួលដល់ទណ្ឌិត។ ហេតុនេះហើយ ទើបយន្ត ការផ្សេងៗទៀតមិនសូវបានយកទៅអនុវត្ត និងនាំឲ្យមានកំណើនទណ្ឌិតនៅក្នុងពន្ធនាគារច្រើនលើសលប់ដែល នាំឲ្យមានផលពិបាកជាច្រើនដល់រដ្ឋ។ ចំពោះបណ្តាទាំងនេះ តុលាការបានប្រើប្រាស់ទោសជំនួស (ទោសការងារសហគមន៍ និងការស្តីបន្ទោស) មកអនុវត្តដែលជួយសម្រួលដល់បញ្ហា ស្ថានភាព ទីកន្លែង ពេលវេលា និងថវិកា ក្នុងការជួលមនុស្សឲ្យឃ្លាំមើលជាដើម។

គួរបញ្ជាក់ផងដែរថា ទោះបីជាច្បាប់បានចែងយ៉ាងលំអិតអំពីទោសទណ្ឌកម្មចំពោះអ្នកដែលបានប្រព្រឹត្តបទល្មើសក៏ដោយ អ្វីដែលសំខាន់ គឺការយកទៅអនុវត្តផ្ទាល់ និងការផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋទូទាំងប្រទេសឲ្យបានយល់កាន់តែស៊ីជម្រៅទាក់ទងនឹងច្បាប់ព្រហ្មទណ្ឌ ក៏ដូចជាច្បាប់ផ្សេងៗផងដែល។ ដើម្បីឲ្យពួកគាត់ចេះទទួល កំហុសដែលខ្លួនបានធ្វើ និងព្រមចូលខ្លួនមកអនុវត្តទោសទៅតាមទំហំនៃអំពើដែលខ្លួនបានល្មើស។ ដើម្បីរួម ចំណែកធ្វើឲ្យវិស័យតុលាការនៃព្រះរាជាណាចក្រកម្ពុជាកាន់តែមានប្រសិទ្ធភាពនោះ យើងខ្ញុំជានិស្សិតសរសេរ សារណា សូមចូលរួមផ្តល់ជាអនុសាសន៍មួយចំនួនដូចជា ៖

- ចៅក្រមត្រូវតែរក្សាភាពមិនលំអៀង ប្រកាននៅជំហរ និងសមត្ថកិច្ចរបស់ខ្លួន ក្នុងការវិនិច្ឆ័យមុននឹងប្រកាសសេចក្តីសម្រេច។
- ពង្រឹងការអនុវត្តនីតិវិធីទៅតាមដំណាក់កាល និងធានាការជំនុំជម្រះក្តីដោយយុត្តិធម៌ និងលុបបំបាត់ចោលនូវអំពើពុករលួយ ដែលមាននៅក្នុងវិស័យតុលាការ។
- ពង្រឹងការផ្សព្វផ្សាយច្បាប់ដល់ប្រជាពលរដ្ឋ ឲ្យយល់ដឹងបន្ថែមអំពីការអនុវត្តច្បាប់

ជាចុងក្រោយ ប្រសិនបើប្រទេសមួយមានច្បាប់ល្អ ហើយប្រជាពលរដ្ឋបានយល់ដឹងពីតម្លៃ និងអនុវត្តទៅតាមការបទបញ្ញត្តដែលមានចែង ប្រទេសនោះនឹងមានតែសុខសន្តិភាព ហើយការអភិវឌ្ឍននឹងកាន់តែមានភាពរីក ចម្រើន ព្រមជាមួយនឹងការស្ញប់ស្ញែង កោតសរសើរពីបណ្តាប្រទេសដទៃទៀតនៅលើពិភពលោក។

# ឯកសារយោង

# ឯកសារយោង

## ១. លិខិតបទដ្ឋានគតិយុត្ត

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០២០៨/០០៨ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ។

២. ព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស, លេខ នស/រកត/០១២១/០៣០ ។

៣. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ។

៤. ច្បាប់ស្តីពីពន្ធនាគារប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ។

៥. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២១១.០២១ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

៦. ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ ។

## ២. ឯកសារស្រាវជ្រាវ

១. នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ, កែសម្រួលដោយលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត បោះពុម្ភ ឆ្នាំ២០១២ ។

២. មេរៀននីតិព្រហ្មទណ្ឌ អត្ថបទនៃសេចក្តីព្រាងព្រហ្មទណ្ឌ រៀបចំដោយ សហប្រតិបត្តិការបារាំងគម្រោងទ្រទ្រង់នីតិរដ្ឋ ឆ្នាំ២០០៧ ។

៣. ទោសព្រហ្មទណ្ឌ រៀបរៀង និងវាយអត្ថបទដោយ លោកមេធាវី កៅ សីហា បណ្ឌិតច្បាប់ និងជាសាស្ត្រា-ចារ្យច្បាប់ ។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ១

# ច្បាប់

# ស្តីពី

# ពន្ធនាគារ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ព្រះរាជក្រម

នស/រកម/១២១១/០២១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**ជាតិសាសនា រក្សាខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ទទួល
លេខ ០០១
ថ្ងៃទី ឆ្នាំ២០១ ម៉ោង
បញ្ជូនទៅ

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីពន្ធនាគារ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី២ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលបំណងកំណត់អំពីការគ្រប់គ្រងពន្ធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះ មានគោលដៅដូចតទៅ :

- អប់រំ កែប្រែ ស្តារនីតិសម្បទា ដើម្បីធ្វើសមាហរណកម្មជនជាប់ឃុំទៅក្នុងសង្គមវិញ និង ទប់ស្កាត់ការប្រព្រឹត្តបទល្មើសសាជាថ្មី
- គ្រប់គ្រងជនជាប់ឃុំឲ្យជានាបានសន្តិសុខ សុវត្ថិភាព សុខភាព និង មនុស្សធម៌ ស្រប តាមគោលការណ៍អន្តរជាតិ និង វិធានសហប្រជាជាតិ សម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសិទ្ធិសេរីភាព ។

**មាត្រា ៣.-**

ច្បាប់នេះ មានវិសាលភាពអនុវត្តលើពន្ធនាគារទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែពន្ធនាគារយោធា ឬកន្លែងឃាត់ខ្លួនរបស់នគរបាលយុត្តិធម៌ ឬមណ្ឌលឃុំខ្លួនដទៃទៀត ដែលកំណត់ដោយច្បាប់ផ្សេង ។

**មាត្រា ៤.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ :

**ពន្ធនាគារ** សំដៅដល់កន្លែងប្រើសម្រាប់ធ្វើការឃុំឃាំងជនជាប់ឃុំតាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុលាការ រួមមានមណ្ឌលឃុំខ្លួន និងមណ្ឌលអប់រំកែប្រែផង ។

**អនីតិជន** សំដៅដល់បុគ្គលទាំងឡាយណា ដែលមានអាយុចាប់ពី ១៤ ឆ្នាំ ឡើង ដល់ក្រោម ១៨ ឆ្នាំ ។

**ជនជាប់ឃុំ** សំដៅដល់ជនត្រូវចោទ ឬជនជាប់ចោទ ឬពិរុទ្ធជន ឬទណ្ឌិតដែលត្រូវបានបញ្ជូនមកឃុំខ្លួននៅក្នុងពន្ធនាគារ តាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុលាការ ។

**មន្ត្រីពន្ធនាគារ** សំដៅដល់មន្ត្រីដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ។

**មន្ត្រីពេទ្យពន្ធនាគារ** សំដៅដល់មន្ត្រីដែលត្រូវបានតែងតាំងឲ្យផ្តល់សេវាថែទាំសុខភាពជនជាប់ឃុំក្នុងពន្ធនាគារ និងត្រូវបានទទួលស្គាល់ ឬបានចុះបញ្ជីជាគ្រូពេទ្យ ឬមន្ត្រីពេទ្យនៅក្រសួងសុខាភិបាល ។

**អ្នកសួរសុខទុក្ខ** សំដៅដល់ជនដែលត្រូវបានអនុញ្ញាតឲ្យចូលក្នុងពន្ធនាគារ ដើម្បីសួរសុខទុក្ខ ឬផ្តល់ជំនួយដល់ជនជាប់ឃុំ ។

**អ្នកសួរសុខទុក្ខផ្លូវការ** សំដៅដល់មន្ត្រីសាធារណៈ ឬតំណាងបុគ្គលមកពីអង្គការនានា ដែលទទួលបានការអនុញ្ញាតឲ្យទៅធ្វើទស្សនកិច្ចឃ្លាំមើលតាមពន្ធនាគារនានា ឬផ្តល់ជំនួយដល់ជនជាប់ឃុំ ។

**យន្តការបង្ការថ្នាក់ជាតិ** សំដៅដល់យន្តការឯករាជ្យមួយ ស្របតាមពិធីសារបន្ថែមស្តីពីការបង្ការអំពើទារុណកម្ម អំពើឃោរឃៅអមនុស្សធម៌ ឬបន្ថាបបន្ថោក ។

## ជំពូកទី ២
## សមត្ថកិច្ចគ្រប់គ្រង

### មាត្រា ៥.-

ក្រសួងមហាផ្ទៃជាស្ថាប័នមានសមត្ថកិច្ច ក្នុងការគ្រប់គ្រងពន្ធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### មាត្រា ៦.-

អគ្គនាយកដ្ឋានពន្ធនាគារជាសេនាធិការឲ្យក្រសួងមហាផ្ទៃ ក្នុងការគ្រប់គ្រងពន្ធនាគារ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានពន្ធនាគារ ត្រូវកំណត់ដោយអនុក្រឹត្យ ។

### មាត្រា ៧.-

មន្ត្រីពន្ធនាគារត្រូវស្ថិតក្រោមលក្ខន្តិកៈដោយឡែក ដែលត្រូវកំណត់ដោយព្រះរាជក្រឹត្យ ស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ៨.-

មន្ត្រីពន្ធនាគារមានឯកសណ្ឋាន សញ្ញាសក្តិ គ្រឿងបំពាក់ ឧបករណ៍ និងសម្ភារៈការពារសមស្រប ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ៩.-**

ក្រសួងមហាផ្ទៃ ត្រូវធ្វើប្រតិភូកម្មមុខងារឲ្យរដ្ឋបាលរាជធានី ខេត្ត ក្នុងការគ្រប់គ្រងពន្ធនាគាររាជធានី ខេត្ត ។

ពន្ធនាគាររាជធានី ខេត្ត ស្ថិតក្រោមការគ្រប់គ្រងរបស់គណៈអភិបាលរាជធានី ខេត្ត ។

## ជំពូកទី ៣
## ហេដ្ឋារចនាសម្ព័ន្ធពន្ធនាគារ

**មាត្រា ១០.-**

ហេដ្ឋារចនាសម្ព័ន្ធរបស់ពន្ធនាគារត្រូវគោរពតាមបទដ្ឋានអប្បបរមា សម្រាប់ការសាងសង់ពន្ធនាគារ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១១.-**

អគារ និងបន្ទប់ឃុំឃាំង ត្រូវមានពន្លឺគ្រប់គ្រាន់ មានខ្យល់ធម្មជាតិ មានបន្ទប់អនាម័យ មានប្រព័ន្ធផ្គត់ផ្គង់ទឹក និងអគ្គិសនីសម្រាប់ប្រើប្រាស់ ។

**មាត្រា ១២.-**

ពន្ធនាគារត្រូវមានប៉ុស្តិ៍សុខភាព មានបន្ទប់សម្រាកព្យាបាលជនជាប់ឃុំ និងត្រូវមានមន្ត្រីពេទ្យពន្ធនាគារបម្រើការងារជាប្រចាំ ។

សេវាសុខាភិបាលពន្ធនាគារត្រូវស្ថិតក្រោមការគ្របដណ្តប់របស់ក្រសួងសុខាភិបាល ។

**មាត្រា ១៣.-**

ពន្ធនាគារត្រូវមានកន្លែងសម្រាប់គោរពជំនឿសាសនា មានបណ្ណាល័យ និងអគារអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា ១៤.-**

ពន្ធនាគារត្រូវរៀបចំឲ្យមានកន្លែងហាត់ប្រាណសម្រាប់ជនជាប់ឃុំ ។

**មាត្រា ១៥.-**

ពន្ធនាគារត្រូវមានកន្លែងធ្វើការ និងផ្ទះមុខងារ សម្រាប់មន្ត្រីពន្ធនាគារក្នុងអំឡុងពេលនៃការបំពេញមុខងាររបស់ខ្លួន ។

**មាត្រា ១៦.-**

ការបង្កើត ការដាក់ឈ្មោះ ការកំណត់ទីតាំង ការកំណត់ចំនួនជនជាប់ឃុំ ការផ្លាស់ប្តូរឈ្មោះ ការផ្លាស់ប្តូរទីតាំង និងការរំលាយពន្ធនាគារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៤
## ការឃុំឃាំង

**មាត្រា ១៧.-**

ការទទួល ឬការឃុំខ្លួនជនណាម្នាក់នៅក្នុងពន្ធនាគារបាន លុះត្រាតែមានលិខិតឃុំខ្លួនដែលចេញពីអាជ្ញាធរតុលាការ ។

**មាត្រា ១៨.-**

មុនពេលទទួលយកជនជាប់ឃុំចូលក្នុងពន្ធនាគារ ប្រធានពន្ធនាគារ ឬមន្ត្រីពន្ធនាគារដែលបានទទួលការចាត់តាំង ត្រូវត្រួតពិនិត្យអត្តសញ្ញាណរបស់ជនជាប់ឃុំឱ្យបានត្រឹមត្រូវ តាមលិខិតឃុំខ្លួនដែលចេញដោយអាជ្ញាធរតុលាការ ។

**មាត្រា ១៩.-**

មន្ត្រីពេទ្យពន្ធនាគារត្រូវពិនិត្យសុខភាពជនជាប់ឃុំ មុននឹងទទួលយកចូលក្នុងពន្ធនាគារ ដោយត្រូវកត់ត្រាបញ្ចូលក្នុងកំណត់ហេតុនូវព័ត៌មានអំពីស្ថានភាពសុខភាពរបស់ជនជាប់ឃុំ ។

**មាត្រា ២០.-**

បន្ទាប់ពីទទួលយកជនជាប់ឃុំចូលក្នុងពន្ធនាគារ មន្ត្រីពន្ធនាគារត្រូវណែនាំដល់ជនជាប់ឃុំអំពីច្បាប់ បទបញ្ជាផ្ទៃក្នុងពន្ធនាគារ សិទ្ធិស្វែងរកអ្នកតំណាងផ្លូវច្បាប់ សិទ្ធិផ្តល់ដំណឹងទៅគ្រួសារ ឬសាច់ញាតិ ឬស្ថាប័នពាក់ព័ន្ធផ្សេងៗ អំពីការជាប់ពន្ធនាគារ និងទីតាំងនៃពន្ធនាគារ ព្រមទាំងសិទ្ធិ និងករណីយកិច្ចផ្សេងៗទៀត ដូចមានចែងក្នុងច្បាប់នេះ ។

ក្នុងករណីជនជាប់ឃុំជាជនបរទេស ប្រធានពន្ធនាគារត្រូវអនុញ្ញាតឱ្យជនជាប់ឃុំជូនដំណឹងទៅស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងរបស់ខ្លួន ។ ប្រសិនបើជនជាប់ឃុំមិនមានលទ្ធភាពជូនដំណឹងបាន ប្រធានពន្ធនាគារត្រូវធ្វើកិច្ចការនេះ ។

ក្រោយពីបានទទួលការណែនាំនេះ ជនជាប់ឃុំត្រូវផ្តិតម្រាមដៃ និង បិទ ឬស្កេនរូបថតបញ្ចូលក្នុងកុំព្យូទ័រ ដើម្បីរក្សាទុកជាអចិន្ត្រៃយ៍ក្នុងសំណុំឯកសារ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ព្រះមហាក្សត្រ

**មាត្រា ២១.-**

ពន្ធនាគារនីមួយៗ ត្រូវមានបញ្ជីជនជាប់ឃុំដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់ជនជាប់ឃុំ ហើយចុះទិដ្ឋាការដោយតំណាងអង្គការអយ្យការនៅគ្រប់ទំព័រ ។

ចំពោះជនជាប់ឃុំជាស្ត្រីភេទ និងជនជាប់ឃុំជាអនីតិជន ត្រូវមានបញ្ជីដោយឡែក ហើយត្រូវយកចិត្តទុកដាក់ជាពិសេសដល់ការគ្រប់គ្រងជនជាប់ឃុំទាំងពីរប្រភេទនេះ ។

**មាត្រា ២២.-**

បញ្ជីជនជាប់ឃុំត្រូវបានត្រួតពិនិត្យដោយតំណាងអង្គការអយ្យការ និងត្រូវជូនទៅចៅក្រមពិនិត្យ មើលតាមការស្នើសុំ ព្រមទាំងបង្ហាញដល់មន្ត្រីនគរបាលយុត្តិធម៌ដែលបំពេញភារកិច្ច តាមការប្រគល់អំណាចពីអាជ្ញាធរតុលាការ ។

**មាត្រា ២៣.-**

គ្រប់ពន្ធនាគារត្រូវបង្កើតសំណុំឯកសារផ្ទាល់ខ្លួន សម្រាប់ជនជាប់ឃុំម្នាក់ៗ រាប់ទាំងជនជាប់ឃុំជាអនីតិជនផង ។ ព័ត៌មាន និងឯកសារពាក់ព័ន្ធទាំងអស់របស់ជនជាប់ឃុំ ត្រូវរក្សាទុកជាការសម្ងាត់ក្នុងសំណុំរឿងផ្ទាល់ខ្លួន ។

**មាត្រា ២៤.-**

ជនជាប់ឃុំ ត្រូវបានពិនិត្យវាយតម្លៃសុខភាពដោយមន្ត្រីពេទ្យពន្ធនាគារ ។ ត្រូវកត់បញ្ចូលទៅក្នុងសំណុំរឿងជនជាប់ឃុំ នូវព័ត៌មានអំពីរបួសស្នាម ជំងឺផ្លូវចិត្ត ពិការភាពផ្នែកកាយសម្បទា ឬ ព័ត៌មានពាក់ព័ន្ធផ្សេងទៀត ។

ក្នុងការចូលរួមការងារពលកម្មក្នុងពន្ធនាគារ ពេលពិនិត្យវាយតម្លៃសុខភាពលើកដំបូង មន្ត្រីពេទ្យពន្ធនាគារត្រូវកំណត់អំពីសមត្ថភាពកាយសម្បទា និងត្រូវកត់បញ្ចូលទៅក្នុងសំណុំរឿងផ្ទាល់ខ្លួនរបស់ទណ្ឌិត ដោយត្រូវយកចិត្តទុកដាក់ដល់សេចក្ដីត្រូវការជាក់លាក់ និងខុសៗគ្នារបស់ស្ត្រី និងអនីតិជន ។

**មាត្រា ២៥.-**

រាល់ការធ្វើទារុណកម្ម ទង្វើអមនុស្សធម៌ ឬការប្រើប្រាស់ឧបករណ៍ផ្សេងៗ ដើម្បីដាក់ទណ្ឌកម្មដល់ជនជាប់ឃុំ ត្រូវហាមឃាត់ លើកលែងតែខ្នោះដៃដែលត្រូវបានអនុញ្ញាតតាមមាត្រា ៥០ នៃច្បាប់នេះ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ២៦.-**

ជនជាប់ឃុំជាជនត្រូវចោទ ជនជាប់ចោទ ឬពិរុទ្ធជន ត្រូវដាក់បំបែកពីជនជាប់ឃុំជាទណ្ឌិត ។

ជនជាប់ឃុំជាស្ត្រី ត្រូវដាក់បំបែកពីជនជាប់ឃុំជាបុរស ។

ជនជាប់ឃុំជាអនីតិជន ត្រូវដាក់បំបែកពីជនជាប់ឃុំជានីតិជន ។

ជនជាប់ឃុំដែលមានជំងឺឆ្លង ត្រូវដាក់បំបែកចេញពីជនជាប់ឃុំដទៃទៀត ។

**មាត្រា ២៧.-**

ក្រោយពីទទួលយកជនជាប់ឃុំចូលក្នុងពន្ធនាគារ ប្រធានពន្ធនាគារត្រូវចាត់ឲ្យមានការវាយតម្លៃ កំណត់អំពីចំណាត់ថ្នាក់សន្តិសុខ ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងពន្ធនាគារ ។

## ជំពូកទី ៥
## សិទ្ធិ និងលក្ខខណ្ឌរស់នៅរបស់ជនជាប់ឃុំ

**មាត្រា ២៨.-**

ជនជាប់ឃុំ មានសិទ្ធិប្ដឹងតវ៉ាទៅប្រធានពន្ធនាគារ ឬទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ឬព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពីអំពើរំលោភរបស់ជនជាប់ឃុំដូចគ្នា ឬអំពើរំលោភរបស់មន្ត្រីពន្ធនាគារ ។

ពាក្យបណ្ដឹងតវ៉ារបស់ជនជាប់ឃុំ ត្រូវធ្វើឡើងតាមរយៈមន្ត្រីពន្ធនាគារ ឬអ្នកសួរសុខទុក្ខផ្លូវការ ឬអ្នកសួរសុខទុក្ខសាច់ញាតិ ឬមេធាវីរបស់ជនជាប់ឃុំ ឬតំណាងអង្គការអយ្យការ ។

រាល់បណ្ដឹងតវ៉ាត្រូវតែបានដោះស្រាយនិងឆ្លើយតប ក្នុងរយៈពេលសមស្រប ។

គ្មានជនជាប់ឃុំណាម្នាក់ត្រូវបានដាក់ទណ្ឌកម្ម ឬត្រូវបានរើសអើងដោយសារតែបានដាក់ពាក្យបណ្ដឹង ឬការដាក់ពាក្យស្នើសុំនោះឡើយ ។

**មាត្រា ២៩.-**

ជនជាប់ឃុំមានសិទ្ធិប្រតិបត្តិសាសនាតាមជំនឿរបស់ខ្លួន និងមិនត្រូវបានបង្ខិតបង្ខំឲ្យប្រតិបត្តិសាសនាណាមួយឡើយ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ៣០.-**

ជនជាប់ឃុំដែលមិនតម្រូវឲ្យធ្វើការនៅខាងក្រៅបាន ដោយមូលហេតុខាងផ្លូវច្បាប់ ឬមូលហេតុខាងសន្តិសុខ អាចអនុញ្ញាតឲ្យធ្វើលំហាត់ប្រាណប្រចាំថ្ងៃបាន ។

**មាត្រា ៣១.-**

ជនជាប់ឃុំជាជនបរទេស មានសិទ្ធិទាក់ទងជាមួយស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងរបស់ខ្លួន ។

រាល់ទំនាក់ទំនងរវាងជនជាប់ឃុំនិងមេធាវី ត្រូវបានធ្វើឡើងដោយសម្ងាត់ ។

**មាត្រា ៣២.-**

ជនជាប់ឃុំ មានសិទ្ធិទទួល និង ផ្ញើលិខិតឆ្លងឆ្លើយ ។ លិខិតឆ្លងឆ្លើយរបស់ជនជាប់ឃុំត្រូវបើកនៅចំពោះមុខមន្ត្រីពន្ធនាគារ ដែលត្រូវបានប្រគល់សិទ្ធិ លើកលែងតែលិខិតរបស់មេធាវី ។

លិខិតឆ្លងឆ្លើយរបស់ជនជាប់ឃុំ ត្រូវបានដកហូត ប្រសិនបើមានការពាក់ព័ន្ធដល់សន្តិសុខសុវត្ថិភាព សណ្តាប់ធ្នាប់ទូទៅ ទាំងក្នុង និងក្រៅពន្ធនាគារ ។

**មាត្រា ៣៣.-**

ជនជាប់ឃុំ ត្រូវបានទទួលរបបជីវភាព ដែលកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៣៤.-**

ការផ្តល់អាហារដល់ជនជាប់ឃុំ ត្រូវយកចិត្តទុកដាក់គិតគូរអំពីអាហារតម ស្របតាមតម្រូវការខាងសុខភាព ដែលបញ្ជាក់ពីមន្ត្រីពេទ្យពន្ធនាគារ ឬស្របតាមតម្រូវការខាងសាសនារបស់ពួកគេ ។

ជនជាប់ឃុំ អាចទទួល ឬទិញអាហារដោយថវិកាផ្ទាល់ខ្លួនពីប្រភពខាងក្រៅបាន តែអាហារទាំងនេះត្រូវបានត្រួតពិនិត្យពីមន្ត្រីពន្ធនាគារ ។

**មាត្រា ៣៥.-**

ជនជាប់ឃុំ អាចត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ថវិកាផ្ទាល់ខ្លួន ដើម្បីទិញសម្ភារៈប្រើប្រាស់ ឬទទួលសម្ភារៈប្រើប្រាស់ពីគ្រួសារ ញាតិមិត្ត ឬពីប្រភពផ្សេងទៀត ប្រសិនបើមានការយល់ព្រម និងការត្រួតពិនិត្យពីប្រធានពន្ធនាគារ ។

ជនជាប់ឃុំ មិនត្រូវបានអនុញ្ញាតឲ្យទិញ ឬផ្តល់ ឬឲ្យខ្ចី ឬលក់សម្ភារៈទៅឲ្យជនជាប់ឃុំផ្សេងទៀតបានឡើយ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា ៣៦.-**

ថវិកា ឬទ្រព្យសម្បត្តិមានតម្លៃជាប់ខ្លួនរបស់ជនជាប់ឃុំ ត្រូវបានដកហូត កត់ត្រាត្រឹមត្រូវ ក្នុងសៀវភៅបញ្ជី និងរក្សាទុកក្នុងគណនីពន្ធនាគារ ឬត្រូវប្រគល់ជូនក្រុមគ្រួសារ ញាតិមិត្តរក្សាទុក ប្រសិនបើមានការយល់ព្រមពីជនជាប់ឃុំ ដោយត្រូវមានហត្ថលេខា ឬស្នាមម្រាមដៃរបស់ជនជាប់ឃុំ ។

ក្នុងករណីចាំបាច់និងមានការយល់ព្រមពីប្រធានពន្ធនាគារ ជនជាប់ឃុំអាចប្រើប្រាស់ថវិកាបញ្ញើរបស់ខ្លួនបាន ។

ថវិកា និងទ្រព្យសម្បត្តិមានតម្លៃរបស់ជនជាប់ឃុំដែលពន្ធនាគារទទួលខុសត្រូវរក្សាទុក ត្រូវប្រគល់ជូនជនជាប់ឃុំវិញ នៅពេលដោះលែង ។

ជនជាប់ឃុំអាចរក្សាទុកឱសថជាកម្មសិទ្ធិផ្ទាល់ខ្លួនបាន ក្នុងករណីមានការយល់ព្រមពីមន្ត្រីពេទ្យពន្ធនាគារ ។

**មាត្រា ៣៧.-**

ជនជាប់ឃុំត្រូវបានអនុញ្ញាតឲ្យទទួលដំណឹង ឬព័ត៌មានសំខាន់ៗ តាមរយៈកម្មវិធីផ្សព្វផ្សាយរបស់វិទ្យុ ទូរទស្សន៍ ទស្សនាវដ្ដី សារព័ត៌មាន និងទំនាក់ទំនងទូរសព្ទជាមួយក្រុមគ្រួសារ ដែលរៀបចំឡើងដោយពន្ធនាគារ ។

ជនជាប់ឃុំអាចអនុញ្ញាតឲ្យចូលសិក្សាស្រាវជ្រាវនៅក្នុងបណ្ណាល័យពន្ធនាគារ ឬអាចអនុញ្ញាតឲ្យខ្ចីសៀវភៅយកទៅស្រាវជ្រាវនៅក្នុងបន្ទប់ឃុំឃាំងដើម្បីបង្កើនចំណេះដឹង ។

ពន្ធនាគារត្រូវជូនដំណឹងទាក់ទងនឹងជំងឺ ឬមរណភាពរបស់ជនជាប់ឃុំ ឬរបស់គ្រួសារជនជាប់ឃុំឲ្យបានដឹងទៅវិញទៅមក ។

**មាត្រា ៣៨.-**

ជនជាប់ឃុំដែលមានជំងឺត្រូវបានទទួលសេវាថែទាំសុខភាពប្រចាំថ្ងៃដោយមន្ត្រីពេទ្យពន្ធនាគារ ។

ជនជាប់ឃុំមានជំងឺធ្ងន់ ហើយតម្រូវឲ្យមានការព្យាបាលនៅមន្ទីរពេទ្យខាងក្រៅតាមសំណើរបស់មន្ត្រីពេទ្យពន្ធនាគារ ត្រូវមានការអនុញ្ញាតពីព្រះរាជអាជ្ញាក្នុងដែនសមត្ថកិច្ច ។ ក្នុងករណីជនជាប់ឃុំមានជំងឺធ្ងន់ ដែលតម្រូវឲ្យមានការសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យខាងក្រៅ ប្រធានពន្ធនាគារត្រូវបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យជាបន្ទាន់តាមសំណើរបស់មន្ត្រីពេទ្យពន្ធនាគារ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ព្រះរាជអាជ្ញាក្នុងដែនសមត្ថកិច្ច និងដល់គ្រួសារសាច់ញាតិ ឬមិត្តភក្តិជិតស្និទ្ធបំផុត តាមសំណើរបស់ជនជាប់ឃុំ ។ បន្ទាប់ពីការព្យាបាលបានធូរស្រាល តាមការបញ្ជាក់ពីមន្ទីរពេទ្យដែលបានទទួលព្យាបាល ត្រូវបញ្ជូនជនជាប់ឃុំមកពន្ធនាគារវិញ ។

ជនជាប់ឃុំដែលមានជំងឺផ្លូវចិត្ត ឬពិការកាយសម្បទា ឬស្ថិតក្រោមឥទ្ធិពលគ្រឿងញៀនត្រូវបានទទួលសេវាថែទាំសុខភាពដោយឡែក ។

**មាត្រា ៣៩.-**

អគារឃុំឃាំងជនជាប់ឃុំជាស្ត្រីត្រូវមានមន្ត្រីពន្ធនាគារជាស្ត្រី ប្រចាំការជាអចិន្ត្រៃយ៍ ។

មិនអនុញ្ញាតឲ្យមន្ត្រីពន្ធនាគារជាបុរសចូលក្នុងតំបន់ជនជាប់ឃុំជាស្ត្រី ដោយគ្មានការអមដំណើរពីមន្ត្រីពន្ធនាគារជាស្ត្រីឡើយ លើកលែងតែក្នុងករណីមានឧប្បត្តិហេតុសង្គ្រោះបន្ទាន់ ឬក្នុងហេតុផលសន្តិសុខ សុវត្ថិភាពពន្ធនាគារ ។

**មាត្រា ៤០.-**

ជនជាប់ឃុំជាស្ត្រីត្រូវបានផ្តល់សេវាគាំពារមាតា និងទារក នៅមុននិងក្រោយពេលសម្រាលកូន ។

ជនជាប់ឃុំជាស្ត្រីដែលមានផ្ទៃពោះ ត្រូវបានអនុញ្ញាតឲ្យសម្រាលកូននៅមន្ទីរពេទ្យខាងក្រៅ ។

ក្នុងករណីមានជនជាប់ឃុំជាស្ត្រីសម្រាលកូនក្នុងពន្ធនាគារ មិនត្រូវចុះសំបុត្រកំណើតថាទារកនោះកើតនៅក្នុងពន្ធនាគារទេ ។

**មាត្រា ៤១.-**

កូនតាមម្តាយ ត្រូវបានអនុញ្ញាតឲ្យស្នាក់នៅក្នុងពន្ធនាគារជាមួយម្តាយត្រឹមអាយុក្រោម ៣ (បី) ឆ្នាំ និងត្រូវបានផ្តល់ម្ហូបអាហារ សម្លៀកបំពាក់ និងសេវាថែទាំសុខភាព ។

កូនតាមម្តាយដែលមានអាយុចាប់ពី ៣ (បី) ឆ្នាំ ឡើង បើគ្មានអាណាព្យាបាលទទួលខុសត្រូវការចិញ្ចឹមបីបាច់ថែរក្សាបន្តនៅខាងក្រៅជាបន្ទុករបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ។

## ជំពូកទី ៦
## ការគ្រប់គ្រងពន្ធនាគារ

**មាត្រា ៤២.-**

គោលដៅជាសារវន្តនៃការគ្រប់គ្រងជនជាប់ឃុំ គឺការអប់រំកែប្រែនិងការស្តារនីតិសម្បទារបស់ជនជាប់ឃុំ ដែលជាស្នូលនៃក្របខ័ណ្ឌគោលនយោបាយកំណែទម្រង់ពន្ធនាគារ ។

ការដាក់វិន័យទៅលើជនជាប់ឃុំ ត្រូវធ្វើឡើងក្នុងកម្រិតអប្បបរមាដែលចាំបាច់ ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ប៉ុណ្ណោះ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា ៤៣.-**

ប្រធានពន្ធនាគារត្រូវទទួលខុសត្រូវដោយផ្ទាល់ ក្នុងការគ្រប់គ្រងពន្ធនាគារឲ្យបានត្រឹមត្រូវតាមនីតិវិធី និងបទបញ្ជាផ្ទៃក្នុងដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤៤.-**

មន្ត្រីពន្ធនាគារអាចធ្វើការឆែកឆេរជនជាប់ឃុំនិងកន្លែងនានាក្នុងពន្ធនាគារ ដើម្បីជានាសន្តិសុខ និងសុវត្ថិភាពរបស់ពន្ធនាគារ ។

ជនជាប់ឃុំដែលបដិសេធមិនឲ្យមន្ត្រីពន្ធនាគារឆែកឆេរ ត្រូវចាត់ទុកជាការល្មើសនឹងបទបញ្ជាផ្ទៃក្នុងពន្ធនាគារ ។

**មាត្រា ៤៥.-**

ដើម្បីជានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ពន្ធនាគារ មន្ត្រីពន្ធនាគារ និងអ្នកមកសួរសុខទុក្ខជនជាប់ឃុំ ត្រូវបានត្រួតពិនិត្យមុនពេលចូលទៅក្នុងពន្ធនាគារ ។

**មាត្រា ៤៦.-**

ការរក្សាទុក ឬការប្រើប្រាស់គ្រឿងស្រវឹងក្នុងពន្ធនាគារត្រូវហាមឃាត់ ។

ជនជាប់ឃុំមិនត្រូវបានអនុញ្ញាតឲ្យរក្សាទុក ឬប្រើប្រាស់វត្ថុទាំងឡាយណាដែលអាចគំរាមកំហែងដល់សន្តិសុខពន្ធនាគារឡើយ ។

ប្រភេទវត្ថុហាមឃាត់ត្រូវបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ ។

**មាត្រា ៤៧.-**

ប្រធានពន្ធនាគារអាចអនុញ្ញាតឲ្យមន្ត្រីពន្ធនាគារដែលបានបណ្តុះបណ្តាលហ្វឹកហាត់ត្រឹមត្រូវឲ្យប្រើប្រាស់អាវុធ និងឧបករណ៍បច្ចេកទេសដើម្បីជានាសន្តិសុខ សុវត្ថិភាពក្នុងកិច្ចប្រតិបត្តិការរបស់ពន្ធនាគារ ។

ប្រធានពន្ធនាគារត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងអាវុធ និងឧបករណ៍បច្ចេកទេសឲ្យមានសុវត្ថិភាព ។

**មាត្រា ៤៨.-**

ប្រធានពន្ធនាគារត្រូវរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញា គណៈអភិបាលរាជធានី ខេត្ត និងអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អំពីព័ត៌មាន ឬឧប្បត្តិហេតុទាំងឡាយណាដែលគំរាមកំហែង ឬដែលអាចគំរាមកំហែងដល់សន្តិសុខ សុវត្ថិភាពពន្ធនាគារ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ៤៩.-**

ប្រធានពន្ធនាគារអាចប្រើប្រាស់កម្លាំងប្រតិបត្តិការដើម្បីរក្សាសន្តិសុខ សុវត្ថិភាពពន្ធនាគារ ។ ក្នុងករណីធ្ងន់ធ្ងរ ប្រធានពន្ធនាគារត្រូវរាយការណ៍សុំកម្លាំងអន្តរាគមន៍ទៅគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ។

**មាត្រា ៥០.-**

ការប្រើប្រាស់ខ្នោះដៃដើម្បីដាក់ទណ្ឌកម្មជនជាប់ឃុំត្រូវហាមឃាត់ លើកលែងតែប្រើប្រាស់ក្នុងស្ថានភាពដូចខាងក្រោម :

- ពេលមានចលាចលក្នុងពន្ធនាគារ
- ពេលផ្ទេរ ឬបញ្ជូន ឬនាំខ្លួនចេញពីពន្ធនាគារ
- ពេលមានហេតុផលខាងពេទ្យ
- ដើម្បីការពារជនជាប់ឃុំកុំឲ្យបង្ករបួសស្នាមដោយខ្លួនឯង ឬបង្ករបួសស្នាមដល់អ្នកដទៃ ឬបង្កការខូចខាតទ្រព្យសម្បត្តិអ្នកដទៃ ។

**មាត្រា ៥១.-**

ជនជាប់ឃុំត្រូវគោរព និងអនុវត្តតាមបទបញ្ជាផ្ទៃក្នុងពន្ធនាគារ និងការណែនាំរបស់មន្ត្រីពន្ធនាគារ ។

**មាត្រា ៥២.-**

ជនជាប់ឃុំដែលបានប្រព្រឹត្តល្មើសនឹងបទបញ្ជាផ្ទៃក្នុង ដែលធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់ពន្ធនាគារ មិនត្រូវលើកយកមកពិនិត្យលក្ខណវិនិច្ឆ័យសម្រាប់ការបន្ធូរបន្ថយទោស និងលើកលែងទោសក្នុងរយៈពេលមួយឆ្នាំ ។ ក្នុងករណីមិនរាងចាល ត្រូវឃុំខ្លួននៅក្នុងបន្ទប់ដោយឡែក ។

ប្រធានពន្ធនាគារដែលចេញបទបញ្ជាឲ្យឃុំខ្លួននៅក្នុងបន្ទប់ដោយឡែក ត្រូវបញ្ជាក់ពីមូលហេតុ និងត្រូវរាយការណ៍ភ្លាមមកអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ។

បទបញ្ជាឃុំខ្លួនដោយឡែកអាចមានរយៈពេលពី ១៤ (ដប់បួន) ថ្ងៃ ដល់ ២០ (ម្ភៃ) ថ្ងៃ ។ ក្នុងករណីមិនរាងចាល បទបញ្ជានេះអាចត្រូវបានចេញបន្តទៀត ។

ក្នុងរយៈពេលនៃការរងទណ្ឌកម្មដោយត្រូវឃុំខ្លួនក្នុងបន្ទប់ដោយឡែក ជនជាប់ឃុំមិនត្រូវបានអនុញ្ញាត :

- ឲ្យជួបគ្រួសារសាច់ញាតិដែលមកសួរសុខទុក្ខ
- ចូលរួមសកម្មភាពផ្សេងៗក្នុងពន្ធនាគារ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ៥៣.-**

ការធ្វើទារុណកម្មមកលើរាងកាយគ្រប់រូបភាព ការឃុំខ្លួនក្នុងបន្ទប់ងងឹត ការកាត់បន្ថយម្ហូបអាហារ ការដាក់ទណ្ឌកម្មជាសមូហភាពដល់ជនជាប់ឃុំ និងការប្រើប្រាស់ជនជាប់ឃុំឲ្យធ្វើទារុណកម្មជនជាប់ឃុំដូចគ្នា ត្រូវហាមឃាត់ ។

**មាត្រា ៥៤.-**

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា ប្រធានសភាស៊ើបសួរ និងចៅក្រមស៊ើបសួរ ត្រូវធ្វើអធិការកិច្ចពន្ធនាគារស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។ បែបបទ នីតិវិធី និងការប្រព្រឹត្តទៅនៃការធ្វើអធិការកិច្ច ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

យន្តការបង្ការថ្នាក់ជាតិ ត្រូវបានអនុញ្ញាតឲ្យធ្វើទស្សនកិច្ចតាមពន្ធនាគារនានា គ្រប់ពេលវេលា និងធ្វើសម្ភាសន៍ជាសម្ងាត់ជាមួយជនជាប់ឃុំ ដើម្បីត្រួតពិនិត្យមើលលក្ខខណ្ឌនៃការឃុំខ្លួន និងការប្រព្រឹត្តចំពោះជនជាប់ឃុំ ផ្តល់អនុសាសន៍កែលម្អ សំដៅបង្ការទារុណកម្ម អំពើឃោរឃៅអមនុស្សធម៌ ឬ បន្ទាបបន្ថោក ។

**មាត្រា ៥៥.-**

ជនជាប់ឃុំត្រូវបានអនុញ្ញាតឲ្យគ្រួសារ ឬញាតិមិត្តមកសួរសុខទុក្ខតាមការកំណត់ លើកលែងតែមានការហាមឃាត់ពីអាជ្ញាធរតុលាការ ។

ប្រធានពន្ធនាគារត្រូវបិទផ្សាយជាសាធារណៈនូវពេលវេលា និងរយៈពេលសួរសុខទុក្ខ ដែលមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ ។

**មាត្រា ៥៦.-**

មន្ត្រីស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងដែលមានបំណងចូលជួបសួរសុខទុក្ខជន ជាប់ឃុំជាពលរដ្ឋរបស់ខ្លួន ឬពលរដ្ឋដែលខ្លួនធ្វើជាតំណាង ត្រូវជូនដំណឹងជាមុនទៅអគ្គនាយកដ្ឋានពន្ធនាគារ ។

គ្រួសារ ឬញាតិមិត្តជាជនបរទេសដែលមានបំណងចូលជួបសួរសុខទុក្ខជនជាប់ឃុំ ត្រូវស្នើមកអគ្គនាយកដ្ឋានពន្ធនាគារ តាមរយៈស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងរបស់ខ្លួន ។

**មាត្រា ៥៧.-**

អ្នកសួរសុខទុក្ខជនជាប់ឃុំ មិនត្រូវយកវត្ថុ ឬសម្ភារៈហាមឃាត់ ដូចមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងពន្ធនាគារចូលពន្ធនាគារឡើយ ។

**មាត្រា ៥៨.-**

អ្នកសួរសុខទុក្ខជនជាប់ឃុំ អាចត្រូវបានហាមឃាត់ ឬបញ្ឈប់ ឬឲ្យចេញជាបណ្ដោះអាសន្នពីពន្ធនាគារ ក្នុងករណីដែលមានឧប្បត្តិហេតុចៃដន្យកើតឡើង ។

ក្នុងករណីអ្នកសួរសុខទុក្ខជនជាប់ឃុំធ្វើសកម្មភាពនាំឲ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់ សន្តិសុខ សុវត្ថិភាពពន្ធនាគារ ត្រូវឃាត់ខ្លួននិងចាត់វិធានការតាមផ្លូវច្បាប់ ។

**មាត្រា ៥៩.-**

បើអ្នកសួរសុខទុក្ខផ្លូវការមានបំណងធ្វើទស្សនកិច្ចពន្ធនាគារណាមួយ ត្រូវផ្ដល់ដំណឹងជាមុនទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អំពីគោលបំណង និងសំណូមពរនៃទស្សនកិច្ចនោះ ។

លទ្ធផលនៃទស្សនកិច្ចខាងលើ ត្រូវផ្ដល់ព័ត៌មានដោយផ្ទាល់មាត់ ឬដោយលាយលក្ខណ៍អក្សរទៅប្រធានពន្ធនាគារ និងអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ។ ព័ត៌មាននោះត្រូវចាត់ទុកជាព័ត៌មានសម្ងាត់ លើកលែងតែមានការឯកភាពពីក្រសួងមហាផ្ទៃ ។

**មាត្រា ៦០.-**

ជនជាប់ឃុំអាចត្រូវបានឲ្យចាកចេញជាបណ្ដោះអាសន្នពីពន្ធនាគារ តាមដីកាបង្គាប់របស់តុលាការ ដើម្បីឡើងសវនាការ ឬធ្វើការស៊ើបអង្កេត ឬចង្អុលបង្ហាញភស្ដុតាង ។

**មាត្រា ៦១.-**

ប្រធានពន្ធនាគារត្រូវទទួលខុសត្រូវអំពីសន្តិសុខ សុវត្ថិភាពចំពោះការនាំខ្លួន ឬការបញ្ជូនជនជាប់ឃុំទៅកាន់តុលាការ ឬទៅកាន់មន្ទីរពេទ្យខាងក្រៅ ។

**មាត្រា ៦២.-**

ការផ្ទេរបញ្ជូនទណ្ឌិតពីពន្ធនាគារមួយទៅពន្ធនាគារមួយ ត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជូនដំណឹងភ្លាម ឬយ៉ាងយូរ ៣ (បី) ថ្ងៃ ដោយប្រធានពន្ធនាគារទៅព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដីបញ្ជូន និងសមត្ថកិច្ចខាងដែនដីទទួល ។

ការផ្ទេរជនជាប់ឃុំក្រៅពីទណ្ឌិត ពីពន្ធនាគារមួយទៅពន្ធនាគារមួយ ត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាមានសមត្ថកិច្ចខាងដែនដីបញ្ជូន និងព្រះរាជអាជ្ញាមានសមត្ថកិច្ចខាងដែនដីទទួល ឬអគ្គព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចកំពុងចាត់ការរឿងក្ដី ។

ក្នុងករណីចាំបាច់ អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាអាចចេញដីកាបង្គាប់ឲ្យផ្ទេរជនជាប់ឃុំក្រៅពីទណ្ឌិត ពីពន្ធនាគារមួយទៅពន្ធនាគារមួយ តាមតម្រូវការនៃនីតិវិធី ។ ដីកាបង្គាប់នេះត្រូវចម្លងជូនទៅក្រសួងមហាផ្ទៃ ។

ការផ្ទេរបញ្ជូនជនជាប់ឃុំពីពន្ធនាគារមួយទៅពន្ធនាគារមួយ ត្រូវភ្ជាប់ទៅជាមួយនូវទ្រព្យសម្បត្តិ សំណុំរឿង និងឯកសារសុខភាពរបស់ជនជាប់ឃុំ ។

**មាត្រា ៦៣.-**

ក្នុងករណីជនជាប់ឃុំលួចរត់គេចខ្លួន ប្រធានពន្ធនាគារ និងអាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងជាបន្ទាន់ទៅគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ និងទៅព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី ដើម្បីស្វែងរកចាប់ខ្លួនជនជាប់ឃុំមកវិញ ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ៦៤.-**

ក្នុងករណីជនជាប់ឃុំទទួលមរណភាពក្នុងពន្ធនាគារ ត្រូវចាត់ទុកជាការសង្ស័យ ។ មន្ត្រីពន្ធនាគារត្រូវការពារកន្លែងសាកសព និងរក្សាទុកជនជាប់ឃុំដែលអាចធ្វើសាក្សី ។ ប្រធានពន្ធនាគារត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាដើម្បីចាត់វិធានការស៊ើបអង្កេត ។

ប្រសិនបើជនជាប់ឃុំស្លាប់នៅក្នុងមន្ទីរពេទ្យ ប្រធានពន្ធនាគារត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា បើមានការសង្ស័យ ព្រះរាជអាជ្ញាត្រូវចាត់ឲ្យនគរបាលបច្ចេកទេសវិទ្យាសាស្ត្រធ្វើការពិនិត្យសាកសព ។

**មាត្រា ៦៥.-**

ប្រធានពន្ធនាគារត្រូវជូនដំណឹងភ្លាមទៅគ្រួសារសព ឬស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងនៃសព ដើម្បីរៀបចំទុកដាក់សព ។

ក្នុងករណីគ្មានក្រុមគ្រួសារ ឬសាច់ញាតិ ប្រធានពន្ធនាគារត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីស្ថានភាពនៃសព ជូនព្រះរាជអាជ្ញា អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ និងមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅឋានរបស់សព ។ ការចំណាយលើការរៀបចំទុកដាក់សពជាបន្ទុករបស់រដ្ឋដែលកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៧
## ការអប់រំ កែប្រែ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និង ការស្តារនីតិសម្បទាទណ្ឌិត

**មាត្រា ៦៦.-**

ទណ្ឌិតត្រូវបានចាត់តាំងឲ្យចូលរួមក្នុងកម្មវិធីអប់រំច្បាប់និងសីលធម៌សង្គម ដែលបានរៀបចំឡើងនៅក្នុងពន្ធនាគារ ។

**មាត្រា ៦៧.-**

ទណ្ឌិតត្រូវបានផ្តល់មធ្យោបាយដើម្បីចូលរួមកម្មវិធីសិក្សាចំណេះទូទៅ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងពន្ធនាគារ ។

កម្មវិធីសិក្សាអប់រំ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងពន្ធនាគារ ត្រូវបានធ្វើសមាហរណកម្មជាមួយប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ជាតិ ។

ទណ្ឌិតជាអនីតិជនត្រូវបានយកចិត្តទុកដាក់ដោយឡែក ទាក់ទងនឹងតម្រូវការសិក្សាអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការស្តារនីតិសម្បទា និងសមាហរណកម្មដោយសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងអប់រំ យុវជន និងកីឡា ។

ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវសហការជាមួយក្រសួងមហាផ្ទៃរៀបចំកម្មវិធី និងដំណើរការអនុវត្តកម្មវិធីសិក្សាអប់រំ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដល់ទណ្ឌិតនៅក្នុងពន្ធនាគារ ។

**មាត្រា ៦៨.-**

ទណ្ឌិតដែលមានកម្រិតសន្តិសុខទាប ហើយត្រូវបានវាយតម្លៃថា មានសមត្ថភាពកាយសម្បទា ត្រូវបានចាត់តាំងឲ្យធ្វើការងារពលកម្មប្រចាំថ្ងៃនៅក្នុងពន្ធនាគារ ឬការងារជាអត្ថប្រយោជន៍សម្រាប់សហគមន៍ និងផលប្រយោជន៍សាធារណៈ ឬចាត់តាំងឲ្យចូលរួមក្នុងកម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ។

**មាត្រា ៦៩.-**

កម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ត្រូវបានរៀបចំឡើងនៅតាមពន្ធនាគារនីមួយៗ ដើម្បីផ្តល់ឱកាសឲ្យទណ្ឌិតមានសមត្ថភាពប្រកបមុខរបរចិញ្ចឹមជីវិត នៅពេលធ្វើសមាហរណកម្មចូលក្នុងសហគមន៍វិញ ។

**មាត្រា ៧០.-**

ទណ្ឌិតដែលចូលរួមក្នុងកម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ត្រូវបានបំពាក់សម្ភារៈ និងឧបករណ៍ការពារសុវត្ថិភាពការងារ ក្នុងពេលបំពេញការងារ ។

**មាត្រា ៧១.-**

បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ មានសិទ្ធិចុះកិច្ចសន្យាជាមួយរូបវន្តបុគ្គល ឬនីតិបុគ្គល ឬអង្គការជាតិ អន្តរជាតិដើម្បីបង្កើតការងារ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

សម្រាប់កម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ និងមានសិទ្ធិចុះកិច្ចសន្យាលក់ផលិតផល ឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ។

**មាត្រា ៧២.-**

ការគ្រប់គ្រង និងការប្រើប្រាស់ប្រាក់ចំណូលដែលបានមកពីកម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

នីតិវិធីគ្រប់គ្រងកម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧៣.-**

មុនផុតរយៈពេលទទួលរងទោស ៦ (ប្រាំមួយ) ខែ ទណ្ឌិតត្រូវបានទទួលកម្មវិធីសមាហរណកម្មដែលរៀបចំដោយពន្ធនាគារ ដើម្បីឲ្យគេក្លាយជាពលរដ្ឋអាចរស់នៅក្នុងសង្គមជាតិនិងសហគមន៍មូលដ្ឋានបានល្អ ។

## ជំពូកទី ៨
## ការបន្ធូរបន្ថយទោស ការលើកលែងទោស និង ការដោះលែងទណ្ឌិត

**មាត្រា ៧៤.-**

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបង្កើតគណៈកម្មការមួយដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត ក្នុងរយៈពេលជាប់ឃុំនៅក្នុងពន្ធនាគារដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន ។ គណៈកម្មការនេះ ត្រូវធ្វើបញ្ជីទណ្ឌិតដែលមានលក្ខណសម្បត្តិអាចស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស បញ្ជូនទៅគណៈកម្មការថ្នាក់ជាតិ តាមរយៈអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ យ៉ាងយឺតបំផុត ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ ។

គណៈកម្មការនេះ មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | ជាប្រធាន |
| - តំណាងអង្គការអយ្យការអមសាលាដំបូងរាជធានី ខេត្ត | ជាអនុប្រធាន |
| - ប្រធានក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគាររាជធានី ខេត្ត | ជាអនុប្រធានអចិន្ត្រៃយ៍ |
| - អនុប្រធានពន្ធនាគាររាជធានី ខេត្តទទួលបន្ទុកអប់រំកែប្រែ | ជាសមាជិក |
| - អនុប្រធានពន្ធនាគាររាជធានី ខេត្តទទួលបន្ទុកប្រតិបត្តិ | ជាសមាជិក |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

គណៈកម្មការនេះអាចមានសមាសភាពមួយចំនួនទៀត តាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការនេះ ត្រូវកំណត់ដោយដីការបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវបង្កើតគណៈកម្មការមួយ ដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត ក្នុងរយៈពេលជាប់ឃុំនៅតាមមណ្ឌលអប់រំកែប្រែដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន ។ គណៈកម្មការនេះត្រូវធ្វើបញ្ជីឈ្មោះទណ្ឌិតដែលមានលក្ខណសម្បត្តិអាចស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស បញ្ជូនទៅគណៈកម្មការថ្នាក់ជាតិ យ៉ាងយឺតបំផុត ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ ។

គណៈកម្មការនេះ មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកពន្ធនាគារ | ជាប្រធាន |
| - តំណាងអង្គការអយ្យការអមសាលាដំបូងដែលមានសមត្ថកិច្ចលើមណ្ឌលអប់រំ កែប្រែសាមី | ជាអនុប្រធាន |
| - ប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ | ជាអនុប្រធាន |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ | ជាអនុប្រធានអចិន្ត្រៃយ៍ |
| - ប្រធាននាយកដ្ឋានអប់រំកែប្រែ | ជាសមាជិក |
| - ប្រធាននាយកដ្ឋានប្រតិបត្តិ | ជាសមាជិក |
| - ប្រធានក្រុមការងារប្រឡងប្រណាំងនៃមណ្ឌលអប់រំកែប្រែនីមួយៗ | ជាសមាជិក |

គណៈកម្មការនេះអាចមានសមាសភាពមួយចំនួនទៀត តាមការចាំបាច់ ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧៥.-**

រាជរដ្ឋាភិបាលត្រូវបង្កើតគណៈកម្មការថ្នាក់ជាតិមួយ ដើម្បីពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស ដែលបានផ្ញើមកពីគណៈកម្មការរាជធានី ខេត្ត និងពីគណៈកម្មការក្រសួងមហាផ្ទៃ ។ ក្រោយពីបានពិនិត្យវាយតម្លៃរួចហើយ គណៈកម្មការនេះត្រូវធ្វើបែបបទជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ដើម្បីដាក់សំណើថ្វាយព្រះមហាក្សត្រសុំបន្ធូរបន្ថយទោស និងលើកលែងទោសឲ្យទណ្ឌិត យ៉ាងយឺតបំផុត ១០ (ដប់) ថ្ងៃ មុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ ។

ROYAUME DU CAMBODGE • ROYAL • LE MINISTRE DU PALAIS ROYAL •
ក្រសួងព្រះបរមរាជវាំង

គណៈកម្មការនេះមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ជាប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃទទួលបន្ទុកពន្ធនាគារ | ជាអនុប្រធានអចិន្ត្រៃយ៍ |
| - អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ | ជាអនុប្រធាន |
| - តំណាងក្រុមប្រឹក្សាអ្នកច្បាប់ ចំនួន ០១ រូប | ជាសមាជិក |
| - ប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ | ជាសមាជិក |
| - តំណាងក្រសួងយុត្តិធម៌ ចំនួន០១ រូប | ជាសមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ | ជាសមាជិក |
| - ប្រធាននាយកដ្ឋានជំនាញនៃអគ្គនាយកដ្ឋានពន្ធនាគារ ចំនួន ០២ រូប | ជាសមាជិក |

គណៈកម្មការនេះអាចមានសមាសភាពមួយចំនួនទៀត តាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការនេះ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៧៦.-**

លក្ខណសម្បត្តិ និងចំណាត់ថ្នាក់ប្រឡងប្រណាំង សំដៅជំរុញលើកទឹកចិត្តដល់ទណ្ឌិតម្នាក់ៗឲ្យខិតខំកសាងកែប្រែគំនិតមារយាទ ក្លាយជាពលរដ្ឋល្អដើម្បីធ្វើសមាហរណកម្មបញ្ចូលទៅក្នុងសង្គមជាតិវិញបាននៅពេលអនាគត ត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ទណ្ឌិតដែលយល់ឃើញថា ខ្លួនបានបំពេញលក្ខខណ្ឌក្នុងការស្នើសុំបន្ធូរបន្ថយទោស ឬលើកលែងទោស ប៉ុន្តែមិនត្រូវបានប្រធានពន្ធនាគារធ្វើការស្នើសុំឲ្យខ្លួន សាមីខ្លួនមានសិទ្ធិប្តឹងតវ៉ាទៅ គណៈ-កម្មការថ្នាក់ជាតិ ដូចមានចែងក្នុងមាត្រា ៧៥ នៃច្បាប់នេះ ដោយមានការគាំទ្រពីក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគារ ។

**មាត្រា ៧៧.-**

ក្នុងករណីចាំបាច់ ប្រមុខរាជរដ្ឋាភិបាលមានបុព្វសិទ្ធិធ្វើសំណើថ្វាយព្រះមហាក្សត្រសុំលើកលែងទោសឲ្យទណ្ឌិតនៅពេលណាក៏បាន ។

**មាត្រា ៧៨.-**

ពិធីបុណ្យ លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបន្ធូរបន្ថយទោសនិងការលើកលែងទោស ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ៧៩.-**

គ្រប់ទណ្ឌិតដែលត្រូវទទួលទោសពន្ធនាគារមួយ ឬ ច្រើន អាចត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនោះបានបង្ហាញឲ្យឃើញថា ខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និងមានសម្បទាដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញបាន ។

លក្ខខណ្ឌ និងបែបបទនៃការអនុវត្តការដោះលែងដោយមានលក្ខខណ្ឌក្នុងច្បាប់នេះ ត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨០.-**

ប្រធានពន្ធនាគារត្រូវធ្វើការដោះលែងជនជាប់ឃុំ ក្រោយពីបានទទួលលិខិតសម្រេចពីអាជ្ញាធរតុលាការ ។ ជាគោលការណ៍ ទណ្ឌិតដែលទោសរបស់ខ្លួនត្រូវបញ្ចប់នៅថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកផ្សេងទៀតដែលច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តបានកំណត់ ត្រូវតែដោះលែងឲ្យមានសេរីភាពវិញ នៅមុនថ្ងៃឈប់សម្រាកនោះ ស្របតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៩
## ទោសប្បញ្ញត្តិ

**មាត្រា ៨១.-**

ការធ្វើទារុណកម្ម អំពើឃោរឃៅ និងរាល់ទម្រង់ផ្សេងទៀតនៃការរំលោភបំពានដែលប្រព្រឹត្តទៅលើជនជាប់ឃុំ ត្រូវផ្តន្ទាទោសដោយយោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨២.-**

ជនជាប់ឃុំដែលបានលួចរត់ចេញពីការឃុំខ្លួនតាមគ្រប់មធ្យោបាយ ត្រូវផ្តន្ទាទោសដោយយោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨៣.-**

អំពើរបស់មន្ត្រីពន្ធនាគារដែលទទួលឃុំបុគ្គលណាម្នាក់ ឬពន្យាររយៈពេលឃុំ ឬដោះលែងជនជាប់ឃុំដោយខុសច្បាប់ ត្រូវផ្តន្ទាទោសដោយយោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១០
## អន្តរប្បញ្ញត្តិ

**មាត្រា ៨៤.-**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងពន្ធនាគារដែលបានអនុវត្តកន្លងមក នៅមានសុពលភាព រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមគោលការណ៍នៃច្បាប់នេះ ។

## ជំពូកទី ១១
## អវសានប្បញ្ញត្តិ

**មាត្រា ៨៥.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១១

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកម.១២១១/០២៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង**

ព.ស.២០៩៤ ច.ល

ចម្លងចេញពីច្បាប់ដើម ចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០១១

**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រីរាជរដ្ឋាភិបាល**

**សយ សុខា**

# ឧបសម្ព័ន្ធ២

ច្បាប់ចម្លង

# ព្រះរាជក្រឹត្យ

## ស្ដីពី

នស/រកត/០១២១/០៣០

## ការបន្ធូរបន្ថយទោស និងការលើកលែងទោស

### យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
### ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
### ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង

### ត្រាស់បង្គាប់
### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

មាត្រា១.-

ព្រះរាជក្រឹត្យនេះកំណត់អំពីពិធីបុណ្យ លក្ខខណ្ឌ បែបបទ និងនីតិវិធីក្នុងការបន្ធូរបន្ថយទោស និងការលើកលែងទោសចំពោះទណ្ឌិត ក្នុងគោលបំណងដើម្បីធ្វើសមាហរណកម្មទណ្ឌិតនោះឱ្យចូលទៅរួមរស់ក្នុងសង្គមវិញ ឬក្នុងគោលបំណងផ្នែកមនុស្សធម៌។

មាត្រា២.-

ព្រះរាជក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់ទៅលើការបន្ធូរបន្ថយទោស និងការលើកលែងទោសចំពោះទណ្ឌិតទាំងអស់ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារដោយសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការនៃព្រះរាជាណាចក្រកម្ពុជា និងចំពោះទណ្ឌិតដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារដោយតុលាការនៃបរទេស ប៉ុន្តែ ត្រូវបានបញ្ជូនមកឱ្យអនុវត្តទោសនៅព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកតាមការព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋបរទេសនោះ។

ព្រះរាជក្រឹត្យនេះមិនអនុវត្តចំពោះការលើកលែងទោសឱ្យទណ្ឌិត ដូចមានបញ្ញត្តិក្នុងមាត្រា ៧៧ នៃច្បាប់ស្តីពីពន្ធនាគារឡើយ។

## ជំពូកទី២

## ពិធីបុណ្យដែលអាចស្នើសុំការបន្ធូរបន្ថយទោស និងការលើកលែងទោស

មាត្រា៣.-

ពិធីបុណ្យដែលអាចស្នើសុំការបន្ធូរបន្ថយទោស និងការលើកលែងទោសចំពោះទណ្ឌិត ត្រូវកំណត់ ៥ (ប្រាំ) ដង ក្នុងមួយឆ្នាំ ដូចតទៅ៖

១-ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍។

២-ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ។

៣-ពិធីបុណ្យវិសាខបូជា។

៤-ពិធីបុណ្យឯករាជ្យជាតិ។

៥-ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក។

ការបន្ធូរបន្ថយទោស និងការលើកលែងទោស ក៏អាចធ្វើផងដែរក្នុងពិធីបុណ្យ ឬព្រឹត្តិការណ៍ធំៗរបស់ជាតិ។

ការបន្ធូរបន្ថយទោស និងការលើកលែងទោស ក៏អាចធ្វើសម្រាប់ពិធីបុណ្យនីមួយៗខាងលើដាច់ដោយឡែកពីគ្នា ឬរួមគ្នា។

## ជំពូកទី៣

## លក្ខខណ្ឌនៃការបន្ធូរបន្ថយទោស និងការលើកលែងទោស

### ផ្នែកទី១

### លក្ខខណ្ឌទូទៅនៃការបន្ធូរបន្ថយទោស និងការលើកលែងទោស

មាត្រា៤.-

ការទទួលបានការបន្ធូរបន្ថយទោស និងការលើកលែងទោស មិនមែនជាសិទ្ធិរបស់ទណ្ឌិតនោះទេ ទណ្ឌិតដែលបានបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងព្រះរាជក្រឹត្យនេះ អាចទទួលបានការផ្តល់ឱ្យ ជាការបន្ធូរបន្ថយទោស ឬជាការលើកលែងទោសបាន។

ការបន្ធូរបន្ថយទោស និងការលើកលែងទោស អាចអនុវត្តបានតែចំពោះទណ្ឌិតដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារដោយសាលក្រម ឬសាលដីកាស្ថាពរប៉ុណ្ណោះ។

**មាត្រា៥.-**

ការបន្ធូរបន្ថយទោស និងការលើកលែងទោស អាចអនុវត្តចំពោះទណ្ឌិតដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ជ្ញាក់រលឹកខិតខំកែប្រែគំនិតមារយាទឱ្យក្លាយជាពលរដ្ឋសុចរិត ដើម្បីធ្វើសមាហរណកម្មចូលរួមរស់ក្នុងសង្គមវិញ
- គោរពប្រតិបត្តិបានយ៉ាងហ្មត់ចត់ និងត្រឹមត្រូវ តាមបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ និងជាគំរូល្អដល់ទណ្ឌិត និងជនជាប់ឃុំដទៃទៀត
- ចូលរួមអនុវត្តយ៉ាងសកម្ម និងទៀងទាត់នូវកម្មវិធីអប់រំកែប្រែ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្មវិធីសមាហរណកម្ម
- គោរពប្រតិបត្តិបានយ៉ាងហ្មត់ចត់ និងត្រឹមត្រូវ តាមសេចក្តីណែនាំផ្សេងទៀតរបស់ពន្ធនាគារ។

ប្រធានពន្ធនាគារត្រូវធ្វើការវាយតម្លៃ និងបញ្ជាក់អំពីការបំពេញលក្ខខណ្ឌខាងលើរបស់ទណ្ឌិតដែលត្រូវបញ្ចូលឈ្មោះក្នុងបញ្ជីទណ្ឌិតដែលត្រូវស្នើសុំទៅគណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត។

**មាត្រា៦.-**

ការបន្ធូរបន្ថយទោស និងការលើកលែងទោស អាចអនុវត្តផងដែរក្នុងហេតុផលមនុស្សធម៌ចំពោះទណ្ឌិតដែលមានវ័យចាស់ជរា ជាស្ត្រីមានគភ៌ ឬមានជំងឺរ៉ាំរ៉ៃធ្ងន់ធ្ងរ វិបល្លាសស្មារតី ឬពិការភាព ដោយមានលិខិតបញ្ជាក់ពីគ្រូពេទ្យដែលទទួលស្គាល់ដោយក្រសួងមានសមត្ថកិច្ច។

ប្រធានពន្ធនាគារត្រូវធ្វើការបញ្ជាក់អំពីការបំពេញលក្ខខណ្ឌតាមស្ថានភាពនីមួយៗរបស់ទណ្ឌិតដូចមានចែងក្នុងកថាខណ្ឌខាងលើ ដើម្បីរៀបចំបញ្ជីឈ្មោះទណ្ឌិតដែលត្រូវស្នើសុំទៅគណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ។

## ផ្នែកទី២
## លក្ខខណ្ឌដោយឡែកនៃការបន្ធូរបន្ថយទោស

**មាត្រា៧.-**

ទណ្ឌិតដែលបានបំពេញលក្ខខណ្ឌតាមបញ្ញត្តិនៃមាត្រា៥ នៃព្រះរាជក្រឹត្យនេះ អាចទទួលការបន្ធូរបន្ថយទោសបាន លុះត្រាតែទណ្ឌិតនោះបានទទួលរងទោស ១/៣ (មួយភាគបី) នៃទោសដាក់ពន្ធនាគារដែលតុលាការបានកំណត់។

ចំពោះទោសដាក់ពន្ធនាគារមួយជីវិត ទណ្ឌិតត្រូវទទួលរងទោស ១០ (ដប់) ឆ្នាំជាមុនសិន។

**មាត្រា៨.-**

រយៈពេលនៃការបន្ធូរបន្ថយទោសត្រូវកំណត់ ដូចខាងក្រោម៖

១- ទោសដាក់ពន្ធនាគារកំណត់ពី ១ (មួយ) ឆ្នាំ ដល់ក្រោម ៥ (ប្រាំ) ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន ៣ (បី) ខែ។

២-ទោសដាក់ពន្ធនាគារកំណត់ពី ៥ (ប្រាំ) ឆ្នាំ ដល់ក្រោម ១០ (ដប់) ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន ៦ (ប្រាំមួយ) ខែ ឬ៣ (បី) ខែ។

៣-ទោសដាក់ពន្ធនាគារកំណត់ពី ១០ (ដប់) ឆ្នាំ ដល់ក្រោម ២០ (ម្ភៃ) ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន ៩ (ប្រាំបួន) ខែ ឬ៦ (ប្រាំមួយ) ខែ ឬ៣ (បី) ខែ។

៤-ទោសដាក់ពន្ធនាគារកំណត់ពី ២០ (ម្ភៃ) ឆ្នាំ ដល់ ៣០(សាមសិប) ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន ១២ (ដប់ពីរ) ខែ ឬ៩ (ប្រាំបួន) ខែ ឬ៦ (ប្រាំមួយ) ខែ ឬ៣ (បី) ខែ។

៥-ទោសដាក់ពន្ធនាគារមួយជីវិត អាចនឹងបន្ថយទោសលើកទី១ មកនៅត្រឹម ៣០ (សាមសិប) ឆ្នាំ។

**មាត្រា៩.-**

ទណ្ឌិតអាចទទួលការបន្ធូរបន្ថយទោសបានតែម្តងគត់ ក្នុងរយៈពេល ១២ (ដប់ពីរ) ខែ។

ទណ្ឌិតអាចទទួលការបន្ធូរបន្ថយទោសច្រើនដងបាន លុះត្រាតែទណ្ឌិតនោះបានទទួលរងទោសពាក់កណ្តាលនៃទោសដាក់ពន្ធនាគារដែលតុលាការបានកំណត់ ប៉ុន្តែត្រូវគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ។

ចំពោះទណ្ឌិតដែលត្រូវបានកំណត់ទោសដាក់ពន្ធនាគារមួយជីវិត ក្រោយពីបានបន្ថយមកនៅត្រឹម ៣០(សាមសិប)ឆ្នាំ អាចនឹងបានទទួលការបន្ធូរបន្ថយទោសច្រើនដងទៀតបាន។ ប៉ុន្តែ ទោះជាទណ្ឌិតនោះបានទទួលការបន្ធូរបន្ថយទោសច្រើនដងក៏ដោយ ក៏រយៈពេលនៃការទទួលរងទោសទាំងអស់ត្រូវឱ្យបានយ៉ាងតិច ២០(ម្ភៃ)ឆ្នាំ។

## ផ្នែកទី៣
## លក្ខខណ្ឌដោយឡែកនៃការលើកលែងទោស

**មាត្រា១០.-**

ទណ្ឌិតដែលបានបំពេញលក្ខខណ្ឌតាមបញ្ញត្តិនៃមាត្រា៥ នៃព្រះរាជក្រឹត្យនេះ អាចទទួលការលើកលែងទោស ក្នុងករណីទណ្ឌិតបានទទួលរងទោសដាក់ពន្ធនាគារ៖

១-ចំនួនពីរភាគបីនៃទោស។

២-ទណ្ឌិតដែលទទួលទោសដាក់ពន្ធនាគារអស់មួយជីវិត អាចទទួលការលើកលែងទោស ប្រសិនបើទណ្ឌិតនោះបានអនុវត្តទោសយ៉ាងតិច ៣០(សាមសិប)ឆ្នាំ ឬ២០(ម្ភៃ)ឆ្នាំ ក្នុងករណីដែលមានការបន្ធូរបន្ថយទោស។

## ជំពូកទី៤
## បែបបទ និងនីតិវិធីនៃការបន្ធូរបន្ថយទោស និងការលើកលែងទោស

**មាត្រា១១.-**

ប្រធានពន្ធនាគារត្រូវរៀបចំបញ្ជីឈ្មោះទណ្ឌិតដែលមានលក្ខណសម្បត្តិអាចស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស រួមនិងសំណុំឯកសារពាក់ព័ន្ធបញ្ជូនមកគណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ។

គណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ ត្រូវពិនិត្យ និងវាយតម្លៃអំពីឥរិយាបថប្រព្រឹត្តិរបស់ទណ្ឌិតម្នាក់ៗដែលបំពេញគ្រប់លក្ខខណ្ឌអាចស្នើសុំបន្ធូរបន្ថយទោស និងលើកលែង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ទោស និងត្រូវរៀបចំបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស រួមនិងសំណុំឯកសារពាក់ព័ន្ធបញ្ជូនទៅគណៈកម្មការថ្នាក់ជាតិ ពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស យ៉ាងយឺតបំផុត ៣០ (សាមសិប)ថ្ងៃមុនថ្ងៃកំណត់ដូចមានចែងក្នុងមាត្រា ៣ នៃព្រះរាជក្រឹត្យនេះ។

គំរូបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស រួមនិងសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ ត្រូវកំណត់ដោយគណៈកម្មការថ្នាក់ជាតិ។

**មាត្រា១២.-**

ទណ្ឌិតដែលយល់ឃើញថា ខ្លួនបានបំពេញលក្ខខណ្ឌក្នុងការស្នើសុំបន្ធូរបន្ថយទោស ឬលើកលែងទោស ប៉ុន្តែ មិនត្រូវបានប្រធានពន្ធនាគារធ្វើការស្នើសុំឲ្យខ្លួន សាមីខ្លួន ឬអ្នកតំណាងស្របច្បាប់មានសិទ្ធិប្តឹងតវ៉ាទៅគណៈកម្មការថ្នាក់ជាតិ ដោយមានការគាំទ្រពីក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគារ។ ពាក្យបណ្តឹងតវ៉ានេះ ត្រូវដាក់នៅគណៈកម្មការថ្នាក់ជាតិ ដោយផ្ទាល់ ឬតាមរយៈប្រធានពន្ធនាគារ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងតវ៉ានេះ ប្រធានពន្ធនាគារត្រូវបញ្ជូនពាក្យប្តឹងនេះ មកគណៈកម្មការថ្នាក់ជាតិ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ពាក់ព័ន្ធនឹងការអនុវត្តទោសរបស់ទណ្ឌិតនោះ។

**មាត្រា១៣.-**

គណៈកម្មការថ្នាក់ជាតិ ត្រូវប្រជុំពិនិត្យ និងវាយតម្លៃលើបញ្ជីឈ្មោះទណ្ឌិតដែលត្រូវស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស និងរៀបចំបែបបទជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចដើម្បីដាក់សំណើថ្វាយព្រះមហាក្សត្រសុំបន្ធូរបន្ថយទោស និងលើកលែងទោសឱ្យទណ្ឌិត យ៉ាងយឺតបំផុត ១០ (ដប់)ថ្ងៃមុនថ្ងៃកំណត់ដូចមានចែងក្នុងមាត្រា៣ នៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី៥
## ការអនុវត្តព្រះរាជក្រឹត្យបន្ធូរបន្ថយទោស និងលើកលែងទោស

**មាត្រា១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវរៀបចំសំណៅចែកផ្សាយជូនក្រសួងយុត្តិធម៌ដើម្បីចាត់ចែងអនុវត្ត ក្រោយពីបានទទួលព្រះរាជក្រឹត្យបន្ធូរបន្ថយទោស និងលើកលែងទោស។

**មាត្រា១៥.-**

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់បញ្ជូនព្រះរាជក្រឹត្យបន្ធូរបន្ថយទោស និងលើកលែងទោស ទៅព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី ខេត្តដែលមានសមត្ថកិច្ច ដើម្បីអនុវត្ត។

**មាត្រា១៦.-**

ចំពោះទណ្ឌិតដែលត្រូវបានលើកលែងទោសដោយព្រះរាជក្រឹត្យ នឹងត្រូវដោះលែងឱ្យមានសេរីភាពភ្លាម ដោយប្រធានពន្ធនាគារ បន្ទាប់ពីទទួលបានដីកាបង្គាប់ឱ្យដោះលែងទណ្ឌិតរបស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី ខេត្តដែលមានសមត្ថកិច្ច។

ទណ្ឌិតដែលត្រូវបានបន្ធូរបន្ថយទោសដោយព្រះរាជក្រឹត្យ លើកលែងឱ្យទណ្ឌិតនោះរួចផុតពីការអនុវត្តទោសសម្រាប់រយៈពេលដែលត្រូវបានបន្ធូរបន្ថយ។ ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង

រាជធានី ខេត្តដែលមានសមត្ថកិច្ច និងប្រធានពន្ធនាគារ ត្រូវធ្វើការប្រកាសផ្សព្វផ្សាយព្រះរាជក្រឹត្យបន្ធូរបន្ថយទោស ដល់ទណ្ឌិតដែលត្រូវបានបន្ធូរបន្ថយទោស។

**មាត្រា១៧.-**

ការបន្ធូរបន្ថយទោស និងការលើកលែងទោស មិនមែនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលសំណងជួសជុលការខូចខាតទេ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយនឹងព្រះរាជក្រឹត្យដែលពាក់ព័ន្ធនឹងការបន្ធូរបន្ថយទោស និងលើកលែងទោសនោះ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៨.-**

ក្រឹត្យលេខ២៨ក្រ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៨៨ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៩.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ អង្គារ ១៤រោច ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០២១

ពរស.ខ២០១.០៣២

**បានប្រមាប់ព្រះរាជលញ្ឆករហើយ**

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**